ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-Sep-2012, 13:45
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១០៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វេង ហ៊ត់

លោក ច័ន្ទ ដារារស្មី

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms.Christine MARTINEAU)*

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីន្ទូហ្វ៊ី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក នង សុផង់ (TCW-480) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក នន សុផង់** (TCW-480)
សួរបន្តដោយលោក អេនត្រូ អ៊ីនូហ្ស៊ី ផ្ដើមពី៖ ............................................................ ទំព័រ ៥
សួរដោយលោក ម៉ៃខល កាណាវាស ផ្ដើមពី៖ ............................................................ ទំព័រ ២០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:២៩]

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយ-ការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះ មានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការដោយផ្ទាល់ពីបន្ទប់សវនាការនេះ សម្រាប់រយៈពេលពេញ១ថ្ងៃ នៃថ្ងៃសវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ ដោយឡែកសាក្សីបន្ទាប់ដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម TCW-307 សាក្សីរូបនេះ មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមគោរព។

[០៩:០៣:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការដោយផ្ទាល់ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញ១ថ្ងៃនេះ។ លោកវេជ្ជបណ្ឌិត គួយ សំណាង គ្រូពេទ្យទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះបានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈអស់កម្លាំងជាប្រចាំ វិលមុខនៅពេលងើបឈរ ឬអង្គុយ ហត់នៅពេលធ្វើចលនា ឈឺចង្កេះ និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាត

ឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោម។ នៅពេលនេះ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការដោយផ្ទាល់ ដោយគាត់មានបញ្ហាសុខភាព ដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយ និងស្មារតីសមស្រប គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏សម្រួលដល់ទំនាក់ទំនងជាមួយ -- រវាងគាត់ ជាមួយនឹងក្រុមមេធាវីការពារក្ដីរបស់គាត់បានដែរ។

[០៩:០៥:០៧]

ហេតុដូច្នេះអង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះដោយផ្ទាល់ ដោយលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

[០៩:០៥:៤០]

ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន ជម្រាបលោក លោកស្រីចៅក្រម ភាគីទាំងអស់។

ជម្រាបសួរលោកសាក្សី សង្ឃឹមថាលោកនឹងបានសម្រាកស្រួលបួលយប់មិញ។ មុននឹងបន្តការតាំងសំណួរ ដើម្បីជាប្រតិចារឹក ខ្ញុំសូមលើកឡើងនូវអ្វីដែលលោកប្រធានបានលើកឡើងពីម្សិលមិញ។ ខ្ញុំបានពិនិត្យមើលទៅលើវិធាន៧៦(៧) ដែលវិធាននេះនិយាយថា “យោងទៅលើ -- អនុលោមទៅតាមបណ្ដឹងសាទុក្ខកំហុសនីតិវិធី ដែលស្ថិតនៅក្នុងអំឡុងពេលស៊ើបអង្កេត បញ្ហានេះអាចនឹងលើកនៅចំពោះមុខអង្គជំនុំជម្រះ ឬក៏នៅមុខអង្គជំនុំជម្រះតុលាការកំពូល”។ អ្វីដែលយើងខ្ញុំបានលើកឡើងមកនិយាយ

ក្នុងនាមជាក្រុមមេធាវីការពារក្តី នួន ជា នោះ មិនមែនជាបញ្ហាដែលអ្នកណាម្នាក់អាចលើកឡើងថាវាជាកំហុសនីតិវិធីនោះទេ។ អ្វីដែលលើកឡើងបាននិយាយ គឺជាបញ្ហាពាក់ព័ន្ធទៅនឹងសវនាការប្រកបទៅដោយយុត្តិធម៌ គឺយើងគោរពទៅតាមនីតិវិធី ដោយមិនទាន់គិតទៅដល់ភាពគួរឱ្យទុកចិត្តបានចំពោះសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនោះផង។

[០៩:០៧:២៩]

ដូច្នេះយើងខ្ញុំគ្រាន់តែនិយាយថា ទាក់ទងទៅនឹងសវនាការនៅក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណី គឺថាសាក្សីត្រូវតែផ្តល់សក្ខីកម្ម ហើយបើសិនណាមានអង្គហេតុលេចឡើងនៅក្នុងពេលសវនាការនោះ គឺថាខ្ញុំយល់ឃើញថាវាមិនមែនជាកំហុសនីតិវិធីទេ ប៉ុន្តែវាជាខ្លឹមសារដែលត្រូវយកមកនៅក្នុងដំណាក់កាលសវនាការនេះតែម្តង។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ព្រឹកមិញនេះ យើងបាន -- បើយើងមិនប្រើពាក្យមិនច្រឡំទេ យើងបានផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ នេះយើងប្រើពាក្យត្រឹមត្រូវណាស់។ ប្រហែលជាទំនងយើងមិនបានផ្តល់វេទិកាឱ្យលោកឡើងមានមតិយោបល់តាមតែចិត្តលោកចង់ទេ តាមទំនងមើលទៅ។

[០៩:០៨:៣៤]

បញ្ហាដែលយើងបានបង្ហាញនេះ ក្នុងន័យដែលលោកបានលើកឡើងអំពីបញ្ហាធ្ងន់ធ្ងរនៃបញ្ហាដែលកើតឡើងនៅក្នុងអំឡុងពេលនៃការដាក់ដេញដោល នូវកំណត់ហេតុស្តាប់សក្ខីកម្មសាក្សីជាច្រើន ដែលយើងបានសម្រេចពីម្សិលមិញរួចហើយ ហើយយើងបានជម្រាបលោកថា ដើម្បីឱ្យបញ្ហានេះជ្រះស្រលះបើលោកនៅតែយល់ដូច្នេះ គួរតែលោកត្រូវបានដាក់ជាសំណើសុំ ជាលាយលក្ខណ៍អក្សរដើម្បីបង្ហាញអំពីសំអាងហេតុឱ្យបានជាក់ច្បាស់ ហ្មត់ចត់ គ្រាន់តែយើងឱ្យលោកពិចារណាលើបទប្បញ្ញត្តិនៃវិធាននីតិវិធីដែលពាក់ព័ន្ធ គឺ ៧៦ អនុវិធាន៧ ដែលចែងច្បាស់ថា “លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ ដោយ អ៎!គឺតាមស៊ើបសួរ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនៃនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ”។ នេះជាការគិតពិចារណាគ្រាន់តែចង្អុលបង្ហាញទៅលោក ទន្ទឹមនឹងលោកដែលពិចារណាលើការដាក់សំណើរបស់លោក។ ម្សិលមិញយើង

បានបញ្ជាក់ហើយ ថាយើងដោះស្រាយលើបញ្ហាសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ដើម្បីឱ្យដោះស្រាយបញ្ហាមិនឱ្យគាត់មកនៅរ៉ាំរ៉ៃនៅក្នុងអង្គជំនុំជម្រះនេះ ច្រើនសប្តាហ៍ទៅមុខទៀតទេ ដោយរង់ចាំការសម្រេចជាលាយលក្ខណ៍ ហើយតម្រូវឱ្យគាត់មកសប្តាហ៍ ឬក៏សប្តាហ៍មួយទៀតទេ។ ប្រសិនបើលោកគ្មានសំណួរទេ គឺនិយាយឱ្យច្បាស់លាស់ គឺយើងប្រគល់វេទិកានេះ ទៅមេធាវីផ្សេងទៀត ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី។

[០៩:១០:៤១]

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ដោយសារតែពាក់ព័ន្ធសេរីភាពនៃការបញ្ចេញមតិនៅក្នុងបន្ទប់សវនាការ ខ្ញុំសូមឆ្លើយតប ទាក់ទងទៅនឹងវិធាន៧៦.៧ នេះ។

**ប្រធានអង្គជំនុំ៖**

យើងជូនវេទិកាលោកសួរសំណួរ។ វិធាននេះ ប្រសិនបើលោកមានបំណងនៅក្នុងការដាក់ឯកសារជាលាយលក្ខណ៍អក្សរអំពីបញ្ហាដែលលោកលើកឡើងពីម្សិលមិញ អំពីវិការៈនៃកំណត់ហេតុស្តាប់សក្ខីកម្មសាក្សីដែលត្រូវ -- នឹងត្រូវយកមកដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនាពេលអនាគត ឬក៏កន្លងមក លោកពិចារណា ហើយលោកផ្អែកលើបញ្ហាទាំងអស់នេះ ដើម្បីរៀបចំនូវសំណើសុំរបស់លោកចុះ។ យើងគ្រាន់តែរំឭកលោកដើម្បីពិចារណាលើបញ្ហានេះ ពាក់ព័ន្ធទៅនឹងសំណើដែលយើងបានជម្រាបលោកកាលពីម្សិលមិញថា ប្រសិនបើបញ្ហានេះ វាធ្ងន់ធ្ងរអ៊ីចឹង ដូចលោកបាននិយាយអ៊ីចឹង វាធ្ងន់ធ្ងរពេក គប្បីប្រើប្រាស់នូវសិទ្ធិរបស់លោកដែលមានការពាក់ព័ន្ធទៅនឹងវិធានកំណត់ សមត្ថកិច្ចសិទ្ធិអំណាចរបស់លោកក្នុងការអនុវត្តសិទ្ធិចំពោះអង្គជំនុំជម្រះ គ្រាន់តែមានការចាប់អារម្មណ៍ផងដែរលើវិធានដែលយើងបានចង្អុលបង្ហាញប៉ុណ្ណោះ មិនមែនយកមកដោះស្រាយសាក្សីរូបនេះទេ។

យើងបានជ្រាបហើយ យើងមិនបណ្តែតបណ្តោយឱ្យលោកយកវេទិកានេះ ថ្លែងតាមតែចិត្តលោកចង់ទេ ដើម្បីក្នុងគោលបំណងជំរុញប្រសិទ្ធភាពនៃដំណើរការសវនាការឱ្យបានឆាប់រហ័ស។

[០៩:១២:២៦]

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក អេនត្រូ អ៊ីនួហ្ស៊ី៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនតូចទៀត មិនជាយូរប៉ុន្មានទេ។ ប្រហែលជាខ្ញុំត្រូវការតែ១ម៉ោងទេ អាចនឹងចប់នៅមុនសម្រាកព្រឹកនេះ។ ហើយខ្ញុំនឹងព្យាយាមនិយាយឲ្យបានយឺត ដើម្បីសម្រួលដល់អ្នកបកប្រែ។ ខ្ញុំសូមចាប់ផ្ដើមជាមួយនឹងបញ្ហាដែលខ្ញុំលើកឡើងពីម្សិលមិញ ដែលលោកសហការីរបស់ខ្ញុំ គឺលោក សុន អរុណ បានលើកឡើងនោះ។ ខ្ញុំមិនមែនមានន័យថា ជំរុញឲ្យលោកឆ្លើយទៅនឹងសំណួរណាមួយនោះទេ។ ដូច្នេះ ខ្ញុំសូមត្រឡប់ទៅអ្វីដែលលោកមេធាវី សុន អរុណ លើកឡើងពីម្សិលមិញ គឺទាក់ទងទៅនឹងតួនាទីរបស់លោក នួន ជា ក្នុងឋានៈជាតំណាងឲ្យសភាតំណាងប្រជាជននោះ។

[០៩:១៣:២៧]

មុននឹងតាមដាន -- មុននឹងត្រឡប់ទៅនឹងសំណួររបស់ខ្ញុំ ដើម្បីជាប្រតិចារឹក នួន ជា មិនដែលបដិសេធថាគាត់មិនធ្លាប់បានធ្វើជាប្រធានសភាតំណាងប្រជាជននោះទេ គាត់បានទទួលស្គាល់ ថាគាត់បានធ្វើជាសភាតំណាងប្រជាជន។ ហើយគាត់មិនមានអ្វីដែលត្រូវអៀនខ្មាសថា លាក់លៀមថាគាត់មិនមែនជាប្រធានសភានោះទេ គឺគាត់ជាប្រធានសភាតំណាងប្រជាជន។ លោកសាក្សី ថាតើធ្វើម៉េចបានជាលោកដឹងច្បាស់ថា ដែលលោកបានលើកប៉ុន្មានសាហើយ ថាលោកទទួល -- នួន ជា ទទួលខុសត្រូវចំពោះប្រជាជន។ ដូច្នេះ មុននឹងតាំងសំណួរ គឺខ្ញុំសុំៗរំឭកទៅដល់លោក អ្វីលោកជម្រាបទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីកាលពីថ្ងៃអង្គារនោះ គឺសូមជួយកែតម្រូវខ្ញុំផង ប្រសិនណាជាខ្ញុំលើកឡើងមិនត្រឹមត្រូវ។ ខ្ញុំសូមដកស្រង់ពីប្រតិចារឹកទំព័រ ៥៦-៥៧ នៅពេលដែលលោកសាកសួរទៅនឹងឯកសារទាំងនេះដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា “ម៉េចបានជាកូពី -- ថតចម្លងទៅឲ្យ នួន ជា?” លោកឆ្លើយថា ដកស្រង់ “ដោយសារបញ្ហានេះ គឺលោក នួន ជា ទទួលខុសត្រូវចំពោះប្រជាជន ហើយគាត់ទទួលខុសត្រូវថ្នាក់តំបន់ដែលពាក់ព័ន្ធទៅនឹងប្រជាជន”។

[០៩:១៥:០១]

មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានសួរថា “តើការទទួលខុសត្រូវពិតប្រាកដរបស់ នួន ជា គឺអ្វី?” លោកឆ្លើយថា “គឺជាការប្រកាសជាសាធារណៈដែលលោក នួន ជា គឺតំណាងឲ្យ -- គឺៗជាតំណាងឲ្យសភាតំណាងឲ្យប្រជាជន គាត់ទទួលខុសត្រូវចំពោះប្រជាជន។ ដូច្នេះក្នុងឋានៈជាតំណាងឲ្យ

សភាតំណាងប្រជាជន គាត់មានការពាក់ព័ន្ធនឹងប្រជាជន ហើយគាត់ជាស្ថាប័នកំពូលមួយដែលត្រូវទទួលខុសត្រូវបញ្ហាទាំងអស់ពាក់ព័ន្ធទៅនឹងប្រជាជន ដោយសារតែគាត់ជាតំណាងឲ្យសភាតំណាងប្រជាជននេះ"។ លោកសាក្សី លោកនៅចាំទេថា លោកបានឆ្លើយចម្លើយនេះទៅនឹងសំណួររបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកាលពីថ្ងៃអង្គារ?

[០៩:១៥:៥៤]

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំបានចងចាំនូវពាក្យសម្ដីខ្ញុំដែលខ្ញុំបានឆ្លើយអ៊ីចឹងមែន។ គឺខ្ញុំដឹងជាចំហទេ ឯកិច្ចការផ្ទៃក្នុងដែលអចិន្ត្រៃយ៍លោកចាត់ចែងការងារទៅលើលោក នួន ជា យ៉ាងណាៗ ខ្ញុំអត់ដឹង។ តាមខ្ញុំដឹងគឺនិយាយតាមខ្ញុំយល់ ពីព្រោះថាលោកជាសភាតំណាងប្រជាជន។ អ៊ីចឹងគឺបានន័យថា តំណាងប្រជាជនទៅហើយ អ្វីៗដែលជាការ -- គេធ្វើអ្វីខាងមូលដ្ឋានគេធ្វើអ្វីដែលប៉ះពាល់ដល់ប្រជាជន គឺមានលោកជាតំណាងមួយនៅក្នុងស្ថាប័នកំពូលរបស់ប្រទេសហ្នឹង ដែលជាអ្នកត្រូវដឹង ត្រូវឮ ហើយក៏ត្រូវការពារប្រជាជន។ អានេះគឺតាមការយល់ដឹងរបស់ខ្ញុំទេ មិនមែនជាការយល់ដឹងថា អចិន្ត្រៃយ៍អ្នកចាត់ចែងឲ្យលោកទទួលខាងប្រជាជននោះទេ។ បាទ នេះជាគំនិតដែលខ្ញុំយល់ថា ក្នុងឋានៈជាតំណាងរាស្ត្រម្នាក់ៗ ហើយលោកមិនមែនជាតំណាងរាស្ត្រផង គឺថាជាប្រធានរដ្ឋសភា តំណាងប្រជាជនទូទាំងប្រទេសបាទ។ អ៊ីចឹងកិច្ចការអ្វីៗដែលទាក់ទងនឹងសុខទុក្ខរបស់ប្រជាជន លោកក៏ត្រូវតែដឹងបាទ។ នេះជាយោបល់ផ្ទាល់របស់ខ្ញុំទេបាទ។

[០៩:១៨:១៩]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមនិយាយអំពីចំណុចទី១ ដែលលោកនិយាយអំពីការប្រកាសព័ត៌មានជាសាធារណៈ។ ថាតើការប្រកាសជាសាធារណៈនេះ តើវានិយាយអំពី -- ដែលថាលោក នួន ជា គឺជាតំណាងឲ្យសភាតំណាងប្រជាជននោះ ឬយ៉ាងណា?

**ឆ៖** បាទ ដែលខ្ញុំដឹងជាសាធារណៈ គឺខ្ញុំបានស្ដាប់វិទ្យុកម្ពុជាប្រជាធិបតេយ្យ ពេលខ្ញុំធ្វើការបណ្ដើរ ខ្ញុំបើកវិទ្យុស្ដាប់ជាបណ្ដើរៗ ដើម្បីដឹងដំណឹងនៃការដែលប្រទេសយើងវារីកចម្រើនប៉ុនណាៗក្នុងសម័យនោះ។ នៅ -- ខ្ញុំចាំឆ្នាំមិនច្បាស់ទេ គឺបើតាមខ្ញុំចងចាំខ្លះគឺប្រហែលជាក្នុងឆ្នាំ៧៦ គេបានប្រជុំសភានីតិកាលទី១ បាទ។ ហើយគេបានប្រកាសផ្សាយថា នរណាៗទទួលគណៈប្រធានរដ្ឋ, ការរៀបចំរាជរដ្ឋាភិបាលយ៉ាងម៉េច, នរណាជារដ្ឋមន្ត្រីទី១, នរណាជាឧបនាយករដ្ឋមន្ត្រី, នរណាជារដ្ឋមន្ត្រី។

អានេះគឺខ្ញុំដឹងតាមរយៈវិទ្យុហ្នឹង។

[០៩:២០:០៨]

ឯខាងសភាតំណាងប្រជាជនក៏អ៊ីចឹងដែរ គេបានប្រកាសផ្សាយថា នៅស្ថាប័នសភាតំណាងប្រជាជនហ្នឹងគឺ មានលោក នួន ជា ហ្នឹងហើយជាប្រធានសភាបាទ តំណាងប្រជាជនហ្នឹង។ ឯខាងតុលាការគឺមានលោក កង ចាប ហ្នឹងហើយជាប្រធាន។ ឯគណៈប្រធានរដ្ឋ ក៏មានលោក ខៀវ សំផន ហ្នឹងហើយជាប្រធានបាទ។ ការផ្សាយនេះគឺមិន -- ខ្ញុំមិនបានឃើញជាលាយលក្ខណ៍អក្សរនៃការរៀបចំអីច្បាស់លាស់ទេ ប៉ុន្តែនេះគឺជាការ អ្វីដែលខ្ញុំចងចាំបានខ្លះៗ ពីព្រោះថា រយៈពេលជាង៣០ឆ្នាំមកហើយ អ្នកណាទៅចាំបានអស់បាទ។ នេះគឺ សូមជូនយោបល់ខ្លីៗបាទ ប៉ុណ្ណឹងចុះ។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរមួយចុងក្រោយទៅលើប្រធានបទនេះ។ នៅពេលដែលលោកនិយាយថា នួន ជា គឺជាប្រធានសភាតំណាងប្រជាជន។ តាមដែលលោកចាំក្រៅពីហ្នឹង ថាតើគេមាននិយាយអំពីអ្វីទៀត មាននិយាយថាតើគាត់មានទទួលមុខនាទីអ្វីទៀតដែរទេ តាមអ្វីដែលលោកចាំនោះ?

**ឆ៖** ខ្ញុំមិនបានចងចាំទេបាទ ហើយក៏ខ្ញុំមិនដឹងដែរបាទ។

**ស៖** បាទ សូមអរគុណ។ បន្តចូលទៅប្រធានបទមួយទៀត ជាពិសេសសារទូរលេខ សារទូរលេខ៥៤ ដែលបានយកមកពិភាក្សាគ្នាមួយរយៈមកហើយ។ ខ្ញុំមិនចង់សួរទៅលើខ្លឹមសារ នៃទូរលេខនេះទេ ឯកសារនេះគឺ E3/513 គឺជាឯកសារដែលបានពិភាក្សាគ្នារួចមកហើយ។ បើសិនណាជាលោកនៅចាំបានលោកសាក្សី ថាតើទូរលេខហ្នឹងក្នុងចំណោមបញ្ហាជាច្រើន វាពាក់ព័ន្ធទៅនឹងបញ្ហាសីលធម៌ ពាក់ព័ន្ធទៅនឹងមនុស្សម្នាក់ឈ្មោះថា សុខ នោះ អ្វីដែលលោកជម្រាបទៅការិយាល័យសហព្រះរាជអាជ្ញានោះ គឺលោកបាននិយាយអំពីសារទូរលេខមួយៗ ដែលនិយាយអំពីកំហុសសីលធម៌របស់មនុស្សម្នាក់ឈ្មោះ សុខ ទេ?

**ឆ៖** បាទ ខ្ញុំបានចាំបាន ជា--

[០៩:២២:៥៨]

**ស៖** បាទ សូមអរគុណច្រើន។ ខ្ញុំសូមដកស្រង់ចេញពីប្រតិចារឹក ជាសេចក្តីព្រាងប្រតិចារឹកថ្ងៃចន្ទ ថ្ងៃទី០៣ ខែកញ្ញា ២០១២ នេះ សំណួរ “នៅពេលថាតើហេតុម៉េចបានជាទូរលេខនេះ ត្រូវផ្ញើទៅនួន ជា?” លោកនិយាយថា “អ្វីដែលពាក់ព័ន្ធទៅនឹងបញ្ហាផ្ទៃក្នុង ហើយនិងការរំលោភទៅលើសីលធម៌

គឺគេត្រូវតែទាក់ទងទៅលោក នួន ជា ពីព្រោះ នួន ជា ពាក់ព័ន្ធ -- ព្រោះ នួន ជា ទទួលខុសត្រូវខាងប្រជាជន"។ តើនេះគឺជាសម្រង់មួយ ដែលខ្ញុំលើកឡើងត្រឹមត្រូវទៅពាក់ព័ន្ធទៅនឹងបញ្ហាផ្ទៃក្នុង ទូរលេខណាពាក់ព័ន្ធនឹងបញ្ហាផ្ទៃក្នុងត្រូវផ្ញើទៅ នួន ជា? "នៅពេលនោះគឺថា ខ្ញុំ -- ប៉ុន ជាអ្នកដឹងអំពីបញ្ហានេះ ប៉ុន្តែតាមដែលខ្ញុំដឹង បានជាសារនេះត្រូវផ្ញើទៅឲ្យអ៊ំ នួន ជា នោះគឺដោយសារថា គាត់ទទួលខុសត្រូវទៅនឹងបញ្ហាសង្គម សីលធម៌។ អ្វីដែលបំពានទៅដល់បញ្ហាសីលធម៌ គឺ អ៊ំ នួន ជា គឺជាអ្នកដែលត្រូវទទួលនូវសារបែបនេះ។ នេះតាមដែលខ្ញុំដឹង"។ បញ្ចប់ការដកស្រង់។

[០៩:២៤:២៧]

ទាក់ទងទៅនឹងសារនេះ ជាពិសេសអ្វីដែលលោកបាននិយាយយោងថាវាជាការវិភាគរបស់លោកនោះ។ ដូច្នេះសំណួររបស់ខ្ញុំ ថាតើលោកយល់ស្របទេ ថាការវិភាគរបស់លោកជូនទៅដល់ការិយាល័យសហព្រះរាជអាជ្ញា គឺត្រូវបានធ្វើឡើងក្រោយពីអង្គហេតុកើតឡើងយ៉ាងយូរណាស់មកហើយ ទាក់ទងទៅនឹងសារលេខនៃកម្ពុជាប្រជាធិបតេយ្យនេះ។ តើលោកនៅចាំបានទេ? តើការដកស្រង់របស់ខ្ញុំនេះត្រឹមត្រូវទេ?

**ឆៈ** បាទ ជាការត្រឹមត្រូវហើយ ដែលលោកបានរៀបរាប់អម្បាញ់មិញនេះ។ អ៊ីចឹងខ្ញុំក៏ -- ដែលឆ្លើយទៅខាងសហព្រះរាជអាជ្ញា -- ចៅក្រមស៊ើប អ៊ំ! ទៅនឹងចៅក្រមស៊ើបអង្កេតហ្នឹង ក៏ខ្ញុំមិនប្រាកដខ្លួនឯងថា សារហ្នឹងត្រូវតែជូនទៅលោក នួន ជា នោះទេ។ ក៏ប៉ុន្តែវាឃើញចំណាររបស់គេ គេដាក់ថាអ៊ំនួន បាទ។ អ៊ីចឹង ខ្ញុំបានជូនយោបល់ទៅក្រុមចៅក្រមស៊ើបអង្កេតថា តាមការវិភាគរបស់ខ្ញុំបានជាគេជូនសារនេះទៅអ៊ំនួន ព្រោះជាសារដែលវាទាក់ទងនឹងបញ្ហាសីលធម៌បាទ។ ហើយក៏វាជាបញ្ហាដែលទាក់ទងទៅនឹងសភាប្រជាជនដែរ ដែលត្រូវតែដឹងរឿងហ្នឹងថា អ្វីដែលអ្នកណារំលោភលើអ្នកណា ព្រោះប្រជាជនម្នាក់ក៏ជាកូនចៅរបស់លោកដែរ នៅក្នុងសម័យហ្នឹង ព្រោះលោកជាតំណាងហើយបាទ។ នេះគឺតាមការវិភាគរបស់ខ្ញុំក្នុងពេលនោះ។ បើអង្គប្រជុំយល់ឃើញថា ការវិភាគ ការពន្យល់គឺចាត់ទុកថាមិនបានការ ក៏ខ្ញុំយល់ព្រម ខ្ញុំសុខចិត្តឲ្យលុបនូវចម្លើយរបស់ខ្ញុំហ្នឹងទៀត។ ពីព្រោះការពន្យល់របស់ខ្ញុំហ្នឹង វាខុស។ បាទ អានេះខ្ញុំសូមឲ្យអង្គសវនាការពិនិត្យទៀតលើ ខ ហ្នឹង។ បើអាចលុបបានក៏លុបចុះ បាទ។ វាដូចជាការប្រហែល ដូចជាវាថាអាចអ៊ីចេះ អាចអ៊ីចុះដែរ ការវិភាគនេះ។ វាមិនមែនជាការពិតទេ។

[០៩:២៧:៣៣]

**ស៖** សូមអរគុណចំពោះចម្លើយនេះ លោកសាក្សី។ ការសន្និតជាក់លាក់មួយនេះ គឺយោងទៅលើបញ្ហាពីរ ទី១ តួនាទីរបស់លោក នួន ជា និងមួយទៀតដោយសារថា មានការសរសេរដាក់ថា "ចម្លងជូនអ៊ំនួន" ទើបលោកធ្វើការសន្និតបែបនេះ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនបាទ ព្រោះឃើញថា គេចារច្បាស់ថា អ៊ំនួន ហើយ ឲ្យខ្ញុំថាអ៊ំណាទៀត។ អានេះវាមិនត្រូវបាទ។

**ស៖** សូមអរគុណច្រើនចំពោះការបំភ្លឺនេះ លោកសាក្សី។ ខ្ញុំចូលទៅប្រធានបទមួយទៀត កាលពីម្សិលមិញពេលព្រឹក លោកបានជម្រាបលោកចៅក្រម ឡាវែន៍ អំពីទូរលេខមួយចំនួន។ គឺកាលពីព្រឹកម្សិលមិញ គឺមុននឹងឈប់សម្រាកនៅ -- ឈប់សម្រាក -- ក្រោយពេលឈប់សម្រាកពេលព្រឹក គឺថាមុននោះ គឺលោកបានជម្រាបទៅចៅក្រម ឡាវែន៍។ លោកចាំទេ?

**ឆ៖** បាទ លោកនិយាយសំណួរហ្នឹង។ ខ្ញុំមិនសូវស្រួលខ្លួនផង បើអ៊ីចឹងខ្ញុំមិនមានការចងចាំថា ម៉ោងណា ពេលណាដែលលោកលើកសំណួរ គឺលោកលើកអ៊ីចឹង គឺនាំឲ្យខ្ញុំ សុខភាពខ្ញុំកាន់តែយ៉ាប់ទៀតហើយ។ អ៊ីចឹងគឺសូមសំណួរត្រង់ៗមកចុះបាទ។

[០៩:២៩:១២]

**ស៖** សូមអភ័យទោសលោកសាក្សី ដែលខ្ញុំមិនបានដឹងថា លោកមិនស្រួលខ្លួន។ លោកសុខភាពស្រួលបួលទេ លោកអាចបន្តទៅទៀតបានទេ?

**ឆ៖** បាទ មិនអីទេ។ ប៉ុន្តែ សូមប្រើសំណួរឲ្យច្បាស់ៗ។ បើជាសំណួរបិទ ពេលណាអី អីណា? ខ្ញុំមិនចងចាំទេ ព្រោះថា សំណួរអី គឺសំណួរហ្នឹងតែម្តងបាទ។ បាទ វាស្រួលក្នុងការឆ្លើយបាទ។

**ស៖** លោកចៅក្រម ឡាវែន៍ គឺគាត់អង្គុយឆ្ងាយខិតទៅខាងណោះ។ ពីម្សិលមិញ គាត់បានពិភាក្សានូវឯកសារមួយចំនួន លើកមកសួរចំពោះលោក។ នេះជាសំណួរទី១ តើលោកចាំទេថា លោកចៅក្រម ឡាវែន៍ បានសួរឯកសារឯកសារមួយចំនួនទៅចំពោះលោក លោកចាំទេ?

**ឆ៖** បាទ លោកចៅក្រមណា? ចៅក្រមបរទេសឬមួយក៏ខ្មែរ? លោករូបណាមួយដែលឲ្យឯកសារខ្ញុំហ្នឹងបាទ?

**ស៖** គឺចៅក្រមបរទេសជាជនជាតិបារាំង លោកមើលទៅគឺលោកពាក់វ៉ែនតា គឺទី២ បន្ទាប់ពីខាងស្តាំមក លោកបែរទៅឃើញខាងស្តាំដៃរបស់លោក ទាល់មុខហ្នឹងតែម្តង គឺចៅក្រមដែលខ្ពស់បន្តិច ហើយពាក់វ៉ែនតាហ្នឹង។

**ឆ៖** បាទ ខ្ញុំបានចងចាំបានខ្លះ ប៉ុន្តែដូចច្រើនដែរ តែខ្ញុំសូមខាងការងាររដ្ឋបាលលោកជួយរៀបចំ អាណាខ្លះដែលជារបស់លោកចៅក្រមខាងនុ៎ងបាទ ដើម្បីខ្ញុំងាយស្រួលក្នុងការឆ្លងឆ្លើយ។ ព្រោះវា -- លោកឃើញទេសារមួយកំភ្លូសនេះ ខ្ញុំពិបាកហ្នឹងរៀបថា នរណាដែលជាទូរលេខណាដែលលោកខាងនោះឲ្យខ្ញុំ ព្រោះទូរលេខឲ្យខ្ញុំហ្នឹងមួយកំភ្លូសអ៊ីចឹង មិនដឹងឯណាឯណីទេបាទ។

[០៩:៣១:២៣]

**ប្រធានអង្គជំនុំ៖**

លោកអាចឆ្លើយថា បើលោកចាំ លោកថាចាំទៅ។ លោកចាំមិនបានទេ ថាចាំមិនបានទេ។ នេះជាការចប់ហើយ។ មិនៗចាំបាច់មករើអីជាក់ស្តែងនោះទេ។ ទី១ គ្រាន់តែលោកឆ្លើយថា លោកពិតជាបានឆ្លើយតបនឹងសំណួរមួយចំនួន ហើយនិងឯកសារមួយចំនួនទៅចប់ហើយ។ មានអ្នកណាចាំ! អ្នកដែលចូលរួមទាំងអស់នេះក៏មិនចាំដែរ គិតទាំងអ្នកសួរហ្នឹងក៏មិនចាំដែរ។

**លោក នង សុផង់៖**

**ឆ៖** បាទ អ៊ីចឹងមែនលោកប្រធាន។ ខ្ញុំមិនចងចាំទេបាទ។

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** ខ្ញុំក៏អត់ចាំដែរ។ លោកសាក្សី លោកបានឆ្លើយសំណួរមួយចំនួនហើយពាក់ព័ន្ធទៅនឹងឯកសារនេះ ហើយខ្ញុំមិនចង់ដឹងទៅលើខ្លឹមសារសំខាន់នោះទេ។ ក៏ប៉ុន្តែមានឯកសារមួយចំនួនតែប៉ុណ្ណោះដែលខ្ញុំចង់ដឹង។ សារទូរលេខមួយ ក្នុងនោះគឺគាត់បានលើកឡើងឯកសារទូរលេខនីមួយៗ ហើយគាត់បានបញ្ជាក់ថា នួន ជា ក្នុងចំណោមអ្នកដទៃទៀតនោះ មានដាក់សរសេរឈ្មោះនៅក្នុងនោះ ដែលគេចម្លងជូនគាត់ផងដែរ។ តើលោកចាំទេថា ឯកសារហ្នឹងគឺមានចម្លងជូនលោក នួន ជា ផងដែរនោះក្នុងចំណោមអ្នកផ្សេង? មិនជាអ្វីទេប្រសិនបើលោកមិនចាំ។

[០៩:៣៣:០០]

**ឆ៖** បាទ និយាយអំពីការចម្លងជូនគ្រប់សារទាំងអស់ គឺកម្របាត់ណាស់ឈ្មោះលោក នួន ជា។ បាទ គឺខ្ញុំរៀបរាប់គ្រប់សារទាំងអស់ហ្នឹងគឺមានអ៊ំ, អ៊ំនួន ជាទី២ហើយ។ បន្ទាប់ពីអ៊ំទី១ ប៉ុល ពត ហ្នឹងសារអ្វីទាំងអស់គឺគេដាកអ៊ីចឹងមក មិនដែលខានទេ អ៊ំនួន នេះ ហើយបន្ទាប់មក អ៊ំវ៉ាន់។ ហើយគេមានលំដាប់របស់គេទៀត អត់មានទៅថា ឲ្យដាក់ អ៊ំវ៉ាន់ មុន អ៊ំនួន ហ្នឹងបានទេ។ ហើយក៏មិនដាក់ -- មិនអាចដាក់ អ៊ំនួន ហ្នឹងឲ្យមុនពីលើអ៊ំៗទី១ ហ្នឹងបានទេ។ នេះការចម្លងជូនគឺវាមានលំដាប់របស់គេ។ ដូចខ្ញុំ

រៀបរាប់លោក -- ជូនលោកហើយ រឿងចម្លងជូន គោលការណ៍គេត្រូវដាក់អ៊ំ គឺប៉ុល ពត ហ្នឹងទី១ ហើយ បន្ទាប់មក អ៊ំនួន ហ្នឹងជាទី២, អ៊ំវ៉ាន់ ហ្នឹងជាលំដាប់ទី៣, ហើយអ៊ំវន ហ្នឹងលំដាប់ទី៤, អ៊ំខៀវ ហ្នឹងលំដាប់លេខទី៥។ បាទ នេះចំពោះឈ្មោះមនុស្ស។ ឯក្រៅពីហ្នឹងគឺមានតែពីរទៀតទេ មន្ទីរ និង ឯកសារ។ អានេះមិនមែនសំដៅលើឈ្មោះអ៊ំណាមួយទេណេះ។ បាទ បានបញ្ជាក់ហូរហែមកហើយ រឿងនេះបាទ។ អ៊ីចឹងលោកមិនច្បាស់យ៉ាងម៉េចទៀត?

[០៩:៣៤:៤០]

**ស៖** សូមអរគុណ។ ពេលខ្លះទៅខ្ញុំឮចំណុចវាខុសៗគ្នាច្រើនពេក។ ខ្ញុំសូមបញ្ជាក់បំភ្លឺតែប៉ុណ្ណោះ។ សំណួរដែលខ្ញុំចង់សួរនោះ គឺផ្អែកអ្វីដែលលោកប្រាប់យើងខ្ញុំកាលពីម្សិលមិញ អំពីការដឹងរបស់លោក តែដឹងនោះគឺវាមានលក្ខណៈកម្រិតតែប៉ុណ្ណោះ។ តើលោកបានចាំទេ ម្សិលមិញនោះយើងពិភាក្សាគ្នាថា លោកអ្វីដែលលោកដឹងហ្នឹងគឺមានកម្រិតតែប៉ុណ្ណោះ លោកចាំថាលោកបាននិយាយជាមួយខ្ញុំអ៊ីចឹងទេ?

**ផ៖** បាទ អ៊ីចឹងមែន គឺលោកដឹងស្រាប់ហើយកម្រិតរបស់ខ្ញុំគឺអ្វីដែលខ្ញុំដឹង គឺដឹងទូទៅដូចជាប្រជាជននៅលើសកលលោកដែរ កម្រិតរបស់ខ្ញុំហ្នឹង។ មិនមានដឹងការរាក់ជ្រៅរបស់អចិន្ត្រៃយ៍នោះទេបាទ។

**ស៖** សូមអរគុណច្រើនលោកសាក្សី។ ខ្ញុំឈប់ពិភាក្សាលើប្រធានបទនេះហើយ ក៏ប៉ុន្តែពេលខ្លះអាចត្រឡប់មកសួរចំណុចនេះឡើងវិញ។ ខ្ញុំសូមបន្តទៅមុខទៀតឲ្យបានលឿន ចូលប្រធានបទមួយទៀត។ នៅពេលនេះ ខ្ញុំចង់ពិភាក្សាលើកឡើងអំពីការបញ្ជូនៗសារទូរលេខចេញពី នួន ជា និងទៅ នួន ជា។ ខ្ញុំចង់ពិភាក្សាជាក់លាក់ទៅលើសារទូរលេខចេញចូលសម្រាប់បញ្ជូនទៅ នួន ជា និងបញ្ជូនមក នួន ជា។ ខ្ញុំចង់សួរបញ្ជាក់ចំណុចដែលលោកឆ្លើយប្រាប់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកាលពីថ្ងៃអង្គារតាមអ្វីដែលលោកឆ្លើយ និងប្រាប់យើងខ្ញុំរួមទាំងលោក សុន អរុណ ផងដែរ ក្នុងពេលដែលលោកធ្វើការងារជាអ្នកបកប្រែទូរលេខ ១០ឆ្នាំនោះ គឺលោកបានធ្វើការបកប្រែសាររបស់លោក នួន ជា តែម្ដងគត់នៅឆ្នាំ១៩៧៧ គឺលិខិតអញ្ជើញឲ្យចូលរួមប្រជុំជាមួយនឹងសភាតំណាងប្រជាជន។ តើត្រឹមត្រូវដែរឬទេ?

[០៩:៣៧:០២]

**ផ៖** បាទ អាហ្នឹងម្ដង។ ហើយក៏មានអង្កាល់នោះហ្នឹង ខ្ញុំក៏មិនចាំកាលបរិច្ឆេទទេ គឺនៅពេល

ដែលប្រជាជនយើងជួបគ្រោះ មិនដឹងជារាំងស្ងួត មិនដឹងជាទឹកជំនន់ទេ។ អាចទឹកជំនន់ បាទ លោកបាន ធ្វើសេចក្តីណែនាំមួយឲ្យខាងខ្ញុំហ្នឹង ធ្វើជាទូរលេខដែរ ជាការណែនាំអំពីវិធីដំណោះស្រាយស្បៀងក្នុង ពេលដែលយើងជួប ក្នុងពេលដែលមូលដ្ឋានគេជួបនូវគ្រោះធម្មជាតិ បាទ អានេះមានម្តងដែរ ហើយក៏ លោកស៊ីញ៉េដាក់ "នួន" ពីក្រោមអ៊ីចឹងដែរបាទ។ បាទ មានៗតែប៉ុណ្ណឹងទេបាទដែលខ្ញុំឃើញ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់ពិភាក្សាចំណុចនេះបន្តិចឲ្យខ្ញុំយល់ យើងឃើញថា នៅ ពេលនោះមានទឹកជំនន់នៅមូលដ្ឋាន ហើយថ្នាក់ដឹកនាំនោះចង់ដោះស្រាយបញ្ហាលិចទឹកនោះ នៅពេល នោះគឺ នួន ជា នោះបានចុះហត្ថលេខានៅលើឯកសារមួយពាក់ព័ន្ធទៅនឹងបញ្ហាទឹកជំនន់នោះ ការដោះ ស្រាយទៅលើទឹកជំនន់នោះ។ តើលោកនិយាយអ៊ីចឹងត្រូវដែរឬទេ?

[០៩:៣៨:៤១]

**ឆ៖** មិនមែនដោះស្រាយរឿងទឹកជំនន់ទេ។ ទឹកជំនន់បានធ្វើឲ្យខូចខាតផលដំណាំរបស់ប្រជាជន របស់មូលដ្ឋានហ្នឹង មូលដ្ឋានណាខ្ញុំមិនចាំ។ អ៊ីចឹងលោកជូនជាវិធីសាស្ត្រដើម្បីឲ្យប្រជាជនយើងរស់មាន បាយហូប មានដំណាំស្បៀងរួមផ្សំ អ៊ីចឹងលោកបានបំផុសឲ្យប្រជាជនហ្នឹង ឲ្យកម្មាភិបាលហ្នឹងចុះ ជាប់ជាមួយប្រជាជនក្នុងការខិតខំបង្កបង្កើនផលដំណាំស្បៀងរួមផ្សំ មានតាំងពី ពោត សណ្តែកអី។ល។ ណ៎ះ! អ៊ីចឹងបាទ ច្រើនណាស់ ហូរហែដើម្បីឲ្យប្រជាជនហ្នឹងបានហូបកុំឲ្យដាច់ពោះបាទ ហើយ ហត្ថលេខារបស់លោកគឺ "នួន" បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមចូលទៅដល់ចំណុចបន្ទាប់ទៀត ដែលខ្ញុំចង់លើកឡើង អំពីការប្រាស្រ័យទាក់ទងបញ្ជូនសារទៅកាន់ នួន ជា អ្វីដែលលោកប្រាប់កាលពីថ្ងៃអង្គារទៅមេធាវីដើម បណ្តឹងរដ្ឋប្បវេណីក្នុងនាមលោកជាអ្នកបកប្រែសារទូរលេខនោះ គឺលោកបានបញ្ជាក់ថា លោកបាន ឃើញសារទូរលេខតែមួយតែប៉ុណ្ណោះ ដែលលើកឡើងអំពីបញ្ហាខុសសីលធម៌ គឺសារទូរលេខ៥៤ ដែល លោកឃើញតែម្តងគត់ ពាក់ព័ន្ធទៅនឹងបញ្ហាការខុសសីលធម៌។ ត្រឹមត្រូវដែរឬទេ ដែលលោកឃើញ សារទូរលេខលើកឡើងអំពីការខុសសីលធម៌តែម្តងគត់ គឺសារទូរលេខលេខ៥៤?

**ឆ៖** បាទ ខាងតំបន់ ខាងលោក សារុន ហ្នឹង បានរាយការណ៍តែរឿងហ្នឹងមួយគត់ដែរ។ ឯក្រៅ ពីហ្នឹងសារកន្លែងផ្សេងៗដូចជាមិនឃើញមានរាយការណ៍រឿងអ៊ីចឹងទេបាទ។

**ស៖** សូមអរគុណលោកច្រើន។ នៅពេលនេះ យើងខ្ញុំសូមមើលចម្លើយលោកមួយ ដែលបាន លោកឆ្លើយជូនអ្នកស៊ើបអង្កេត គឺខ្ញុំលើកឡើងឯកសារ E3/67 គឺកំណត់ហេតុស្តាប់ចម្លើយដែលលោក

បានឆ្លើយជូនអ្នកស៊ើបអង្កេតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩។ យើងបានពិភាក្សាឯកសារនេះប៉ុន្មានថ្ងៃរួចមកហើយ តើលោកចាំដែរឬទេ ឯកសារកំណត់ហេតុស្តាប់ចម្លើយមួយ ដែលថាជាការស្តាប់ចម្លើយលើកទី២ លោកបានឆ្លើយជូនអ្នកស៊ើបអង្កេតរបស់តុលាការនេះ។ តើលោកចាំទេ ថាទៅលើចម្លើយដែលលោកបានឆ្លើយនោះ?

[០៩:៤២:០១]

**ធ៖** បាទ មិនចាំទេ។

**ស៖** ដូច្នេះខ្ញុំសូមឲ្យលោកចាំឡើងវិញ ខ្ញុំនឹងអានចំណុចមួយចំនួនដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុនេះ គឺឯកសារលេខ E3/67 កំណត់ហេតុរបស់អ្នកស៊ើបអង្កេតថ្ងៃទី២០ មីនា ២០០៩ ERN ជាភាសាអង់គ្លេសគឺ 00483970 ទំព័រលេខ៨ ជាភាសាអង់គ្លេស, ខ្មែរគឺ 00294542, បារាំងគឺ 00374937 រហូតទៅដល់ 38។ ខ្ញុំសូមអានចំណុចនេះ ដែលលោក -- នេះជាចម្លើយរបស់លោកឆ្លើយជូនសំណួរអ្នកស៊ើបអង្កេតមួយរូប "ខ្ញុំមិនដឹងកន្លែងនីមួយៗ គេរាយការណ៍សមហេតុសមផលតាមភាពជាក់ស្តែង ឬយ៉ាងម៉េច។ ខ្ញុំមិនដឹងដែរ ពីព្រោះដូចទូរលេខខ្លះ គេរាយការណ៍ថា ជីវភាពប្រជាជនធូរធារហើយ តែជាក់ស្តែងមិនដឹងថាប្រជាជនហូបបបរក៏មិនដឹង។ ខ្ញុំមិនដឹងដែរ។ ខ្ញុំឮមិត្តភក្តិរបស់ខ្ញុំនិយាយជួនកាលគេបានទៅលេងផ្ទះទៅ គេត្រឡប់មកវិញ គេថា មានការសោកស្តាយណាស់ ដោយគេឃើញថានៅមូលដ្ឋានក្រខ្វះខាត ឪពុកម្តាយគេហូបមិនគ្រប់គ្រាន់ តែស្តាប់តាមវិទ្យុអី គេផ្សាយថាប្រទេសយើងសម្បូរសប្បាយណាស់ មហាលោកផ្លោះ មហាអស្ចារ្យ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គេតែងតែផ្សាយ ខ្ញុំបានស្តាប់ផងដែរ។ ពេលកំពុងធ្វើការសប្បាយណាស់ ឮថាប្រជាជនមានជីវភាពធូរធារមានប្រឡាយខ្វាត់ខ្វែង ប៉ុន្តែធាតុពិតខុសពីអ្វីដែលវិទ្យុបានផ្សព្វផ្សាយ។ ជួនកាលចង់បានមុខមាត់ខ្លួនឯងចេះតែរាយការណ៍ថាល្អណាស់ៗ តែកន្លែងខ្លះក៏មានការរាយការណ៍ពិតប្រាកដដែរ"។

[០៩:៤៤:១៦]

តើលោកចាំទេថាលោកបានឆ្លើយដូច្នេះប្រាប់អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនោះ?

**ធ៖** បាទ ខ្ញុំបានឆ្លើយអ៊ីចឹងមែន។

**ស៖** សូមអរគុណ។ ខ្ញុំសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងចំណុចនេះ។ ចំពោះខ្ញុំ នៅពេលដែលខ្ញុំអានចំណុចនេះ គឺលោកនៅធ្វើការនៅកន្លែងបកប្រែសារទូរលេខហ្នឹង នៅពេលដែលខ្ញុំអានចំណុចនេះទៅ គឺលោកមិនបានដឹងពិតប្រាកដជាក់ស្តែងថាមានអ្វីកើតឡើងនៅមូលដ្ឋាននោះទេ។ អ្វីដែលលោកដឹង

នោះគឺគ្រាន់តែលោកលើកឡើងថា របាយការណ៍មកពីមូលដ្ឋាននោះ គឺមិនត្រឹមត្រូវនោះទេ មិនលើកឡើងឲ្យបានបញ្ជាក់ឲ្យបានត្រឹមត្រូវនោះទេ។ តើចំណុចនេះ ត្រឹមត្រូវដែរឬទេ ខ្ញុំយល់ដូច្នេះនោះ?

**ឆ៖** បាទ របាយការណ៍ទាំងអស់ ខ្ញុំដូចប្រាប់លោកហើយ ថាខ្ញុំមិនដឹងអ្វីដែលកើតឡើងនៅមូលដ្ឋានពិត ឬមិនពិតនោះទេ។ ប៉ុន្តែអ្វីដែលជាព័ត៌មានត្រឡប់ គឺខ្ញុំបានទៅសាកសួរមិត្តភក្តិខ្ញុំដែលគេមកពីលេងផ្ទះ លេងអីហ្នឹង ឃើញថានៅតាមសហករណ៍ខ្លះ ដែលមានអ្នកដឹកនាំល្អ ក៏គេបានប្រជាជនហ្នឹងជីវភាពហូបឆ្អែតអីអ៊ីចឹងទៅ ប៉ុន្តែសហករណ៍ខ្លះដែលអ្នកដឹកនាំហ្នឹង ឆ្វេង ប្រជាជននៅតែហូបបបរអ៊ីចឹង។ នេះគឺជាការពិតដែលផ្ទុះបញ្ហាំងនៅសម័យនោះបាទ។

[០៩:៤៦:២៥]

**ស៖** សូមអរគុណលោកសាក្សី។ មានសំណួរមួយទៀតដែលខ្ញុំចង់សួរទៅលើចំណុចនេះ ខ្ញុំសូមលើកឡើងវិញអ្វីដែលលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេត៖ "ជួនកាលចង់បានមុខមាត់ខ្លួនឯង គេចេះតែរាយការណ៍ថា ល្អណាស់ៗ"។ តើលោកអាចពន្យល់ទេ ថាលោកចង់បានន័យយ៉ាងម៉េចដែរ នៅពេលដែលលោកឆ្លើយដូច្នោះ ដែលលោកលោកលើកឡើងថា "ជួនកាលចង់បានមុខមាត់ខ្លួនឯង" តើលោកមានន័យយ៉ាងម៉េចដែរ?

**ឆ៖** បាទ មានន័យថា មនុស្សយើង វាមានការចង់បានមុខមាត់ ចង់បានសក្តិ វាមិនចេះចប់ទេ។ បានធ្វើគណៈតំបន់ហើយ ចង់ធ្វើគណៈភូមិភាគ បានធ្វើគណៈភូមិភាគហើយ ចង់ធ្វើមជ្ឈិម បានមជ្ឈិមហើយ ចង់បានអចិន្ត្រៃយ៍អីៗរហូត ចង់ធ្វើស្តេចអីមិនបានដែរ អ្នកខ្លះនោះ។ នេះជាការលោភលន់អំណាច អានេះវាមានជាក់ស្តែងនៅក្នុងប្រភេទមនុស្សមួយចំនួន។ ដូច្នេះ គឺអានេះគឺ មិនមែនជាការពិតដែលថាអ៊ីចឹងមែនទេ គឺជាកាលវិភាគ។ អ៊ីចឹងហើយបានជាខ្ញុំឃើញសារខ្លះ កន្លែងខ្លះ គេរាយការណ៍ថាមកមួយហិកតាបីបួនតោន ប្រាំតោន រហូតមានកន្លែងខ្លះ មានដល់មួយហិកតាដប់តោនឯណោះ។ ចុះបើបានផលច្រើនម្ល៉េះៗ ចុះហេតុអ្វីបានជាប្រជាជនយើងនៅហូបបបរអ៊ីចឹង។ អានេះ ជាចំណោទឲ្យខ្ញុំនៅក្នុងសម័យនោះ។ ខ្ញុំគិតខ្លួនឯងទេ។ ហើយដល់ខ្ញុំឃើញសំណួររបស់អស់លោកអ៊ីចឹងទៅ ខ្ញុំជាការវិភាគឲ្យខ្ញុំថា ប្រហែលជាមានមនុស្សខ្លះហ្នឹង ចង់បានមុខ ចង់បានមាត់ បានជារាយការណ៍ក្នុងសារទូរលេខហ្នឹង វាបានសម្បូរសប្បាយ ការរីកចម្រើន តែផ្ទុយទៅវិញ មានរីកចម្រើនឯណា គឺថាសូម្បីតែការស្លៀកពាក់ ការហូបចុកមិនគ្រប់គ្រាន់ផង។

[០៩:៤៨:៥៨]

ហើយខ្ញុំឃើញសារទូរលេខខ្លះ ដែលខ្ញុំបកហ្នឹង គឺជួនកាលអង្គការបញ្ជូនសម្ភារៈទៅជាអង្ករជាក្រណាត់អីច្រើនណាស់។ លោក ខៀវ សំផន ហ្នឹងចាត់ទៅក្នុង១ខែៗមិនដឹងប៉ុន្មានដងទេ។ តែប្រជាជនទាំងអស់នោះ មិនបានទទួលការស្លៀកពាក់ដោយសមរម្យ ហើយឧបមា ដូចបញ្ជូនម៉ាស៊ីនដេរហ្នឹងទៅ វាយកត្រល់ហ្នឹងចោលអស់រលីង ដូច្នេះដេរវាមិនកើត អាហ្នឹង។ នេះជា ទាំងអស់នោះជាអ្វីដែលជាបញ្ជាំងឲ្យឃើញនូវជីវភាពប្រជាជនផង នូវបញ្ជាំងឲ្យឃើញនូវអាកប្បកិរិយារបស់អស់លោកនៅតាមមូលដ្ឋានហ្នឹងផង។ បាទ សូមមានយោបល់ប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណច្រើនលោកសាក្សី។ ប្រសិនបើខ្ញុំចូលសួរសំណួរមួយទៀត គឺនៅលើឯកសារនេះដដែល ឯកសារ E3/67 កំណត់ហេតុថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៩។ អង់គ្លេស ERN 00483974 ទំព័រ១២ ជាភាសាអង់គ្លេស, ខ្មែរគឺ 00294546, បារាំងគឺ 00374941។ ខ្ញុំនឹងដកស្រង់សម្ដីដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេត "ពាក់ព័ន្ធទៅនឹងការដាក់ទណ្ឌកម្មនោះ អង្គការគេមិនឲ្យធ្វើអ្វីចំពោះប្រជាជននោះទេ។ ក៏ប៉ុន្តែពេលខ្លះទៅយើងមិនបាន -- ពេលខ្លះមិនត្រូវចំគោលដៅនោះទេ ពេលខ្លះក៏មិនចំគោលដៅដូចដែលយើងបានកំណត់នោះដែរ ជួនកាលវាវាលដាល"។ ដូច្នេះ ខ្ញុំចង់សួរលោកថាពេលខ្លះទៅប្រជាជនគាត់ទទួលរងនូវការធ្វើបាប ដោយសារតែវាមានការខូចរបស់របរ ដោយសារតែការបាញ់កាំភ្លើងធំរបស់យោធា តើអីចឹងដែរឬទេ?

[០៩:៥១:៣៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានជាទីគោរព! យើងខ្ញុំជំទាស់ទៅនឹងការសួរសំណួរនេះ។ លើកលែងតែមេធាវីបានផ្ដល់មូលដ្ឋានក្នុងការសួរសំណួរ ទើបយើងមិនជំទាស់។ ដូច្នេះ យើងគ្រាន់តែចង់ធ្វើយ៉ាងណាទាញយកការដឹងដោយផ្ទាល់របស់សាក្សីតែប៉ុណ្ណោះ។ សាក្សីតាមខ្ញុំចាំ គឺគាត់បញ្ជាក់ថា គាត់មិនបានចុះទៅតាមមូលដ្ឋាន ហើយគាត់ក៏មិនដែលឃើញមានការបាញ់កាំភ្លើងធំផងដែរ។ ដូច្នេះហើយខ្ញុំ -- កែខ្ញុំប្រសិនបើខ្ញុំនិយាយខុស ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសូមឲ្យមេធាវីការពារក្ដីនោះបង្ហាញមូលដ្ឋានលើចំណុចនេះមុនសួរសំណួរ។ ថាតើសាក្សីគាត់បានដឹងជាក់ស្ដែងពិតប្រាកដ ទៅលើហេតុការណ៍នេះដែរឬទេ ទើបគាត់អាចសួរបាន។

[០៩:៥២:២៧]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំឯកភាពទៅលើចំណុចនេះ ខ្ញុំអធ្យាស្រ័យដែលខ្ញុំមិនបានផ្តល់មូលដ្ឋាន។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរលោកម្តងទៀត។ ខ្ញុំសូមអានសាជាថ្មី តាមចម្លើយដែលលោកបានឆ្លើយ “ពេលដែលបាញ់កាំភ្លើងធំទៅ ពេលខ្លះត្រូវចំគោលដៅ ហើយពេលខ្លះទៀតក៏មិនចំគោលដៅដូចដែលយើងបានកំណត់នោះទេ ជួនកាលវារាលដាល។ វាគេចមិនផុតពីការធ្វើឲ្យស្លាប់ និងរបួស”។ សំណួរដែលខ្ញុំសួរលោកគួរតែ តើលោកដឹងអ្វីខ្លះ? តើលោកមានមូលដ្ឋានអ្វីខ្លះដែលលោកដឹងទៅលើចំណុចនេះ? តើលោកដឹងដោយផ្អែកលើអ្វី ដែលថាអ្វីដែលខ្ញុំបានអានអម្បាញ់មិញនេះ?

[០៩:៥៣:១០]

**លោក នង សុផង់៖**

**ឆ៖** បាទ រឿងនេះ ខ្ញុំបានបញ្ជាក់ជូនអង្គសវនាការអស់ហើយ ថាខ្ញុំមិនដឹងការពិតនៅមូលដ្ឋាននោះ ហើយក៏មិនដឹងការពិតដែលគេបាញ់កាំភ្លើងសម្លាប់ប្រជាជននោះទេ។ អ៊ីចឹងអ្វីដែលខ្ញុំឆ្លើយថាខ្ញុំមិនដឹង គឺវាកុំយកជាការបានអី អាធ្វើការអធិប្បាយខាងក្រោយបន្តៗអីហ្នូវហែហ្នឹង គឺសូមលុបចេញទាំងអស់ទៅ។ ជាការស្រេចហើយ។ ទុកជាមោឃៈ ពីព្រោះមិនមែនជាការពិតបាទ។

**ស៖** សូមអរគុណលោកសាក្សី។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំគ្រាន់តែជូនដំណឹងទៅដល់ភាគី និងអស់លោកទាំងអស់ថា ខ្ញុំមានតែបីសំណួរទៀតប៉ុណ្ណោះបន្ទាប់មក ខ្ញុំនឹងបញ្ចប់ការតាំងសំណួររបស់ខ្ញុំ។

[០៩:៥៤:១៨]

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សី កាលពីថ្ងៃមុនលោកបានលើកឡើងថាលោករីករាយ លោកសប្បាយនឹងមកចូលរួមនៅក្នុងតុលាការនេះ ដើម្បីផ្តល់សក្ខីកម្មអំពីអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះទៅ តើលោកយល់យ៉ាងម៉េចដែរគឺថា នៅពេលដែលលោកនិយាយថាអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្មនេះ តើលោកសំដៅទៅលើអ្នកណាដែរ ដែលក្នុងចិត្តរបស់លោកនោះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមជំ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់សំណួរនេះ គឺមិនពាក់ព័ន្ធទៅលើការសួរថា តើអ្នកណាគេជាអ្នកប្រព្រឹត្តទៅលើឧក្រិដ្ឋកម្មនោះ? ហើយយើងក៏មិនដឹងថា មានភស្តុតាងអ្វី ដែលបញ្ជាក់ទៅលើចំណុចនេះផងដែរ។ វាជាការសន្មតនោះតែប៉ុណ្ណោះ។ វាជាការជំនុំជម្រះរបស់យើងនៅទីនេះ។

**លោក អេនគ្រូ អ៊ីនូហ្សី៖**

ខ្ញុំសូមឆ្លើយតបដោយខ្លី។ គឺនៅពេលដែលសាក្សី គាត់ដឹងថាដោយផ្ទាល់នេះហើយ ទើបគាត់ដឹងថាឧក្រិដ្ឋកម្មមួយចំនួននោះគឺ បានប្រព្រឹត្តនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ឬក៏អាចមុនសម័យកម្ពុជាប្រជាធិបតេយ្យ ដោយរដ្ឋបរទេស។ ដូច្នេះហើយជាចំណុចមួយហើយ ដែលខ្ញុំចង់សួរជជីក និងពិភាក្សា។ ដូច្នេះ ខ្ញុំសូមរៀបចំសំណួររបស់ខ្ញុំឡើងវិញ ដើម្បីឲ្យខ្ញុំអាចបង្កើតមូលដ្ឋាន នៃការដឹងដោយផ្ទាល់របស់សាក្សី បន្ទាប់មកខ្ញុំនឹងសួរទៅដល់ចំណុចនេះ។

[០៩:៥៥:៥៣]

**សួរដោយលោក អេនគ្រូ អ៊ីនូហ្សី៖**

**ស៖** លោកសាក្សី លោកបានលើកឡើងនៅក្នុងពេលមុន ហើយសូមឲ្យលោកពន្យល់ជូនយើងខ្ញុំនូវអ្វីដែលលោកបានឆ្លើយនោះ ដើម្បីឲ្យយើងអាចសួរបញ្ជាក់ទៅលើចម្លើយ ដែលលោកបានឆ្លើយ។ តើលោកបានដឹងដោយផ្ទាល់ ដឹងពិតប្រាកដដែរឬទេ ដែលថាមានឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តដោយរដ្ឋបរទេសនៅក្នុងប្រទេសនេះ មិនថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏មុនរបបកម្ពុជាប្រជាធិបតេយ្យនោះទេ តើលោកបានដឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

[០៩:៥៦:២៦]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៦:៤៣]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ! ពីព្រោះសំណួរនេះមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទប្រកាន់ទៅលើជនជាប់ចោទ ដែលយើងកំពុងតែធ្វើសវនាការនេះទេ។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបន្តសំណួរបន្ទាប់របស់ខ្ញុំ។

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ គឺលោកបាននិយាយអំពីមន្ទីរដែលមានអក្សរ “ក” ក-១, ក-១៨ គឺលោកបានដាក់មន្ទីរ“ក” នៅក្នុងតារាង ដែលលោកគូសឲ្យអ្នកស៊ើបអង្កេត។ ពាក់ព័ន្ធទៅនឹងមន្ទីរ “ក” នេះ ខ្ញុំចង់ដឹងក្នុងនាមលោកជា ប្រជាជនមួយរូបនោះ ថាតើផែនការ “ក-៥” នោះ តើវាយ៉ាងម៉េចដែរ ក្រោយពីសម័យកម្ពុជាប្រជាធិបតេយ្យ? តើលោកស្គាល់ផែនការ “ក-៥” ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតប អ់! កុំអាលឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៥៧:៥៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងខ្ញុំជំទាស់ដដែលផ្អែកតាមមូលដ្ឋាន ដែលយើងខ្ញុំលើកពីមុន ចំពោះការតាំងសំណួររបស់មេធាវីការពារក្តី។ ហេតុការណ៍នេះកើតក្រោយកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ លើកលែងតែវាមានការជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងភស្តុតាង ទើបយើងគិតថា វាពាក់ព័ន្ធ។ ហើយចំណុចនេះមិនគួរសួរជជីកនោះទេ។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

ដូចដែលខ្ញុំបញ្ជាក់ជាច្រើនដងហើយ ក្នុងបន្ទប់សវនាការនេះ។ បញ្ហាថាតើការស្លាប់នោះនៅក្នុងទំហំធំធេងក្នុងឆ្នាំ១៩៧៨ ឬក៏យ៉ាងណានោះ គឺពេលខ្លះទៅវាអាចមានការពាក់ព័ន្ធ ឬមិនពាក់ព័ន្ធទៅនឹងខ្មែរក្រហម។ ដូច្នេះហើយអ្វីដែលខ្ញុំចង់ដឹងនោះ គឺថាសំណួរដែលខ្ញុំសួរនេះ គឺវាពាក់ព័ន្ធដែលខ្ញុំគួរតែមាន

សិទ្ធិសួរ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា មានមូលដ្ឋានត្រឹមត្រូវ។ សំណួរនេះមិនពាក់ព័ន្ធនឹងអង្គហេតុ ដែលបាន និងងកំពុងតែធ្វើសវនាការដេញដោល ដែលចោទប្រកាន់ទៅលើជនជាប់ចោទនោះទេ។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរបែបនេះទេ!

[០៩:៥៩:២២]

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរតែមួយទៀត តែប៉ុណ្ណោះ។

**សួរដោយលោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

**ស៖** លោកសាក្សី សូមអរគុណដែលលោកអត់ធ្មត់ ចំពោះការតាំងសំណួររបស់ខ្ញុំ។ ពាក់ព័ន្ធទៅនឹងលោក ដែលមានការងាររក្សាការសម្ងាត់ផងដែរ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ សូមឲ្យលោកជួយពន្យល់អង្គជំនុំជម្រះផង ថាតើ -- សូមលោកជួយពន្យល់ទៅលើឃ្លា ដែលខ្ញុំបានពិនិត្យមើលជាយូរមកហើយ។ ឃ្លានេះគឺគេថា មានលេខកូដសម្ងាត់ ដែលថា លេខកូដសម្ងាត់ ដែលលោកធ្វើការងារនោះគឺវាមានលក្ខណៈសំខាន់ណាស់ ចំពោះប្រជាជនអ្នកដែលធ្វើការនៅសម័យនោះ។ គឺឃ្លានោះគឺថា "ឆ្កែព្រុស ឡានបើកទៅមុខ"។ ដូច្នេះចំពោះថា ឃ្លានេះ គឺវាអាចពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់លោក ដែលថា តើវាមានន័យយ៉ាងម៉េចទៅលើឃ្លា ដែលប្រើប្រាស់ដោយរដ្ឋមន្ត្រី ខៀវ កាញារីទ្ធ? មានពាក្យមួយចំនួនដែលគាត់ប្រើប្រាស់។ ដូច្នេះ តើវាមានន័យយ៉ាងម៉េចដែរ?

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

ខ្ញុំឃើញថា តំណាងសហព្រះរាជអាជ្ញា ក្រោកឈរជំទាស់។

**លោក អាប់ឌុលឡាក់ ថារីក៖**

(គ្មានការបកប្រែ)

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:០០:៥៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់សំណួរចុងក្រោយនេះ គឺវាបន្តខាតបង់ពេលវេលារបស់យើង។ យើងមិនអាចផ្ដល់យោបល់ទៅលើអ្វីដែលគេនិយាយនោះទេ។ ជាពិសេស គឺយើងមិនអាចងាកចេញពីបរិបទនៃកម្ពុជាប្រជាធិបតេយ្យទេ។ អ្វីដែលងាកចេញនេះ គឺវាមិនពាក់ព័ន្ធនោះទេ។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សម្រាប់ប្រតិចារឹក គឺថាការលើកឡើងជាសាធារណៈនោះ គឺវាមានលក្ខណៈជាក់លាក់។ ដូច្នេះហើយវាអាចជាការព្យាយាមមួយធ្វើការឲ្យប៉ះពាល់ទៅដល់ដំណើរការនេះ។ ដូច្នេះហើយ វាពាក់ព័ន្ធ។ ខ្ញុំមិនចំណាយពេលច្រើននោះទេ។

នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ដែលខ្ញុំលើកឡើងអម្បាញ់មិញ សម្ដីថា“ឆ្កែចេះតែព្រុស មនុស្សចេះតែដើរនោះ”។ សូមអរគុណលោកសាក្សី ដែលលោកបានមកចូលរួមផ្ដល់សក្ខីកម្ម។

[១០:០១:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ សំអាងហេតុនៃសេចក្ដីជំទាស់ត្រឹមត្រូវ។ សេចក្ដីជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា អម្បាញ់មិញនេះទេ។

ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅ ក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់ សាធារណជនទាំងក្នុង ទាំងក្រៅបន្ទប់សវនាការ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ៃខល កាណាវាស រួមទាំងលោក អាង ឧត្ដម ដែលជាសហមេធាវីការពារលោក អៀង សារី។ ខ្ញុំចង់ចូលទៅពេលវេលាមួយ ទៅកាន់ពេលវេលាមួយដែលលោកបានផ្ដល់ចម្លើយជាលើកដំបូង គឺឯកសារដែលខ្ញុំយោងនោះគឺ ឯកសារដែលបានយោងកាលពីម្សិលមិញ ដើម្បីជាប្រតិចារឹក គឺ E3/64 នៅទំព័រដំបូងបំផុតនៃកំណត់ហេតុស្ដាប់ចម្លើយនេះ គឺចាប់

ផ្តើមនៅថ្ងៃទី១៨ កុម្ភៈ ២០០៩ ដែលមានអ្នកស៊ើបអង្កេតជាជនជាតិកម្ពុជា និងក្នុងនោះមានវត្តមានអ្នកស៊ើបអង្កេតជាជនជាតិបរទេសផងដែរ។ លោកនៅចាំថា លោកបានផ្តល់ចម្លើយដល់អ្នកស៊ើបអង្កេតទាំងពីរនេះទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំចាំបាន។

[១០:០៣:៤៩]

**ស៖** ប្រសិនយើងចូលទំព័រទី២ ដែលមាន ERN ជាភាសាខ្មែរ 00328022 ទៅដល់ ២៣, ERN ជាភាសាបារាំង 00411693, ERN អង់គ្លេស 00334043។ នៅត្រង់នេះ យើងឃើញមានប្រអប់មួយចំនួន នៅក្នុងប្រអប់មួយចំនួននេះ ដែលថាលោកត្រូវបានផ្តល់យោបល់មកឲ្យលោក ដោយមានការថតសំឡេងមុនការសម្ភាសលោក។ តើលោកមានចាំទេថាគេបានផ្តល់យោបល់ទៅឲ្យលោកថា សុំឲ្យលោកហ្នឹងផ្តល់បទសម្ភាសន៍ហ្នឹង ថតសំឡេងជាមុនសិន មុននឹងសម្ភាសលោកជាសំណេរនោះ?

**ឆ៖** បាទ ប្រអប់នេះ គេបានដាក់ថា “យើងបានជូនព័ត៌មានរួចហើយ ដល់ជននេះថា ការស្តាប់ចម្លើយនេះ នឹងត្រូវថតយកសំឡេង ឬរូបភាព”។ បាទ គេបានជូនព័ត៌មានអ៊ីចឹងមែន ប៉ុន្តែគេមិនមែនថតយករូបភាព ថតសំឡេងមុនទេ គឺថា ពេលដែលយើងផ្តល់សម្ភាស គេក៏ថតសំឡេងតែម្តងបាទ។ នេះគេជូនព័ត៌មានមុនអ៊ីចឹងដែរបាទ។

**ស៖** ដូច្នេះយើងឃើញថា ការសម្ភាសចាប់ផ្តើមនៅម៉ោងប្រាំបួនព្រឹក ហើយក្រោយមកក៏មានចាក់ខ្សែអាត់សំឡេង ដើម្បីបញ្ជាក់ថា តើការសម្ភាសចាប់ផ្តើមនៅពេលណា។ ខ្ញុំនឹងចោទសំណួរមួយចំនួនទៅនឹងបញ្ហានេះ។ នៅក្នុងប្រអប់នេះ យើងក៏ឃើញថា គេបានប្រាប់លោកអំពីសិទ្ធិរបស់លោក ហើយអ្នកស៊ើបអង្កេតក៏បានជម្រាបទៅលោក គឺនៅក្នុងប្រអប់មួយថា លោកបានធ្វើសម្បថហើយ លោកបានស្បថហើយ មុននឹងលោកឆ្លើយទៅនឹងបណ្តាសំណួរទាំងឡាយនោះ តើលោកចាំថា លោកបានស្បថទេ?

[១០:០៦:៣៩]

**ឆ៖** បាទ ខ្ញុំចាំថា ខ្ញុំបានស្បថមែន។

**ស៖** ហើយនៅពេលគេជម្រាបទៅលោកអំពីសិទ្ធិរបស់លោក តើគេបានប្រាប់លោកអំពីសិទ្ធិមុននឹងថតខ្សែអាត់សំឡេង ឬក៏លោកនិយាយ ឬក៏ថា ការប្រាប់ហ្នឹង គឺថាចាប់ផ្តើមនៅមុនការថត

សំឡេងនោះ?

**ឆ៖** បាទ គេបានប្រាប់ថា ឲ្យខ្ញុំហ្នឹងមិនផ្តល់សក្ខីកម្មអ្វីដែលប្រឆាំងនឹងខ្លួនឯងបាទ។

**ស៖** សូមអរគុណច្រើន។ បញ្ហាបច្ចេកទេសមួយ គឺនៅក្នុងប្រអប់មួយនេះ បើសិនណាជាលោកចេះភាសាបរទេស? ថាឥឡូវលោកមានចេះភាសាបរទេសដែរឬទេ? លោកប្រកាសថា លោកមិនចេះអាន មិនចេះសរសេរភាសាបរទេសទេ។

**ឆ៖** បាទ ការចេះតិចតួច មិនអាចយកជាការបាន។ អ៊ីចឹងខ្ញុំថាមិនចេះតែម្តងទៅ។ អត់ឮអ៊ីចឹង?

**ស៖** បាទ អរគុណហើយ។ ដូច្នេះនៅពេលសម្ភាសក្រោយមកទៀត លោកបានបញ្ជាក់ថា នៅពេលលោកចាប់ផ្តើមបង្រៀនក្មេងៗ គឺលោកបង្រៀនជាភាសាបារាំង និងជាភាសាអង់គ្លេស គឺថាលោកមានកម្រិតភាសាមានកម្រិត ដែលយ៉ាងហោចណាស់គឺថាលោកបានបង្រៀនជាភាសាអង់គ្លេស ជាភាសាបារាំង និងអង់គ្លេសដែរ ទុកណាជាចំណេះដឹងខាងផ្នែកភាសានេះមិនគ្រប់គ្រាន់ក៏ដោយ។ អ៊ីចឹងមែនទេ?

[១០:០៨:៤៥]

**ឆ៖** បាទ មិនមែនបង្រៀននិយាយជាភាសាបារាំង និងអង់គ្លេសទេ គឺថាបង្រៀនឲ្យគេមានចំណេះដឹងមូលដ្ឋានពីអក្សរឡាតាំង។ ឧបមាថា អាណាជា*បេ* អាណាជា*អា* ហើយអង់គ្លេសថា *អា*ហ្នឹងគេហៅ *អេ* អីអ៊ីចឹងទៅណា។ តិចៗទេ មិនមានអីប្រើប្រាស់ភាសាបារាំង ភាសាអង់គ្លេស ដើម្បីបង្រៀនគេនោះទេបាទ។

**ស៖** សូមអរគុណច្រើនលោកសាក្សី។ បើយើង -- ហើយសូមចូលទៅមើលទំព័រចុងក្រោយនៃឯកសារដដែលនេះ យើងឃើញ គឺថាឯកសារមួយច្បាប់ជាសំណេរនេះបានប្រគល់ជូនលោកដែលជាសាក្សី។ ហើយឯកសារនេះគឺថាបានអានឲ្យលោកស្តាប់ ហើយលោកគឺថាមិនជំទាស់ទៅនឹងឯកសារនេះទេ ហើយលោកក៏ព្រមចុះហត្ថលេខាលើឯកសារនេះផងដែរ។ លោកចាំទេ?

**ឆ៖** បាទ ខ្ញុំបានចងចាំថាគេបានអានឲ្យខ្ញុំស្តាប់អ៊ីចឹងមែន ហើយខ្ញុំក៏បានអានអី បានស្តាប់ទៅគឺថា មិនមានអ្វីដែលខុសពីពាក្យពេចន៍ដែលខ្ញុំបាននិយាយនោះទេ ទើបខ្ញុំចុះហត្ថលេខាបាទ។

**ស៖** ហើយយើងឃើញកាលបរិច្ឆេទគឺថ្ងៃទី២៧ មីនា ២០០៩ ប្រហែលជា ៥សប្តាហ៍ក្រោយពីការផ្តល់ចម្លើយនេះ ហើយមួយថ្ងៃមុននឹងលោកផ្តល់ចម្លើយជាលើកទី២ តើអ៊ីចឹងទេ?

**ផ:** បាទ អ៊ីចឹងខ្ញុំមិនបានឃើញអាចាប់ផ្តើមពេលណា? ដែលចាប់ផ្តើម?

**ប្រធានអង្គជំនុំ៖**

លោកៗមេធាវី ម៉ៃខល កាណាវាស អាចពន្យល់យើងបានទេ ថាតើសំណួរដែលលោកសួរប៉ុន្មាននេះវាមានការពាក់ព័ន្ធនឹងអង្គហេតុ ដែលចោទប្រកាន់លើជនជាប់ចោទហ្នឹងយ៉ាងម៉េចខ្លះទៅ?

[១០:១១:៤៥]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានសាក្សីបានផ្តល់សក្ខីកម្ម គាត់បានផ្តល់ចម្លើយដែលគេយកមកសំអាងនេះ ហើយអង្កាល់ពីពេលមុននោះ។ កាលដែលខ្ញុំលើកបញ្ហានេះឡើង លើកនូវកំណត់ហេតុស្តាប់ចម្លើយនេះឡើង គឺយើង -- គឺគេបានប្រាប់ឲ្យយើងខ្ញុំ គឺថាគួរតែលើកនូវបញ្ហានេះឡើងដោយសារបញ្ហានេះវាពាក់ព័ន្ធនឹងរឿងក្តីនេះតែម្តង។ បើសិនជាលោកប្រធានផ្តល់ពេលវេលាឲ្យខ្ញុំ ៥នាទី គឺខ្ញុំនឹងពន្យល់ថា ហេតុអ្វីបានលើកបញ្ហានេះឡើង។ ខ្ញុំគ្រាន់ -- ពេលនេះខ្ញុំចង់សួរទៅសាក្សីថាតើគាត់ទទួលស្គាល់ទេ គឺគាត់បានផ្តល់ចុះហត្ថលេខា ៥សប្តាហ៍ក្រោយពីការសម្ភាសលើកទី១--

**ប្រធានអង្គជំនុំ៖**

យើងសួរលោកវិញ ថាតើអំឡុងពេលដំណើរការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតហ្នឹងលោកដែលបានមើលឯកសារអស់ហ្នឹងដែរឬទេ? នេះជាសំណួររបស់យើង។

[១០:១២:៤៣]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន លោកសួរខ្ញុំថា តើខ្ញុំបានអានឯកសារនេះទេ? បាទ ខ្ញុំបានអានលោកប្រធាន គឺថាមានកំណត់ហេតុស្តាប់ចម្លើយនេះរៀបពាន់ឯណោះ។ ប៉ុន្តែខ្ញុំពេលវេលាដែលត្រូវពិនិត្យមើលទាំងអស់ឬក៏អត់នោះ គឺថាចម្លើយ គឺថាខ្ញុំមិនអាចអាននូវគ្រប់ទាំងអស់នោះទេ។ ហើយចម្លើយទៅនឹងថា តើខ្ញុំអានគ្រប់ឯកសារកំណត់ហេតុស្តាប់ចម្លើយ ឬក៏អត់? គឺថា ខ្ញុំមិនអាចអានទាំងអស់បានទេ ប៉ុន្តែការខិតខំប្រឹងប្រែងរបស់យើងខ្ញុំគឺ ប្រឹងប្រែងបង្ហាញនូវចំណុចនេះ គឺថាយោងទៅតាមការចងចាំចម្លើយរបស់គាត់ដែលបានផ្តល់នៅពេលនេះ នៅពេលដែលគាត់ផ្តល់សក្ខីកម្មនោះ បង្ហាញឯកសារទៅគាត់។ ហើយខ្ញុំ--

[១០:១៣:៣២]

**ប្រធានអង្គជំនុំ៖**

យើងមានការចាប់អារម្មណ៍លើពីរចំណុច។ ពាក់ព័ន្ធជាមួយនឹងវិធាន៧៦ ប្តឹងសុំមោឃភាព ដោយការមិនគោរពវិធានប្បញ្ញត្តិ នៅក្នុងកថាខណ្ឌ២ នៃវិធាននោះចែងថា "ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យប្តឹងសុំ ដោយបញ្ជាក់ពីមូលហេតុទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកា ដែលអាចជាការទទួលយក ឬបដិសេធសំណើសុំភ្លាមៗតាមដែលអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើមុនពេលចេញដីកាដំណោះស្រាយ។ ដីកាបែបនេះ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ"។

[១០:១៥:២៨]

ហើយឆ្លើយតបនឹងបញ្ហានេះ គឺ៧៦(៧) យើងបានអានពីរដងហើយ គឺបានបង្ហាញអំពីដីកាដំណោះស្រាយកែតម្រូវកំហុសមិនគោរពវិធានប្បញ្ញត្តិនៅក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលអាចពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ។ នេះជាបញ្ហាដែលយើងធ្វើការកត់សម្គាល់ពីព្រោះលោកឃើញថា តាំងសំណួរនេះ គឺហាក់ដូចជាបង្ហាញអំពីភាពពាក់ព័ន្ធនឹងអង្គហេតុ ដែលចោទប្រកាន់ទៅលើជនជាប់ចោទ ពីព្រោះបញ្ហានេះ គឺយើងធ្វើការងារនៅក្នុងការដេញដោល ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលចោទប្រកាន់ដាក់បន្ទុកលើជនជាប់ចោទ។ យើងគ្រាន់តែចង់បញ្ជាក់ឲ្យលោក បញ្ជាក់ឲ្យបានច្បាស់លាស់បញ្ហាហ្នឹងទេ ពីព្រោះយើងឃើញបញ្ហានេះច្រើនឡើងហើយដែរ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន ប៉ុន្តែវាមានករណីលើកលែង។ អ្វីដែលលោកប្រធានលើកឡើងនោះ គឺថាយើងខ្ញុំមិនមានឱកាសដើម្បីតតាំងជាមួយសាក្សីនេះទេ លោកប្រធានកំពុងតែដកសិទ្ធិរបស់ខ្ញុំ។ ខ្ញុំមិនមែនស្នើសុំមោឃភាពនៃដំណើរការនិតិវិធីនេះទេ ប្រហែលជាចៅក្រមយល់ឃើញថាខ្ញុំកំពុងស្នើសុំមោឃភាពដំណើរការនីតិវិធីនេះហើយ។ ខ្ញុំគ្រាន់តែថាអ្វីដែលបាននិយាយនៅលើខ្សែអាត់សំឡេងថតសំឡេងពីសាក្សីនេះ ហើយយើងបានស្តាប់ឮនូវខ្សែអាត់សំឡេងដែលថាគាត់បានទទួលស្គាល់ថា គាត់បាននិយាយជាមួយអ្នកស៊ើបអង្កេតមុនការធ្វើកំណត់ហេតុនេះ។ គឺអ្នកស៊ើបអង្កេតនេះ គឺអ្នកស៊ើបអង្កេត

តែមួយ ដែលពាក់ព័ន្ធទៅនឹងបញ្ហានេះ។ ហើយយើងដឹងអ្នកស៊ើបអង្កេតជាតិម្នាក់ គឺថាគាត់ពាក់ព័ន្ធទៅនឹងខាងផ្នែកការិយាល័យសហចៅក្រមស៊ើបអង្កេត អ៎! សូមទោស ការិយាល័យសហព្រះរាជអាជ្ញា។ ហេតុដូច្នេះឯងបានជាខ្ញុំថា តើមានអ្វីកើតឡើងនៅមុនលោកផ្តល់ចម្លើយនោះ? តើការសាកសួរនេះមានរាស៊ីអស់រយៈពេលប៉ុន្មាន ហើយគោលបំណងអ្វីបានជាយើង -- គេធ្វើបែបដូច្នេះ? បើសិនជាយើងចង់ឲ្យមានតម្លាភាព--

[១០:១៦:៤៤]

**ប្រធានអង្គជំនុំ៖**

បានហើយ ប៉ុណ្ណឹងបានហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៨:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីឆ្លើយតបដោះស្រាយបញ្ហានេះ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កាណាវាស អង្គជំនុំជម្រះសូមរំឭកនូវចំណុចមួយចំនួន។ ជាដំបូង គឺការស៊ើបអង្កេតតុលាការដែលបានធ្វើឡើងមុនការជំនុំជម្រះនេះ គឺថាមានរយៈពេលរាប់ឆ្នាំមកហើយ។ ហើយនៅអំឡុងពេលនៃកិច្ចស៊ើបសួរ កិច្ចស៊ើបសួរត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ក្រុមមេធាវីការពារក្តីក៏អាចចូលមើលសំណុំរឿងនេះបានដែរ។ ហើយជនជាប់ចោទក៏អាចពិនិត្យមើលបាន។ រាល់បញ្ហាទាំងអស់ដែលបានកើតឡើងនោះ គឺបញ្ហាចោទទៅលើកំណត់ហេតុនៃការស៊ើបអង្កេត និងព័ត៌មានផ្សេងៗដែលមាននៅក្នុងកំណត់ហេតុនោះ។

[១០:២០:០០]

មេធាវីការពារក្តីទាំងអស់ គឺអាចមើលបានព័ត៌មានទាំងអស់ ដែលមាននៅក្នុងកំណត់ហេតុទាំងអស់នោះ។ ទោះបីជាលោកប្រធានអង្គជំនុំជម្រះបានរំឭកជាច្រើនលើក ហើយច្រើនលើកច្រើនសារួចមកហើយ ពាក់ព័ន្ធទៅនឹងបញ្ហាដែលបានចោទឡើង ពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយនោះ ក៏យើង

មិនអាចចោទជាបញ្ហាទៅលើការស៊ើបអង្កេតនោះដែរ។ ពាក់ព័ន្ធទៅនឹងខ្សែអាត់ស្តាប់សំឡេង ខ្សែអាត់ទាំងអស់នេះ មានជាភាសាខ្មែរ ហើយមិនមានការបកប្រែ ឬក៏មិនមានប្រតិចារឹកជាភាសាបារាំង ឬក៏អង់គ្លេសនៃខ្សែអាត់នោះដែរ។ ក៏ប៉ុន្តែមេធាវីការពារក្តី គឺមានមេធាវីជាជនជាតិខ្មែរ ហើយមេធាវីខ្មែរនីមួយៗនោះ មានលទ្ធភាពក្នុងការស្តាប់ខ្សែអាត់ទាំងអស់នោះ ប្រសិនបើខ្លួនចង់ស្តាប់។ យើងអាចសួរថា តើមេធាវីការពារក្តីធ្វើអ្វីខ្លះ នៅក្នុងអំឡុងរយៈពេលប៉ុន្មានឆ្នាំនៃកិច្ចស៊ើបសួរនេះ? នេះគឺជាសំណួរដែលលោកចោទសួរខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងសុំឲ្យមេធាវីការពារក្តីដោះ -- ចោទសួរពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗ បញ្ហាសារធាតុ។ យើងមិនត្រូវចោទសួរដដែលៗ ពាក់ព័ន្ធទៅនឹងបញ្ហានៃការស៊ើបអង្កេតនោះទេ។ យើងទទួលបានសំណើជាលាយលក្ខណ៍អក្សរជាច្រើន ពាក់ព័ន្ធទៅនឹងបញ្ហាទាំងអស់នេះ។

[១០:២១:៣៩]

អង្គជំនុំជម្រះនឹងឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះក៏ប៉ុន្តែយើងបានស្តាប់គ្រប់គ្រាន់ហើយ ពាក់ព័ន្ធទៅនឹងចំណុចទាំងអស់នេះ។

**លោក ម៉ែខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**អ្នកបកប្រែ៖**

ស្តាប់អត់បាន។ សូមទោសលោកប្រធាន ស្តាប់អត់បាន មេធាវីការពារក្តីអម្បាញ់មិញ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអញ្ជើញនិយាយសាជាថ្មីម្តងទៀត ពីព្រោះមិនមានការបកប្រែជាភាសាខ្មែរទេ។

[១០:២២:២៧]

**លោក ម៉ែខល កាណាវាស៖**

បាទ នៅពេលនេះ គឺខ្ញុំចង់ចាក់ខ្សែអាត់សំឡេងលើកទី១។ ចង់ជម្រាបថា ចៅក្រម ឡាវែន៍ កំណត់សម្គាល់របស់លោកចៅក្រម ឡាវែន៍ គឺខ្ញុំមិននិយាយពីអ្នកស៊ើបអង្កេតទេ ខ្ញុំនិយាយពីសក្ខីកម្មរបស់សាក្សីរូបនេះ ដែលថាយ៉ាងហោចណាស់ គឺតាមការសន្មតរបស់ខ្ញុំ គឺយើងចង់ស្វែងរកនូវការពិត។ នៅពេលដែលយើងចាក់ខ្សែអាត់នេះ គឺយើងនឹងបានស្តាប់ឮថា "ខ្ញុំចង់ឲ្យលោករៀបរាប់អំពីខ្សែជីវិតរបស់លោក ដូចដែលលោកបានរៀបរាប់ប្រាប់ខ្ញុំកាលពីម្សិលមិញ" មានន័យថា ១ថ្ងៃមុន គឺមិនបានថត

សំឡេងទេ គេបានប្រាប់អំពីសិទ្ធិរបស់គាត់។ ១ថ្ងៃមុនថតសំឡេងនេះ គឺមិនមានការសម្ភាសទេ តើនៅពេលហ្នឹង តើមានបង្ហាញឯកសារអ្វីខ្លះ ទៅដល់សាក្សីរូបនេះ?

[១០:២៣:៣៣]

ការស្ដាប់ចម្លើយនេះធ្វើឡើងនៅពេលណា? ហើយនេះ ខ្ញុំមានសិទ្ធិត្រូវសួរបែបនេះ គឺថាបើសិនណាជាមិនអនុញ្ញាតខ្ញុំសាកសួរទេ ដើម្បីឲ្យ -- ការដែលខ្ញុំចង់សួរ ចង់ឲ្យអង្គជំនុំជម្រះបានយល់ឲ្យបានច្បាស់ ដើម្បីឈានទៅដល់ការស្វែងរកការពិត។ ពីព្រោះសំណួរទាំងអស់នេះ គឺថាវាសំខាន់ណាស់។ តើ -- ហេតុដូច្នេះឯងបានជាយើងចង់ស្ដាប់សក្ខីកម្មសាក្សីរូបនេះ នៅចំពោះមុខអង្គជំនុំជម្រះក្នុងសវនាការនេះតែម្ដង។ គាត់បានប្រាប់យើងជាញឹកញាប់មកហើយ ថាគាត់មិនច្បាស់លាស់នូវអ្វីដែលគាត់និយាយ ហើយក្រោយមក គាត់បានចុះហត្ថលេខា ហើយគាត់យល់ស្របទៅនឹងខ្លឹមសារ។ បើគាត់ចុះហត្ថលេខាដែលគាត់បានស្បថ ហើយយល់ស្របទៅនឹងខ្លឹមសារហ្នឹង ថាវាពិត ឬក៏មិនពិត ឬក៏អ្នកណាបានបញ្ចូលខ្លឹមសារខ្លះទៅនឹងកំណត់ហេតុនេះ។ ទាំងអស់នេះ គឺជាបញ្ហាដែលខ្ញុំត្រូវមានសិទ្ធិលើកឡើង និងពន្យល់ថាហេតុអ្វីអំពីមូលហេតុទាំងអស់នេះ។

ហើយសហព្រះរាជអាជ្ញាបានស្ដាប់នូវសក្ខីកម្ម និងកំណត់ហេតុស្ដាប់ចម្លើយនេះរាប់ពាន់ គឺយើងខ្ញុំ និងក្រុមខ្ញុំនេះ ប៉ុន្មានឆ្នាំ ជិត៤ឆ្នាំនេះ យើងខ្ញុំសូមរំឭកថានេះជាលើកទី១ នៅក្នុងប្រទេសកម្ពុជាដែលត្រូវយកមកដោះស្រាយចំពោះមុខអង្គជំនុំជម្រះទេ បើមិនដូច្នេះទេ យើងបោះបង់សិទ្ធិនេះចោល។

ក្រុមរបស់យើងខ្ញុំបានសុំលើកឡើងថា និយាយអំពីសហព្រះរាជអាជ្ញា គាត់បានលើកឡើងអំពីបញ្ហា *វ៉ូមិន លីជិន* នេះ ដែលអាចជួយទៅដល់អង្គជំនុំជម្រះ ដើម្បីថ្លឹងថ្លែងអំពីសក្ខីកម្មរបស់សាក្សីរូបនេះ ដែលយើងអាចនឹងមើលឃើញ បើសិនលើកឡើង យើងនឹងឃើញថាតើសំណើសុំឲ្យមានការស៊ើបអង្កេត ជាលើកទី៣ គឺថា ខ្ញុំស្នើសុំទម្រង់បែបបទ គំរូនៃការស៊ើបអង្កេត នេះគឺធ្វើឡើងដោយរបៀបណា? តើគេស្វែងរកភស្តុតាងដោះបន្ទុកបានដោយរបៀបណា? យើងមិនដែលបានទទួលចម្លើយ តាមរយៈសំណើរបស់យើងខ្ញុំនោះទេ។ ដូច្នេះប្រហែលយើងខ្ញុំអាចនឹងបានចម្លើយ តាមរយៈសំណួររបស់ខ្ញុំនេះ ដែលសួរទៅកាន់សាក្សីរូបនេះ ដើម្បីឲ្យគាត់ប្រាប់ខ្ញុំថាតើការសម្ភាសនេះគឺ គេបានធ្វើឡើងជាមួយគាត់នៅមុនការកត់ត្រាហ្នឹង គឺប៉ុន្មានម៉ោង? ហើយនៅក្នុងលក្ខខណ្ឌស្រដៀងគ្នានេះដែរ ទាក់ទងទៅនឹងការធ្វើការសម្ភាសនេះតែម្ដង។

[១០:២៦:២៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបដោយសង្ខេបទេ។ ការកត់ត្រានេះគឺថាត្រឹមត្រូវក្នុង ចំណុចមួយចំនួន។ ទី១ មេធាវីការពារក្តី គាត់បានលើកឡើងថា កំណត់ហេតុស្តាប់ចម្លើយ មានដល់រាប់ពាន់ឯណោះ។ វាមិនមែនជាការពិតទេ។ គឺការនិយាយយោងដំបូងថាមាន តាមការពិតមាន ៩៤៣ កំណត់ហេតុស្តាប់ចម្លើយនេះ ដែលមេធាវីក្រុមមេធាវីការពារក្តី មានគ្នាច្រើននេះ អាចនឹងពិនិត្យមើលទៅបានគឺថា ហើយខាងការិយាល័យសហព្រះរាជអាជ្ញា ក៏មានធនធានមនុស្សប្រហាក់ប្រហែលគ្នាហ្នឹងដែរ។ ទាក់ទងទៅនឹងការ សាកសួរ ដែលមេធាវីការពារក្តី គាត់បានលើកឡើងនោះ ខ្ញុំបានកត់សម្គាល់នូវការណែនាំរបស់អង្គជំនុំជម្រះ ហើយខ្ញុំក៏សូមបន្ថែមទៅក្នុងប្រតិចារឹកផងដែរ។ ចម្លើយនេះគឺបានដាក់នៅថ្ងៃទី១៥ ខែកញ្ញា ២០០៩ ក្រៅពីកំណត់ហេតុស្តាប់ចម្លើយជាង៩០០នេះ គឺមានកំណត់ហេតុស្តាប់ចម្លើយមួយចំនួនតូចទៅហ្នឹង ទាក់ទងទៅនឹងអត្តចរិត អាកប្បកិរិយារបស់ជនជាប់ចោទនៅក្នុងនោះគឺថាមាន ដូចមួយ ជាអ្នកឆ្លើយទៅនឹងបញ្ហាអាកប្បកិរិយា និងអត្តចរិតរបស់ជនជាប់ចោទនោះ។

[១០:២៨:១០]

ការដែលមិនបានលើកឡើងនូវបញ្ហាទាំងអស់នេះ ជាមួយសហចៅក្រមស៊ើបអង្កេត ការខកខានមិនបានដាក់សំណើពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរនោះ គឺជាការមិនត្រឹមត្រូវទេ ដែលមេធាវីការពារក្តីត្រូវធ្វើបែបនេះនៅមុននោះ។ ប៉ុន្តែពេលនេះមេធាវីការពារក្តី ត្រឡប់មកលើកបញ្ហានេះក្នុងរយៈពេល៣ឆ្នាំក្រោយមក ហើយគេមិនបានលើកឡើងបញ្ហានេះ នៅជាមួយនឹងអង្គជំនុំជម្រះជាមុននោះទេ។ យើងខ្ញុំយល់ស្របប្រសិនណាជាមេធាវីការពារក្តី លើកឡើងឃើញថា មានភាពមិនស៊ីសង្វាក់គ្នា មានសំណួរណាមួយដែលមិនស្របច្បាប់ ពាក់ព័ន្ធទៅនឹងភាពគួរឲ្យជឿជាក់បាន នៃការសម្ភាសសាក្សី។

[១០:២៩:០២]

ដូច្នេះ ចំណុចទាំងអស់នេះ គួរតែលើកឡើងដើម្បីឲ្យបាននូវប្រតិចារឹក ក៏ដូចជាចម្លើយជាមុន។ ប៉ុន្មានថ្ងៃមកនេះ គឺយើងឃើញអំពីការបង្ខំឲ្យសាក្សីនេះឆ្លើយ ដើម្បីបញ្ជាក់អំពីភាពស៊ីសង្វាក់គ្នា នៃចម្លើយរបស់សាក្សីរូបនេះ ជៀសវាងការឲ្យសាក្សីរូបនេះឆ្លើយដោយស្មានៗ។ ដូច្នេះ យើងខ្ញុំសូមស្នើថា ចេតនានៃការបង្កើតឲ្យមានភាពចម្រូងចម្រាសគ្នានេះគឺ មិនគួរឲ្យមាននោះទេ។ ជាពិសេស យើងខ្ញុំគាំ

ទ្រទៅដល់សិទ្ធិរបស់មេធាវីការពារក្តីក្នុងការតាំងជាសំណួរផ្សេងៗ។ ប៉ុន្តែនៅក្នុងករណីនេះ មិនគួរឲ្យវាលើកពីចំណុចនេះទៅបាននោះទេ។ ដូច្នេះ គួរតែឲ្យមេធាវីការពារក្តី តាំងនូវសំណួរទាំងឡាយណា ដែលវាស៊ីសង្វាក់គ្នាទៅនឹងចម្លើយនេះ។ សូមអរគុណលោកប្រធាន។

[១០:៣០:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣០:២១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលរដ្ឋតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក។ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយ ខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១១:០៥ នាទី)*

[១១:០៥:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងបន្តនីតិវិធីទៅទៀត ដើម្បីដោះស្រាយនូវបញ្ហាដែលកើតមាននៅក្នុងបច្ចេកទេស ឬក៏វិធីសាស្ត្រក្នុងការតាំងសំណួរដេញដោលដោយសាក្សី ដោយមេធាវី ម៉ៃខល កាណាវាស មេធាវីអន្តរជាតិការពារក្តីលោក អៀង សារី អម្បាញ់មិញនេះ។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយបំភ្លឺតបទៅនឹង

បញ្ហាដែលកើតមានឡើងនេះ។

សូមអញ្ជើញលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍!

[១១:០៦:១១]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពាក់ព័ន្ធទៅនឹងបញ្ហារបស់លោក កាណាវាស ហើយក្នុងនាមឲ្យអង្គជំនុំជម្រះសាលាដំបូង។ ទី១ ខ្ញុំសូមទទួលស្គាល់ថា តាមការដែលយល់ទៅបាន អ្នកដែលមកពីប្រព័ន្ធច្បាប់ផ្សេងៗគ្នា តែងតែមានការយល់ឃើញផ្នែកគតិយុត្តិនេះខុសៗគ្នា។ ប៉ុន្តែសម្រាប់នីតិវិធីនៃដំណើរការរបស់សាលាក្តីនេះ គឺយើងមានការយល់ស្របគ្នាជាយូរមកហើយ ជាពិសេសគឺកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ ហេតុដូច្នេះឯងបានជាវិធានទូទៅនោះគឺថា មានសច្ចធារណ៍គតិយុត្តិ និយាយអំពីសុចរិតភាពនៃការស៊ើបអង្កេត ដែលថា រាល់ការព្រួយបារម្ភពាក់ព័ន្ធទៅនឹងវិធីសាស្ត្រ ឬក៏កម្មវត្ថុណាមួយ ដែលកើតមានឡើងក្នុងអំឡុងពេលស៊ើបអង្កេតនេះ ត្រូវតែលើកឡើងក្នុងអំឡុងពេលស៊ើបអង្កេតនោះតែម្តង។ ហើយឥឡូវនេះគឺនៅក្នុងពេលសវនាការនេះ ដូចជាលោកចៅក្រម ឡាវែន៍ គាត់បានលើកឡើងហើយថា ការស៊ើបអង្កេតត្រូវបានចាត់ទុកថាជាចំណុចចាប់ផ្តើម ហើយអាចជំទាស់តវ៉ាតែនៅក្នុងករណីលើកលែងមួយចំនួនតែប៉ុណ្ណោះ។ រាល់ការជំទាស់តវ៉ាទាំងនោះ មិនមែនត្រូវតែពាក់ព័ន្ធទៅនឹងបញ្ហាបច្ចេកទេសទេ ក៏ប៉ុន្តែវាត្រូវតែពាក់ព័ន្ធទៅនឹងខ្លឹមសារផងដែរ។

[១១:០៨:០០]

ហើយការលើកឡើង -- ហើយចំពោះការលើកលែងនេះ គឺថាត្រូវតែបំពេញលក្ខខណ្ឌឲ្យបានច្បាស់លាស់ថា មានមូលហេតុគ្រប់គ្រាន់ដែលពាក់ព័ន្ធទៅនឹងការគួរឲ្យជឿជាក់បាននៅត្រង់ផ្នែកណាមួយនៃការស៊ើបអង្កេត។ ដូច្នេះ យើងមិនអាចយកពាក្យពេចន៍នៃច្បាប់ខំមិនឡ យកមកធ្វើជាអំណះអំណាងនោះទេ។

ហើយចំពោះអង្គជំនុំជម្រះសាលាដំបូងវិញគឺ អ្វីដែលសាក្សីអាចនិយាយនៅក្នុងពេលស៊ើបអង្កេតនោះ គឺសាក្សីអាចនិយាយបានថា ភស្តុតាងអាចនឹងយកមកដោះស្រាយ ដោយចោទសំណួរផ្សេងៗទៅលើសាក្សីរូបនោះ។ សម្រាប់ហេតុផលនេះអង្គជំនុំជម្រះយល់ឃើញ ការលេង -- ការចាក់ឡើងវិញនូវផ្នែកណាមួយនៃខ្សែអាត់សំឡេងនេះគឺមិនជួយដល់ផ្នែកណាមួយនោះទេ គឺថាត្រូវតែបង្ហាញមូលហេតុ

ឲ្យបានច្បាស់លាស់ថា វាមានការពាក់ព័ន្ធទៅដល់ការស៊ើបអង្កេតនោះតែម្តង។ ហេតុដូច្នេះ យើងយល់ឃើញថា គឺលោកគ្រាន់តែសួរសំណួរណាមួយ ទៅសាក្សីតែប៉ុណ្ណោះបានហើយ។ ខ្ញុំសូមផ្អាកត្រឹមនេះសិន ក្រែងលោលោកប្រធានមានបញ្ហាអ្វីត្រូវបន្ថែមទៅនឹងអ្វី ដែលខ្ញុំកំពុងតែលើកឡើងនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ខ្ញុំមិនមានបញ្ហាអីបន្ថែមទៀតទេ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ។ ខ្ញុំយល់ស្របជាមួយនឹងសេចក្តីសម្រេចនេះ ហើយយើងខ្ញុំថាតើវាមានកាលៈទេសៈពិសេសលើកលែងណាមួយដែលត្រូវលើកឡើង ឬក៏យ៉ាងណានោះ។ ឥឡូវនេះយើងខ្ញុំយល់ហើយចំពោះជំហរបស់អង្គជំនុំជម្រះ។

សហការីរបស់ខ្ញុំបានជម្រាបមកខ្ញុំថា អ្នកស៊ើបអង្កេតជាតិមួយ គឺថាវាជាប់សាច់ញាតិ ជាប់ពាក់ព័ន្ធទៅនឹងសហ -- គឺគាត់ជាប្អូនប្រុសទៅដល់សហព្រះរាជអាជ្ញាជាតិមួយរូប។ ហេតុដូច្នេះហើយបានជាយើងដាក់ -- គឺពាក់ព័ន្ធទៅនឹង E2/224 ពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

សូមៗ! សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៌៖**

សូមទោសលោក ម៉ៃខល កាណាវាស ខ្ញុំក៏ចង់លើកឡើងនៅចំណុចនេះដែរ។ អ្វីដែលលើកឡើងថា វាមានមិនត្រឹមត្រូវដែលយល់ឃើញថា ជាការមិនត្រឹមត្រូវនោះ ប្រសិនណាអ្នកណាម្នាក់ជាប់សាច់ញាតិនោះ គឺថាត្រូវតែស្នើសុំឲ្យអង្គជំនុំជម្រះពិនិត្យមើលទៅលើ (ឮមិនច្បាស់)។ ដូច្នេះចំណុចនេះ គឺនៅក្នុងអង្គសវនាការនេះគឺថា មិនអាចទទួលយកបានទេ។ សូមអភ័យទោសដែលខ្ញុំកាត់ផ្តាច់លោក។ ដូច្នេះសូមចាប់ផ្តើមតាំងសំណួរតែម្តងទៅ!

[១១:១១:១៩]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមទោសលោកស្រីចៅក្រម ខ្ញុំព្យាយាមឲ្យអស់ពីលទ្ធភាពរបស់ខ្ញុំដើម្បីប្រើប្រាស់នូវ វិជ្ជាជីវៈរបស់ខ្ញុំ ដោយការខិតខំប្រឹងប្រែងបំផុត។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរសំណួរងាយៗទៅលោក។ ១ថ្ងៃមុនគេសម្ភាសថតខ្សែអាត់សំឡេងនោះ តើលោកមានការជួបជាមួយអ្នកស៊ើបអង្កេតដែរឬទេ? ហើយបើបានជួបថាតើលោកជួបនៅទីកន្លែងណា?

[១១:១១:៥៥]

**លោក នង សុផង់៖**

**ឆ៖** បាទ ១ថ្ងៃមុននឹងគេសម្ភាស គេបានជួបខ្ញុំនៅជាមុនដែរ គឺគេបានជួបនៅពេលដែលខ្ញុំកំពុងបង្រៀនសិស្សនៅសាលាបឋមសិក្សាអូរចម្លងបាទ។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញសហការីរបស់ខ្ញុំបានបង្ហាញនូវផ្នែកមួយ នៃកំណត់ហេតុស្ដាប់ចម្លើយលើកទីមួយរបស់លោក លោកនិយាយអំពីឈ្មោះ ប៉ង់។ ប៉ុន្ដែនៅក្នុងសេចក្ដីសង្ខេបនូវចម្លើយមិនមានឈ្មោះនេះទេ ពីមុន។ ឈ្មោះ ប៉ង់ នេះគឺគេបាននិយាយគ្នានៅមុនការសម្ភាសនេះ តើលោកនៅចាំទេ លោកបានលើកពីឈ្មោះ ប៉ង់ នេះនៅពេលដែល១ថ្ងៃមុននឹងថតខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍ជាមួយនឹងលោកនេះទេ?

[១១:១៣:០០]

**ឆ៖** ខ្ញុំមិនចាំបានទេ ព្រោះថា មុននឹងថតសំឡេងគេមិនបានសួរនាំអីពីឈ្មោះ ប៉ង់ ហ្នឹងដែរ។

**ស៖** បាទ សូមអរគុណ។ តើលោកមានត្រូវបានគេជួបសម្ភាស ឬក៏សួរសំណួរផ្សេងៗមុននឹងការសម្ភាសជាផ្លូវការជួយមួយលោកដែរឬទេ?

**ឆ៖** បាទ មុននឹងជួបសម្ភាសគេបានសួរសំណេះសំណាលអីខ្លះដែរ តែខ្ញុំពុំចាំនូវការសន្ទនានៅពេលនោះទេបាទ។ ព្រោះគ្មានអ្វីជាលាយលក្ខណ៍អក្សរ ហើយក៏គេមិនបានថតសំឡេងទុក។ ដូច្នេះវា ៣-៤ឆ្នាំទៅហើយ អ្នកណាទៅចាំបានបាទ។

**ស៖** ចុះការជួបសន្ទនាគ្នារបស់លោកជាមួយអ្នកស៊ើបអង្កេត ១ថ្ងៃមុននោះ តើលោកបានជួបគ្នាអស់រយៈពេលប៉ុន្មានដែរ? ហើយនិយាយគ្នាពីអ្វីដែរ?

[១១:១៤:២៩]

**ឆ៖** បាទ តាមខ្ញុំគិតឡើងវិញដូចជា មិនយូរប៉ុន្មានទេ ប្រហែលជា ១ម៉ោងអីតែប៉ុណ្ណឹងទេ។ ព្រោះម្យ៉ាងខ្ញុំកំពុងជាប់បង្រៀនសិស្សផង ហើយគេក៏អង្គុយរង់ចាំខ្ញុំរហូតដល់ពេលដែលខ្ញុំចេញលេង

ទើបបានគេហៅមកសន្ទនាគ្នាបាទ។ អ៊ីចឹងប្រហែលជានៅក្នុងរយៈពេលម៉ោងដប់ហើយ យើងចេញលេងម្តង។ តែ១ម៉ោងប៉ុណ្ណឹងទេ បាន១ចេញទៅផ្ទះបាទ។

**ស៖** សូមអរគុណ។ សូមបន្តទៅមុខបន្តិចទៀត មុន -- នៅពេលដែលលោកអានសេចក្តីសម្រង់នៃកិច្ចសម្ភាសន៍នេះ ហេតុផលដែលខ្ញុំសួរលោក គឺនៅពេលដែលលោកផ្តល់សក្ខីកម្មរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ នៅពេលនោះលោកឆ្លើយដោយស្មាន នៅពេលដែលលោកឆ្លើយ គឺលោកឆ្លើយដោយស្មានលោកចាំទេ? តើអ៊ីចឹង ឬក៏យ៉ាងណា?

[១១:១៦:០៥]

**ឆ៖** បាទ មានពាក្យជាច្រើនដែលខ្ញុំឆ្លើយនៅពេលនោះ។ មានពាក្យ “ប្រហែល” មានពាក្យ “ស្មាន” ហើយក៏មានពាក្យ “អាចអ៊ីចេះ, អាចអ៊ីចុះ”។ នេះគឺមកពីកាលដែលអស់លោកចៅក្រមស៊ើបអង្កេតមិនបានបញ្ជាក់ខ្ញុំថា អ្វីដែលជាពាក្យ “ស្មាន” ពាក្យ “ប្រហែល” ពាក្យ “អាចអ៊ីចេះ អាចអ៊ីចុះ” ហ្នឹងគេមិនយកជាការបានទេ។ លោកមានតែឲ្យខ្ញុំជួយពន្យល់ជួយអ៊ីចេះអ៊ីចុះតែប៉ុណ្ណឹង។ ឯត្រង់ពាក្យពេចន៍ថា ណែនាំថា កុំឲ្យនិយាយរឿងស្មានរឿងប្រហែល គឺអត់មាន អស់លោកណែនាំខ្ញុំទេបាទ។

**ស៖** សូមអរគុណ។ ឃ្លាមួយដែលលោកបានពិនិត្យឡើងវិញនោះ គឺនៅក្នុងកំណត់ហេតុស្តាប់ចម្លើយទាំងពីរនេះតែម្តង។ បើតាមខ្ញុំយល់នោះ តាមដែលខ្ញុំយល់ទៅបាន នៅពេលដែលលោកនិយាយថា “តាមដែលខ្ញុំយល់” តើឲ្យខ្ញុំបកស្រាយថាលោកក៏និយាយស្មានដែរឬក៏យ៉ាងណា?

**ឆ៖** បាទ ព្រោះពេលនុ៎ងអស់លោកបានឲ្យខ្ញុំថា ជួយពន្យល់។ អ៊ីចឹងការពន្យល់របស់ខ្ញុំនេះ គឺទៅតាមស្មារតីដែលខ្ញុំយល់បាទ។ គឺពុំមែនជាការពិតនោះយ៉ាងណាទេបាទ គឺវាស្មើនឹងការវិភាគ ការប៉ាន់ស្មានដែរ អាពាក្យថា “តាមខ្ញុំយល់” នេះបាទ វាមានតម្លៃស្មើគ្នានឹងពាក្យតាមខ្ញុំស្មានដែរ។

[១១:១៨:០៧]

**ស៖** នេះនឹងត្រូវឆ្លើយទៅនឹងសំណួរបន្ទាប់របស់ខ្ញុំហើយ។ នៅក្នុងឃ្លាដដែល១លោកក៏និយាយថា សូម្បីតែនៅក្នុងអង្គជំនុំជម្រះនេះ -- នៅចំពោះមុខអង្គជំនុំជម្រះក៏ដោយ។ នៅពេលដែលលោកនិយាយថា “តាមការវិភាគរបស់ខ្ញុំ” ជាពិសេសនៅពេលអ្នកស៊ើបអង្កេតបង្ហាញឯកសារទៅលោក តើនៅពេលនោះលោកឆ្លើយស្មានក្នុងការបកស្រាយទៅនឹងឯកសារណាមួយ ឬក៏បកស្រាយទៅលើព្រឹត្តិការណ៍ណាមួយ ឬក៏យ៉ាងណាដែរ?

**ឆ៖** បាទ ការឆ្លើយហ្នឹង គឺវាអាស្រ័យទៅនឹងសំណួរដែលអស់លោកសួរបាទ។ បើលោកសួរ

ទៅលើបញ្ហាអ្វី ចំពោះព្រឹត្តិការណ៍ ឬសំណួរទាំងហ្នឹងដែលខ្ញុំយល់កម្រិតណា ក៏ខ្ញុំនិយាយទៅតាមកម្រិតនៃការយល់ដឹងរបស់ខ្ញុំបាទ។

[១១:១៩:១៦]

**ស៖** បាទ សូមអរគុណ។ ហើយកាលពីម្សិលមិញ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា ខ្ញុំហ្នឹងបានយល់ៗថា គោលការណ៍ដែលលោកនិយាយ ឬក៏ឆ្លើយស្មានៗទៅនឹងសំណួរដែលចៅក្រមបានសួរទៅលោក។ ឥឡូវខ្ញុំសូមលើកយកចម្លើយដែលលោកឆ្លើយកាលពីម្សិលមិញ យើងអាចរកឃើញនៅទំព័រទី៦ ដែលមានលេខ ERN 091653 -- បាទ នៅម៉ោង ០៩:១៦:៥៣ “ថាតើវាអាចទេ ដែលថា សោ ភឹម អាច -- ខ្ញុំ ថាតើលោកយល់បញ្ហានេះទេ? ប៉ុន្តែសួរថាតើវាអាចអ្នកដែលស៊ីញេនេះ ជា សោ ភឹម ឬក៏យ៉ាងណា?” លោកឆ្លើយថា “អាចជា សោ ភឹម”។ នេះជាឧទាហរណ៍មួយទេ។ នៅពេលលោកឆ្លើយទៅនឹងសំណួរនេះ តើលោកឆ្លើយស្មានៗដែរ ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់ចំពោះការលើកឡើងរបស់មេធាវីការពារក្តី ចំពោះចម្លើយរបស់គាត់នេះ។ វាមានសារៈសំខាន់ជាការពិត នេះគឺជាចម្លើយចុងក្រោយរបស់គាត់ គាត់ប្រើពាក្យថា “វិភាគ”។ ការវិភាគដោយយោងទៅលើការយល់របស់ខ្ញុំ។ មានលក្ខណៈខុសគ្នាជាចម្បង ទី១ រវាងការនិយាយដោយស្មានដោយមិនមានការដឹងអំពីអង្គហេតុ និងអ្នកដែលមានបទពិសោធន៍ជាង៨ឆ្នាំហើយ នៅក្នុងនីតិវិធីនៃការទំនាក់ទំនង ប្រព័ន្ធទំនាក់ទំនងគ្នា។ ដូច្នេះយើងខ្ញុំសូមស្នើដល់អង្គជំនុំជម្រះដោយក្តីគោរពថា នៅពេលដែលសាក្សីប្រើពាក្យរបស់គាត់ថា “វិភាគ ដោយយោងទៅលើការយល់ដឹងដ៏ទូលំទូលាយរបស់គាត់” ហេតុដូច្នេះហើយបានជាខ្ញុំជំទាស់ ដោយសារតែមេធាវីការពារក្តី គាត់មានការប្រើពាក្យពេចន៍នៃនិយាយដោយស្មានៗទៅលើសាក្សីរូបនេះ។

[១១:២១:៥៨]

ដូច្នេះ ខ្ញុំសុំឲ្យអង្គជំនុំជម្រះធ្វើការណែនាំទៅដល់មេធាវីការពារក្តី។ ប្រហែលជាមានការបកប្រែបាត់ពាក្យពេចន៍នៅក្នុងការពាក់ព័ន្ធ -- ក្នុងពាក្យពេចន៍ទាំងឡាយពាក់ព័ន្ធទៅនឹងភស្តុតាងនេះ។

**លោក ម៉ៃខល កាណាវាស៖**

ប្រសិនខ្ញុំសូមឆ្លើយដោយសង្ខេបទេ។ ដូច្នេះសម្រាប់ឲ្យតំណាងសហព្រះរាជអាជ្ញានេះ គាត់ក្រោកឡើងដើម្បីជំទាស់តវ៉ា ចំណុចនេះគឺថាវាអាចយកមកនិយាយក្នុងពេលធ្វើសេចក្តីសន្និដ្ឋាន។ សាក្សីរូបនេះ គឺថាគាត់ជាអ្នកធ្វើការនៅកន្លែងសារទូរលេខ លោកមានចម្លើយរបស់គាត់ហើយ។ ខ្ញុំសួរទៅគាត់ថា ខ្ញុំសួរគាត់នៅសំណួរមួយ គាត់ឆ្លើយចម្លើយមួយ ហើយខ្ញុំសួរថា “តើវាអាស្រ័យទៅលើការវិភាគ ឬក៏អាស្រ័យទៅលើការស្មាន?” ដូច្នេះ ខ្ញុំសូមទុកនាទីជូនអង្គជំនុំជម្រះដើម្បីសម្រេច។ ដោយសារសាក្សី គាត់មានពេលវេលាមួយដែលឆ្លើយមិនច្បាស់លាស់ នៅពេលដែលឆ្លើយថាគាត់ឆ្លើយនេះ គឺយោងទៅលើការវិភាគរបស់គាត់។ តែសំណួររបស់ខ្ញុំគឺថា នៅពេលដែលលោកចៅក្រម ឡាវែន៍ សួរសំណួររបស់គាត់ គឺមិនពាក់ព័ន្ធទៅនឹងការវិភាគទេ។ ប្រហែលជាតំណាងសហព្រះរាជអាជ្ញា គាត់ឆក់ឱកាសដើម្បីក្រោកឡើងជំទាស់របស់ខ្ញុំ ការជំទាស់នេះគឺថាមិនមានមូលដ្ឋាន -- ការជំទាស់នេះ គឺយឺតពេលហើយ។

[១១:២៣:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៦:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់ភារកិច្ចជូនទៅលោកស្រីចៅក្រម ស៊ីវៀល ខាតវ៉ាយថ៍ ដើម្បីសម្រេចលើបញ្ហានៃការលើកឡើងតាំងសំណួរចុងក្រោយ ដោយមេធាវីការពារក្តីលោក ខៀវ សារី ហើយនិងមានសេចក្តីជំទាស់ពីតំណាងសហព្រះរាជអាជ្ញា អម្បាញ់មិញនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះអនុញ្ញាតឲ្យមានការជំទាស់ពីតំណាងសហព្រះរាជអាជ្ញា ហើយអង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណួរដែលបានសួរទៅសាក្សី គឺដោយយោងទៅលើការស្មាន ដែលលោកចៅក្រម ឡាវែន៍ បានសួរទៅ ហើយឲ្យសាក្សីឆ្លើយស្មាននោះ មិនមែនជាការត្រឹមត្រូវទេ។ វាជាការចាំបាច់ណាស់ដែលត្រូវពាក្យថា “*ស្ពិចឃ្យូលេសិន*” ពាក្យជាភាសាអង់គ្លេសនេះ គឺថា “ស្មាន” គឺមិនមានមូលដ្ឋានជាក់លាក់ណានោះទេ។

[១១:២៧:២៩]

សក្ខីកម្មរបស់សាក្សីរូបនេះ ត្រូវបានបកស្រាយថាជាការវិភាគ ដែលជាចម្លើយរបស់សាក្សី ដោយសំអាងទៅលើអង្គហេតុដែលគាត់ធ្លាប់បានដឹង។ ដូច្នេះ ជាលទ្ធផលគឺថាការប្រើថា ពាក្យថា "ស្មាន" គឺមិនអាចទទួលយកបានទេ ពាក់ព័ន្ធទៅនឹងអ្វីដែលសាក្សីនេះ គាត់បានឆ្លើយថា វិភាគនោះ គឺវាខុសគ្នា។ ដូច្នេះ លោក កាណាវាស សូមលោកជៀសវាងកុំប្រើពាក្យ "ស្មាន" សូមឲ្យប្រើពាក្យកណ្ដាលមួយ ពាក្យអព្យាក្រិត្យមួយ នៅពេលដែលលោកធ្វើការតាំងសំណួរ លោកជំទាស់តវ៉ានោះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយធ៍។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** យើងខ្ញុំសូមត្រឡប់ចូលមកបញ្ហាខាងដើមអម្បាញ់មិញនេះវិញ។ បាទ ខ្ញុំសូមបន្តទៅមុខ ខ្ញុំត្រឡប់មកបញ្ហាការវិភាគរបស់លោកជាក្រោយ។ បន្ទាប់ពីលោកបានស្ដាប់នូវសេចក្ដីសង្ខេបនៃចម្លើយរបស់លោក ដោយសារលោកដឹង ថាលោកត្រូវចុះហត្ថលេខា ចាត់ទុកថា វាជាចម្លើយមួយដែលធ្វើនៅក្រោមសម្បថ ហើយនៅក្នុងតុលាការនេះ គឺមានការសួរទៅលោកពាក់ព័ន្ធទៅនឹងកូនក្ដីរបស់ខ្ញុំ គឺលោក អៀង សារី ដែលនៅក្រសួងការបរទេស។

[១១:២៩:១៣]

ខ្ញុំយោងទៅទំព័រ១៣ នៃឯកសារ E3/64 ERN ជាភាសាខ្មែរ 00328035 ទៅដល់ 37, ជាភាសាបារាំង ERN 00411703 ដល់ 04, ERN អង់គ្លេស 00334054។ ប្រសិនបើជាលោកសាក្សីមើលទៅចំណុចនេះ គឺថាមានការតាំងសំណួរមកលោក លោកនិយាយថា "លោក អៀង សារី មានកន្លែងរបស់គាត់ផ្ទាល់។ សួរថាតើមានការបកប្រែទូរលេខនៅកន្លែងរបស់លោកទេ?" លោកឆ្លើយថា "អៀង សារី មានក្រសួងការបរទេសរបស់គាត់។ ដូច្នេះ គាត់មានអ្នកបកប្រែសារទូរលេខរបស់គាត់ផ្ទាល់"។ បាទ ខ្ញុំសូមបញ្ចប់ត្រឹមនេះ។ នៅពេលដែលលោកនិយាយថា "ដូច្នេះគាត់មានអ្នកបកប្រែសារទូរលេខផ្ទាល់របស់គាត់" តើជាចម្លើយរបស់លោក ឬក៏ជាឃ្លាដែលអ្នកស៊ើបអង្កេតបានដាក់បញ្ចូលនៅទីនេះ?

**លោក នង សុផង់៖**

**ឆ៖** បាទ សារនេះជា -- ចម្លើយនេះគឺជាចម្លើយរបស់ខ្ញុំមែនបាទ មិនមែនរបស់គេបញ្ចូលអីនោះ

ទេបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលគាត់និយាយថា ដូច្នេះ គាត់មានអ្នកបកប្រែសារទូរលេខរបស់គាត់ផ្ទាល់ នៅពេលដែលលោកនិយាយដូច្នេះនេះ លោកមិនបានស្មានទេ មិនបានទាយទេ គឺជាការពិតដែលលោកដឹងនាពេលនោះតែម្តង។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ពេលហ្នឹងវាកន្លងហួសមកហើយ យូរមកហើយ។ ខ្ញុំមិនសូវប្រាកដលើបញ្ហា អ្នកណាដែលជាអ្នកបកប្រែទូរលេខគាត់ផ្ទាល់ទេ។ ក៏ប៉ុន្តែដំបូងឡើយ ខ្ញុំគិតថា អ្វីដែលកន្លែងខ្ញុំមិនបានទទួលខុសត្រូវ ហើយគាត់ចង់ទាក់ទងទៅខាងក្រៅប្រទេស គឺច្បាស់ជាមានទាំងអ្នកទូរលេខ មានទាំងអ្នកបកប្រែរបស់គាត់ផ្ទាល់ដែរហើយ មិនបាច់ឆ្លងមកខាងខ្ញុំទេ។ គាត់មានមធ្យោបាយរបស់គាត់ផ្សេងទៀតក៏មិនដឹង អានេះ បានថា ឈរលើសភាពការណ៍ជាក់ស្តែងនៅពេលនោះ។ អ៊ីចឹង សូមជម្រាបពេលនេះដែរគឺថា មុនដំបូង ខាងផ្នែកទាក់ទងទៅខាងក្រៅប្រទេសហ្នឹង រឿងទូរលេខហ្នឹងគឺ គាត់មានឆ្លងមកខាងក្រុមខ្ញុំមែន ដូចជាសារទូរលេខដែលមាន យ៉េម មានអីចុះហត្ថលេខាហ្នឹង។ តែក្រោយមក ខ្ញុំមិនចាំបានទេ ពីព្រោះខ្ញុំក៏បានបង្រៀនខាងទៅអ្នកការបរទេសដែរ ឲ្យគេចេះបកសារទូរលេខនោះបាទ។ អ៊ីចឹងបានមួយរយៈក្រោយមក ខ្ញុំក៏លែងបានទទួលការងារ ខាងទាក់ទងក្រៅប្រទេសនោះបាទ។

[១១:៣៣:២៩]

**ស៖** សូមអរគុណ យើងនឹងចូលទៅដល់ចំណុចនេះ។ លោកកំពុងតែប្រាប់យើងជាលើកទី១នេះថា ដោយសារតែលោកមិនបានឆ្លើយពីមុននោះទេ លោកបានកំពុងតែនិយាយថា លោកបានទៅក្រសួងការបរទេស ហើយធ្វើការអប់រំ និងបណ្តុះបណ្តាលនៅទីនោះផងដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំជាអ្នកជួយបណ្តុះបណ្តាលខាងក្រសួងការ អ៎! អ្នកបកប្រែខាងក្រសួងការបរទេសនៅទីស្តីការនាយករដ្ឋមន្ត្រីចាស់ បាទ ដោយតាមខ្ញុំចាំហ្នឹង។ អគារកោងអ៊ីចឹងមួយហ្នឹង។

**ស៖** យើងពិនិត្យតទៅមុខទៀត ដើម្បីបញ្ជាក់មើលថាតើលោកនិយាយអ្វីខ្លះ។ នៅពេលដែលគាត់ អៀង សារី នេះត្រូវបញ្ជូនសារនោះ គឺគាត់ឲ្យនីរសាររបស់គាត់យកទៅខាងវិទ្យុដោយផ្ទាល់ នៅស្ថានទូតអាមេរិកចាស់។ នៅទីនេះ លោកនិយាយថា “ខ្ញុំមិនដឹងច្បាស់នោះទេ ដោយសារតែវាមិនមែនជាក្របខ័ណ្ឌ ដែលខ្ញុំបានធ្វើ”។ តើលោកនៅតែរក្សាពាក្យសម្តីដែលលោកបាននិយាយនៅទីនេះដដែលដែរឬទេ?

[១១:៣៤:៥១]

**ឆ៖** បាទ ខ្ញុំនឹងរក្សាពាក្យសម្ដីនេះ ពីព្រោះខ្ញុំវាមិនច្បាស់មែន។ មិនដឹងជាគាត់ជូនទៅស្ថានទូតអាមេរិក ឬមួយក៏គាត់មានមធ្យោយបាយជូនទៅស្ថានទូត តាមរយៈស្ថានទូតណាផ្សេងទៀត ក៏ខ្ញុំមិនដឹង។ ដូច្នេះអ្វីដែលមិនច្បាស់ គឺខ្ញុំមិននិយាយ។

**ស៖** សូមអរគុណ។ បន្ទាប់មកលោកបន្តឡើងថា "ពេលដែលគេត្រូវបញ្ជូនសារទូរលេខទៅក្រៅប្រទេស តើគេប្រើវិទ្យុទាក់ទងនៅទូតអាមេរិកចាស់ដែរ ឬយ៉ាងណា?"។ លោកឆ្លើយថា "ប្រហែលជាមួយគ្នា"។ តើលោកឃើញទេចំណុចហ្នឹង ដែលលោកឆ្លើយដូច្នោះ?

**ឆ៖** បាទ ឃើញ។ អ៊ីចឹងហើយ បានជាខ្ញុំឲ្យលុបចេញថា ខ្ញុំមិនដឹងអ៊ីចឹងវិញទៅបាទ។

[១១:៣៥:៥១]

**ស៖** នេះជាចំណុចទាំងមូលដែលខ្ញុំចង់សួរដេញដោលហ្នឹងហើយ។ ដូច្នេះនៅពេលដែលលោកនិយាយថា ប្រហែលនោះ គឺលោកគ្រាន់តែជាការស្មានតែប៉ុណ្ណោះ។ លោកមិនដឹងការពិតនោះទេ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** នៅពេលនេះ យើងមើលការឆ្លើយរបស់លោកពាក់ព័ន្ធនឹងចំណុចនេះ នៅពេលដែលគេ -- នៅពេលសហព្រះរាជអាជ្ញាបានសួរលោក។ ខ្ញុំយោងលើសក្ខីកម្មរបស់លោកដែលបានឆ្លើយ នៅថ្ងៃ៣ ខែកញ្ញា ឆ្នាំ២០១២។ ទំព័រ១៤ ជាភាសាអង់គ្លេស ខ្មែរមានលេខ 00844181, បារាំង ក៏ទំព័រ១៤ ដូចគ្នា។ គេបានសួរលោក សហព្រះរាជអាជ្ញាបានសួរលោក គឺវាជាពាក្យដើមរបស់លោក "តើរឿងណាក្រៅពីហ្នឹងបាន តើលោកអាចប្រាប់ពីហ្នឹងបានឬទេ តើមានអ្នកណាដែលត្រូវធ្វើ មានភារកិច្ចអ្វីផ្សេងទៀតដែរ ក្រៅពីបកប្រែសារទូរលេខនោះ?" នៅពេលនេះយើងមើលចម្លើយដែលលោកបានឆ្លើយកាលពីប៉ុន្មានថ្ងៃមុននេះ "បាទ ចំពោះការទាក់ទងសារទូរលេខកន្លែងលោក អៀង សារី មិនបានចាំទាំងអស់ទេ។ យើងក៏មិនសូវដឹងថា លោកមានកន្លែងបកប្រែ ឬមួយក៏កន្លែងបញ្ជូនសារទូរលេខទីណាក៏ខ្ញុំភ្លាប់មិនបាន។ បាទ សូមអរគុណ។ ដូច្នេះយើងខ្ញុំនឹងអាចកែតម្រូវចម្លើយរបស់លោក លោកថា លោកមិនបានដឹងថា តើមានអង្គភាពបកប្រែទូរសារប្រចាំនៅក្រសួងការបរទេសដែរឬក៏អត់នោះទេ។ តើអ៊ីចឹងមែនដែរឬទេ? ឆ្លើយ ខ្ញុំមិនសូវច្បាស់រឿងនេះបាទ។ បានជាខ្ញុំមិនប៊ាននិយាយព្រោះអ្វីដែលមិនច្បាស់គឺខ្ញុំមិននិយាយទេ"។ តើលោកឃើញទេ សំណួរដែលបានគេសួរ ដែលបានគេសួរមកលោក ហើយលោកឃើញទេ ចម្លើយដែលលោកបានឆ្លើយកាលពីប៉ុន្មានថ្ងៃមុននេះ?

**ឆ៖** បាទ បានឃើញហើយបាទ។

[១១:៣៨:២១]

**ស៖** នៅពេលដែលលោកឆ្លើយដូច្នោះនោះ តើលោកឆ្លើយដោយស្មោះត្រង់ និងឆ្លើយតែការពិតដែរឬទេ?

**ឆ៖** បាទ នេះជាការពិតបាទ។

**ស៖** សូមអរគុណ។ នៅពេលនេះ យើងគិតថា ក្រោយមកទៀត គេសួរលោកថា នៅថ្ងៃទី០៤ ខែកញ្ញានោះ គឺគេក៏បានសួរលោកទំព័រអង់គ្លេស ជាភាសាប្រាំពីរ (ស៊ីក) ខ្មែរគឺ 00844480, បារាំង គឺ ៤១ ទៅដល់ ៤២ ទំព័រ៤១ ទៅដល់ ៤២។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសួរលោក គឺគេចាប់ផ្តើមសួរថា "សំណួររបស់ខ្ញុំបន្ទាប់នោះ ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់លោក ដែលលោកបានឆ្លើយនៅថ្ងៃទី២៩ ខែសីហា រហូតមកដល់ព្រឹកនេះ។ លោកលើកឡើងថា លោកធ្វើការទៅលើ ខាងសារទូរលេខនៅក្នុងប្រទេស។ ចុះសារទូរលេខឆ្លើយឆ្លងរវាងប្រទេសកម្ពុជា និងប្រទេសដទៃនោះ តើគេធ្វើឡើងដោយរបៀបណា? តើសារទូរលេខពីបរទេសនោះ បានបញ្ជូនមកគណៈ៨៧០ដែរឬទេ?"។ លោកឆ្លើយថា "ពាក់ព័ន្ធទៅនឹងសារទូរលេខពីក្រៅប្រទេស ខ្ញុំមិន -- ខ្ញុំក្តាប់មិនបានពេញលេញនោះទេ។ ដូច្នេះ ខ្ញុំមិនអាចផ្តល់ជាពន្លឺ ឬបង្ហាញឆ្លើយជូនលោកបានទេ។ សូមអរគុណ ចុះចំពោះក្រសួងការបរទេសវិញយ៉ាងម៉េចដែរ? ថាតើធ្លាប់ក្រសួងការបរទេស -- ក្រសួងការបរទេសធ្លាប់បញ្ជូនសារទៅគណៈ៨៧០ នោះតាមរយៈមន្ទីររបស់លោកដែរឬទេ?" លោកបានឆ្លើយថា "គណៈ៨៧០ នៅក្នុងទីក្រុងភ្នំពេញ គឺគណៈ៨៧០ មិនមានមន្ទីរទំនាក់ទំនងជាមួយនឹងក្រុមសារទូរលេខរបស់ខ្ញុំនោះទេ។ បើសិនជាអត់មាន តើពួកគេទាក់ទងដោយរបៀបណា? ការធ្វើទំនាក់ទំនងរវាងក្រសួងការបរទេស និងគណៈ៨៧០ នោះគឺធ្វើឡើងដោយរបៀបណា?" លោកបានឆ្លើយថា "ខ្ញុំមិនដឹងទេ"។ តើលោកនៅតែរក្សាពាក្យសម្តីនេះដដែល ដែលថាលោកមិនអាចក្តាប់ចំណុចនេះឲ្យបានពេញលេញនោះទេ ពាក់ព័ន្ធទៅនឹងសារទូរលេខផ្ញើពីបរទេសនោះ?

**ឆ៖** បាទ នៅរក្សាដដែលបាទ។

[១១:៤១:២២]

**ស៖** ដូច្នេះតើលោកធ្លាប់បានទៅក្រសួងការបរទេសដែរឬទេ?

**ឆ៖** បាទ ខ្ញុំដូចខ្ញុំជម្រាបអំមិញហ្នឹងគឺថា ខ្ញុំទៅពន្យល់ណែនាំពីរឿងការប្រើប្រាស់ឯកសារ

សម្ងាត់ម្តងនៅអតីតទីស្តីការនាយករដ្ឋមន្ត្រីចាស់ ដែលគេហៅថា ប-១ បាទ។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំបានឬទេ លោកទៅនោះក្នុងឆ្នាំណាដែរ ហើយលោកធ្វើឧទ្ទេសនាមបង្រៀនគេនោះទៅដល់អ្នកណាខ្លះដែរ?

**ឆ៖** ខ្ញុំបង្រៀនឈ្មោះលោក ប៊ុន បាទ។ លោកប៊ុន ហ្នឹងជាស្អីទេ ខ្ញុំអត់ដឹងទេ ប៉ុន្តែថា ក្រោយមកលោកត្រូវបានគេរៀបចំជាទូតមួយប្រចាំនៅបាងកក ហើយការបង្រៀនហ្នឹងមិនមានប្រើរយៈពេលយូរទេ តែកន្លះថ្ងៃទេបាទ។

**ស៖** ដូច្នេះការបង្រៀននេះមានរយៈពេលប៉ុន្មានដែរ ដើម្បីឲ្យគេនោះចេះធ្វើការបកប្រែសារទូរលេខនេះ? ដោយសារលោកបញ្ជាក់ហើយថា ការបកសារទូរលេខមានលក្ខណៈស្មុគស្មាញណាស់។

**ឆ៖** បានមានលក្ខណៈស្មុគស្មាញមែន។ ក៏ប៉ុន្តែគេមានមូលដ្ឋានចំណេះដឹងរបស់គេវាខ្ពស់ ដូច្នេះគាត់អាចប្រើពេលរយៈកាលខ្លីបាទ។

**ស៖** សូមឲ្យលោកឆ្លើយសំណួររបស់ខ្ញុំ តើលោកបង្រៀនគេនោះ រយៈពេលប៉ុន្មានដែរ ដើម្បីឲ្យគេចេះនោះ?

[១១:៤៣:៥២]

**ឆ៖** បាទ ខ្ញុំប្រាប់អំមិញហើយថា តែកន្លះថ្ងៃទេ តែពីម៉ោងប្រាំពីរដល់ម៉ោងដប់មួយ។ គេអាចក្តាប់បាន។

**ស៖** ប្រហែលជាមានការបកប្រែខ្វះខាតចំណុចហ្នឹង។ គឺលោកបានផ្តល់ឈ្មោះមកយើងខ្ញុំហើយ ដូច្នេះវាមានមូលដ្ឋានដែលយើងខ្ញុំចង់ផ្ទៀងផ្ទាត់។ ខ្ញុំចង់សួរលោក តើលោកចំណាយរយៈពេលប៉ុន្មាន ដើម្បីបណ្តុះបណ្តាលបុគ្គលម្នាក់នោះ ឲ្យមានជំនាញដូចលោកជាអ្នកបកប្រែសារនោះ ជាធម្មតាបាទ?

**ឆ៖** បាទ ៤ម៉ោង រយៈពេល៤ម៉ោង។

**ស៖** ដូច្នេះជាធម្មតានោះ គឺចំណាយពេលតែ៤ម៉ោងទេ ដើម្បីឲ្យបុគ្គលមួយរូបហ្នឹងចេះបង្រៀនចេះស្ទាត់ទៅលើដំណើរការនៃការបកប្រែសារទូរលេខ។ អ៊ីចឹងដែរឬទេបាទ?

**ឆ៖** បាទ អ៊ីចឹងមែនចំពោះដែល អ្នកដែលមានចំណេះដឹងខ្ពស់។

**ស៖** នៅពេលដែលលោកនិយាយថា បើសិនជាអ្នកនុ៎ងគាត់ចេះ គាត់មានមូលដ្ឋានបានន័យថា អ្នកហ្នឹងចេះអាន ចេះសរសេរមែនដែរឬទេ?

**ឆ៖** បាទ មិនមែនគ្រាន់តែចេះអានទេ ចេះសរសេរទេ ថែមទាំងគាត់ជានិស្សិតមហាវិទ្យាល័យមួយផង។

**ស៖** សូមអរគុណ។ នៅពេលនេះគឺនៅក្នុងចម្លើយរបស់លោក គឺលោកមិនបានលើកឡើងនូវក្នុងសង្ខេបនោះ ក៏បាន -- ក៏ឃើញមានរៀបចំឡើងដែរ ដែលក្នុងនោះលោកបានបញ្ជាក់ថា លោកដឹងតែពីបញ្ហាបច្ចេកទេសតែប៉ុណ្ណោះ។ តើត្រឹមត្រូវដែរឬទេ ចំណេះដឹងរបស់លោកនោះគឺលោកដឹងតែបញ្ហាបច្ចេកទេសទេ? បញ្ហាស៊ីជម្រៅ បញ្ហាសំខាន់ៗនោះលោកមិនដឹងទេ នេះគឺជាចម្លើយនៅក្នុងចម្លើយលើកទី១ របស់លោកដែលលោកបានឆ្លើយ គឺប្រហែលជានៅលោកឆ្លើយនៅម៉ោង ១១:១៥នាទី កាសែតថ្ងៃ១៨ កុម្ភៈ នោះ? លោកបាន លោកចាំទេថាលោកបានឆ្លើយអ៊ីចឹងប្រាប់អ្នកស៊ើបអង្កេតថា ចំណេះដឹងរបស់លោកនុំងគឺវាពាក់ព័ន្ធតែលោកចេះតែបញ្ហាបច្ចេកទេសតែប៉ុណ្ណោះ?

[១១:៤៧:០៤]

**ឆ៖** បាទ ចំណេះដឹងរបស់ខ្ញុំគឺខ្ញុំនិយាយអ៊ីចឹងមែន ខាងបច្ចេកទេស ខ្ញុំអាចយល់ដឹង ប៉ុន្តែកិច្ចការរាក់ជ្រៅអ្វីៗផ្សេងទៀត ខាងនយោបាយខាងអីខ្ញុំមិនមានចំណេះដឹងអីខ្ពស់ទេបាទ។

**ស៖** សូមអរគុណ។ យើងទៅមុខបន្តិចទៀត អ៊ីចឹងបានន័យថា លោកមិនដឹងអំពីបញ្ហានយោបាយនោះទេ នៅពេលដែលលោកវិភាគទៅលើឯកសារ ហើយផ្តល់ជាយោបល់ទៅលើឯកសារដែលបានបង្ហាញជូនលោក ថាតើគួរតែបកប្រែយ៉ាងម៉េចនោះ? សារទូរលេខទាំងអស់នោះ តើលោកធ្វើដោយរបៀបណាទៅ បកប្រែដោយរបៀបណាទៅ? បាទ ខ្ញុំ -- តើលោកធ្វើការងារហ្នឹងយ៉ាងម៉េចប្រសិនបើលោកដឹងមិនពិតប្រាកដ មិនមានប្រវត្តិ មិនមានការបណ្តុះបណ្តាលជាក់លាក់ផងនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១១:៤៨:២៦]

**លោក អាប់ឌុលឡាក់ ចារីក៖**

សំណួរនេះ គឺមិនច្បាស់នោះទេ។ មេធាវីសួរឲ្យ -- ភាគីបានសួរឲ្យសាក្សីនេះធ្វើការបញ្ជាក់វិភាគទៅលើសារទូរលេខ។ ដូច្នេះប្រសិនបើមានសារទូរលេខជាក់លាក់ណាមួយ ហេតុការណ៍ជាក់លាក់ណាមួយដែលពាក់ព័ន្ធនឹងការវិភាគរបស់សាក្សីនោះ គឺគួរតែលើកឲ្យបានច្បាស់លាស់ យើងឃើញ

មានការរៀបរាប់យ៉ាងច្រើនលម្អិតទៅលើសារទូរលេខ ក៏ប៉ុន្តែខ្ញុំគិតថា មេធាវីការពារក្តីគួរតែបញ្ជាក់ឲ្យបានជាក់លាក់ទៅលើចំណុចនេះ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំហៀបនឹងចូលទៅដល់ចំណុចនេះរួចទៅហើយ ហើយយើងខ្ញុំនឹងបន្តទៅមុខទៀត យើងឯកភាពគ្នាហើយថា យើងគួរតែបង្ហាញឧទាហរណ៍ជាក់លាក់ឲ្យសាក្សីមើល។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** នៅក្នុងសក្ខីកម្មរបស់លោក លោកសាក្សី សក្ខីកម្មបានបង្ហាញថា ខ្ញុំៗមិនចង់ពិនិត្យមើលចំណុចបច្ចេកទេសទាំងអស់នោះទេ ក៏ប៉ុន្តែនៅពេលណាមួយនោះ នៅពេលដែលលោកធ្វើការបកប្រែសារទូរលេខ លោកបកប្រែសារទូរលេខនោះហើយ គឺថាលោកផ្តល់ទៅដល់អ្នកនីរសារ តើអ៊ីចឹងដែរឬទេ?

[១១:៤៩:៤២]

**លោក នង សុផង់៖**

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** នៅពេលដែលលោកឲ្យទៅនីរសារ តើលោកធ្លាប់តាមដាននីរសារនោះមើលទៅ ថាតើនីរសារនុ៎ងបញ្ជូនយកទៅណាដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានតាមដានដែរ គឺថា គេមិនមានបញ្ជូនទៅណាផ្សេងចំពោះនីរសារដែលចេញពីកន្លែងខ្ញុំហ្នឹង មិនមានយកទៅកន្លែងណាផ្សេងក្រៅពីកន្លែងនៅមុខរោងយាមនៅក-១ នោះទេបាទ។

**ស៖** ដូច្នេះ ខ្ញុំនឹងសួរមួយដំណាក់កាលម្តងមួយដំណាក់កាលម្តង។ នីរសារហ្នឹងយកទៅដាក់កន្លែងរោងយាម ហើយទុកឲ្យបុគ្គលដែលយាមនៅទីនោះ។ នេះគឺអ្វីដែលលោកយល់ហេតុការណ៍ដែលគេធ្វើអ៊ីចឹងនៅពេលនោះ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គេយកទៅប្រគល់ជូនគេហើយ ខាងអ្នកយាមហ្នឹងគេយកឡើងទៅភ្លាមបាទ។

**ស៖** ខ្ញុំនឹងសួរមួយដំណាក់កាលម្តងមួយដំណាក់កាលម្តង។ ដូច្នេះ ប្រសិនបើនីរសារ សារទូរលេខ ហ្នឹងធ្លាប់ដែលចូលទៅដល់មន្ទីរ ក-១ នោះតែម្តងដែរឬទេ?

**ឆ៖** នីរសារខ្ញុំមិនមានសិទ្ធិចូលផ្ទាល់ទេបាទ ទៅខាងក្នុងនុះ។

[១១:៥១:៤៨]

**ស៖** តើលោកនោះមានសិទ្ធិចូលទេ? ហើយបើសិនជាលោកមានសិទ្ធិចូលមន្ទីរក-១នោះ តើលោកចូលមន្ទីរក-១ នោះញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទខ្ញុំមានសិទ្ធិចូលដែរ ប៉ុន្តែណាដែលលោក ប៊ុន កោះហៅទៅប្រជុំតែប៉ុណ្ណោះ។

**ស៖** សូមអរគុណ។ តើលោកធ្លាប់ចូលបរិវេណ ក-១ ជាមួយនីរសាររបស់លោក ហើយលោកដែលចូលទៅមន្ទីរបរិវេណក-១ ជាមួយនឹងសារទូរលេខរបស់លោក ដើម្បីយកទៅឱ្យគេផ្ទាល់ដែរឬទេ?

**ឆ៖** បាទ វាមានអ៊ីចឹងដែរ។ បើពេលខ្ញុំបកសាររួចហើយ ហើយគាត់ចួនពេលហ្នឹងគេកោះហៅខ្ញុំទៅប្រជុំ ខ្ញុំក៏ពុំបាច់ប្រើនីរសារទេ គឺខ្ញុំយកទៅជូនខាង ប៊ុន ផ្ទាល់តែម្តង ផ្ទាល់ដៃដែរ។

**ស៖** លោកហុចផ្ទាល់ទៅឱ្យ ប៊ុន ក៏ប៉ុន្តែលោកមិនហុចទៅឱ្យបុគ្គលណាមួយផ្ទាល់ដែរគេបញ្ជូនសារនេះទៅឱ្យនោះទេ ត្រឹមតែហុចឱ្យ ប៊ុន តែប៉ុណ្ណោះ លោកត្រឹមតែហុចឱ្យ ប៊ុន តែប៉ុណ្ណោះ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ប៊ុន ពីព្រោះជាមេរបស់ខ្ញុំ ខ្ញុំមិនហុចទៅអ្នកណាផ្សេងពីហ្នឹងទេបាទ។

[១១:៥៣:៤២]

**ស៖** សូមអរគុណ។ តើលោកអាចរៀបរាប់ទីតាំងមន្ទីរ ក-១ បានដែរឬទេ? តើមានអគារប៉ុន្មាននៅក្នុងមន្ទីរ ក-១ ហ្នឹង?

**ឆ៖** បាទ ក្នុងមន្ទីរ ក-១ នេះ កាលសម័យនោះ គឺមានតែអគារខ្ពស់ៗពីរតែប៉ុណ្ណោះ។

**ស៖** ចុះកន្លែង ប៊ុន ធ្វើការ គឺគាត់ធ្វើការនៅក្នុងអគារតូចមួយ ឬក៏នៅកន្លែងតូចមួយ ឬក៏យ៉ាងម៉េច? ឬក៏ ប៊ុន នេះ ធ្វើការនៅក្នុងអគារខ្ពស់មួយក្នុងចំណោមអគារខ្ពស់ទាំងពីរនោះ?

**ឆ៖** បាទ ប៊ុន ហ្នឹងធ្វើការនៅជាន់ទីពីរ ហើយផ្នែកខាងជ្រុងគេបង្អស់ បន្ទាប់ពីទ្វារចូលទៅ គឺនៅអាជាន់ទីពីរហ្នឹងហើយដែល ប៊ុន ធ្វើការ។

**ស៖** លោកប្រាប់ហើយថា មានអគារខ្ពស់ពីរ តើអគារមួយណាដែរកន្លែងគាត់?

**ឆ៖** បាទ គឺអគារមួយដែលចូលពីផ្លូវចូលទៅ គឺអគារមួយដែលបណ្តោយថ្ងៃបាទ។ អគារបណ្តោយថ្ងៃមួយ។

**ស៖** នេះជាចម្លើយរបស់លោក សូមអរគុណ។ លោកទំនងជាបង្ហាញឆ្លើយប្រាប់យើងថា នៅពេលដែលនីរសារ -- នៅពេលដែលសារនោះ នីរសារយកសារទូរលេខទៅនោះ នីរសារនោះគឺដាក់ទៅឱ្យអ្នកយាម ហើយនៅពេលដែលគេបញ្ជូនពីក-១ មកក៏គេនីរសាររបស់គេទៅយកពីកន្លែងរោងយាម

ហ្នឹងដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** អត់អ៊ីចឹងទេ។ ពេលដែលគេចង់ឲ្យខាងខ្ញុំបកប្រែ គេក៏អាចពេលខ្លះសារខ្លីៗ គេហៅតាមទូរស័ព្ទ បើសារវែងៗ ក៏គេឲ្យអ្នករោងយាមទៅឲ្យកន្លែងខ្ញុំដែរ បាទ។ គឺមានមធ្យោបាយច្រើនណាស់សម្រាប់យកទៅកន្លែងខ្ញុំនោះ មិនមែនគោលការណ៍ងាប់ក្រឡា។ ជួនណា លោកទៅផ្ទាល់ក៏មាន លោក ប៊ុន ហ្នឹងយកទៅឲ្យខ្ញុំផ្ទាល់ ក៏មានដែរ។

[១១:៥៧:១៨]

**ស៖** ប្រសិនបើខ្ញុំយល់ចំណុចនេះ គឺការងាររបស់លោក សារដែលបញ្ជូនទៅខាងក្រៅមិនយកមកផ្ទាល់នោះ គឺបានន័យថា គឺថាសារទាំងឡាយដែលវាមានលក្ខណៈមិនសម្ងាត់ទេ ទើបគេបញ្ជូនចេញទៅក្រៅបាន មិនមែនយកមកផ្ទាល់។ តើអ៊ីចឹងដែរឬទេ អ្វីដែលខ្ញុំយល់នេះ?

**ឆ៖** បាទ បើសារណាដែលមិនប្រញាប់ហ្នឹង ក៏គេអាចជូនតាមឲ្យនីរសារមក ក-១ ហ្នឹងយកមកផ្ទាល់បាន។ ប៉ុន្តែអារឿងអ្វីដែលប្រញាប់ គេនឹងយកមកផ្ទាល់ខ្លួនគេ ហើយនឹងប្រាប់ខ្ញុំថា ឲ្យដាក់សញ្ញា អាសញ្ញា ដេៗ ហ្នឹងឲ្យនៅលើសារហ្នឹងផង ព្រោះសារហ្នឹងវាត្រូវឆ្លើយឆ្លងគ្នាបាទ។ គេមកណែនាំបន្ថែមផ្ទាល់ទៀត អាហ្នឹងពេលខ្លះដែលវាចាំបាច់។

**ស៖** ប៊ុន គឺជាមេរបស់លោក មេផ្ទាល់របស់លោក។ តើ ប៊ុន ធ្លាប់ប្រាប់លោកអំពីការងារសកម្មភាពរបស់គាត់ដែរឬទេ? គឺការងារសកម្មភាពរបស់ ប៊ុន នៅក្នុងមន្ទីរ ក-១ គាត់ធ្វើអី? និយាយជាមួយអ្នកណាខ្លះ? ហើយគាត់ដឹងព័ត៌មានអ្វីខ្លះពីខាងក្នុង? តើ ប៊ុន នោះធ្លាប់លាតត្រដាងព័ត៌មានទាំងនេះជូនលោកនៅពេលណាមួយដែរឬទេ?

[១១:៥៩:០៤]

**ឆ៖** បាទ មិនមានការលាតត្រដាងអ្វីទេបាទ។

**ស៖** តើ ប៊ុន ធ្លាប់ប្រាប់លោកទេ ថា ប៊ុន ហ្នឹងជួបប្រជុំជាមួយអ្នកណាខ្លះនៅមន្ទីរ ក-១? ហើយគាត់ហ្នឹងទទួលការណែនាំប្រភេទណាខ្លះ? ហើយ ក-១ ដំណើរការទៅយ៉ាងម៉េច? ដោយសារតែលោកបានប្រាប់យើងហើយថា គេគោលការណ៍រក្សាការសម្ងាត់ គឺខ្ពស់ណាស់។

**ឆ៖** បាទ គឺគេមានគោលការណ៍សម្ងាត់ណាស់នៅក្នុង ណែនាំមកលោក អ៎! មកអ្នកដែលធ្វើការងារសម្ងាត់នោះ។ គោលការណ៍បីយ៉ាង គឺអ្វីដែលត្រូវនិយាយ អ្វីដែលមិនត្រូវនិយាយ គឺមិនត្រូវនិយាយ។ អ្វីដែលមិនត្រូវសួរ គឺមិនត្រូវសួរ។ ដូច្នេះគឺថា មិនដឹង មិនឮ មិនឃើញ និងមិននិយាយបាទ

នូវអ្វីទាំងឡាយណាដែរជាការងារសម្ងាត់។

**ស៖** តាមបទពិសោធន៍ដែលលោកធ្លាប់ឆ្លងកាត់ធ្វើការងារជាមួយនឹង ប៉ុន តើពួកគេទាំងអស់នោះ គឺគោរពតាមគោលការណ៍ហ្នឹងដែរឬទេ? ជាពិសេសនៅពេលដែលធ្វើការជាមួយនោះ គាត់ធ្វើការជាមួយលោក តើគាត់គោរពគោលការណ៍ទាំងនេះដែរឬទេ?

**ឆ៖** បាទ គាត់ពិតជាបានធ្វើគំរូខ្ញុំមែន។ ព្រោះគាត់មិនបានិយាយអ្វី ដែលគាត់បានជួប ឬមួយក៏ការសម្ងាត់អ្វីដែលជាការកិច្ចការសម្ងាត់ផ្ទៃក្នុងនៅក-១ គាត់មិនដែលបែកធ្លាយនិយាយប្រាប់ខ្ញុំទេបាទ។

[១២:០១:២៦]

**ស៖** សំណួរចុងក្រោយមុនពេលដែលយើងសម្រាកអាហារថ្ងៃត្រង់។ លោកបាននិយាយហើយថាបុគ្គលនេះ គឺលោកធ្លាប់ធ្វើការជាមួយគាត់នោះ នៅប-២០ មុនឆ្នាំ១៩៧៥ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ពុំមែនអ៊ីចឹងទេ គឺខ្ញុំធ្វើការជាមួយគាត់តាំងពីចុងឆ្នាំ៧៣ មកម្ល៉េះ ហើយក៏មិនមែននៅប-២០ ទេ គឺទាល់តែបែកគ្នាពី ប៉ុន ហ្នឹង គឺឆ្នាំ ចុងឆ្នាំ៧៤ ហើយបានខ្ញុំរើកន្លែងពីក្នុងព្រៃម៉ាគីហ្នឹងមកនៅប-២០ នោះ។ ដូច្នេះ អំឡុងដែលខ្ញុំធ្វើការជាមួយ ប៉ុន ហ្នឹងគឺចុង៧៣ ដល់ចុង៧៤ គឺបានរស់នៅជាមួយគ្នា១ឆ្នាំដែរ ទម្រាំបែកគ្នាទៅធ្វើការរៀងៗខ្លួន។ គាត់ទៅខាងលិចភ្នំពេញទៅ ឯខ្ញុំគឺ -- រើកន្លែងមកកន្លែងព្រៃចេកមួយនៅប-២០ ហ្នឹងបាទ។

**ស៖** គឺប-២០ នោះ គឺកន្លែងដែលលោកធ្វើការ ដែលនៅទីនោះគឺគេបែងចែកការងារជាបីផ្នែក ទី១ គឺកន្លែងបកប្រែសារទូរលេខ គឺមានទីតាំងដោយឡែក មានបុគ្គលដោយឡែក ធ្វើការងារបកប្រែសារទូរលេខ និងផ្សព្វផ្សាយសារទូរលេខនោះ គឺអ៊ីចឹងដែរឬទេ?

[១២:០៣:២៨]

**ឆ៖** បាទ អ៊ីចឹងមែន។ គឺមានទីតាំងដោយឡែកៗពីគ្នា មិនដែលស្គាល់មុខគ្នាទេបាទ គឺមានកន្លែងទូរលេខខ្ញុំ កន្លែងវេបញ្ជូនសារទូរលេខ ទាក់ទងទូរលេខក៏នៅផ្សេងគ្នា ហើយមានអង្គភាពមួយទៀតដែលពេលដែលខ្ញុំមានដំណឹងពីសមរភូមិអី ក៏ខ្ញុំបញ្ជូនឲ្យគេរៀបចំផ្សាយ ក៏គេនៅដោយឡែក។ អ៊ីចឹងគឺខ្ញុំបានជម្រាបច្បាស់ហើយនៅក្នុងចម្លើយរបស់ខ្ញុំហ្នឹង គឺថាមិនដែលឃើញមុខគ្នា ទីតាំងវាដាច់ពីគ្នា មិនស្គាល់គ្នាទេ។

**ស៖** ការដែលថាមិនដែលឃើញមុខ ធ្លាប់ឃើញមុខគ្នា នៅដាច់ពីគ្នានេះ គឺដោយគេគោរពតាមគោលការណ៍រក្សាការសម្ងាត់នោះហើយ អ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គេរៀបចំដូច្នេះ គឺវាជាគោលការណ៍សម្ងាត់បាទ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំដឹងថានៅពេលនេះម៉ោងដប់ពីរប្រាំនាទីរួចទៅហើយ។ ដូច្នេះវាជាពេលសមរម្យមួយ ប្រហែលខ្ញុំគិតថាយើងអាចឈប់សម្រាកសម្រាប់អាហារថ្ងៃត្រង់។

សូមអរគុណ។

[១២:០៤:៤៩]

**ប្រធានអង្គជំនុំ៖**

អរគុណៗសាក្សី។

បាទឥឡូវនេះដល់ពេលសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី នៅរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលដល់កន្លែងសម្រាក នៅកន្លែងបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាកពិសាត្រង់ថ្ងៃ ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ វិញនៅវេលាម៉ោងកំណត់ គឺម៉ោងមួយសាមសិបនាទីរសៀលនេះ។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

[១២:០៥:២៩]

**លោក អេនឌ្រូ អ៊ីអាន់ហ្វ្រ៊ី៖**

ខ្ញុំសូមលើកឡើងខ្លីទេ លោកប្រធាន មុនឈប់សម្រាកពិសាបាយថ្ងៃត្រង់។ ទី១ ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ខ្ញុំសូមលើកឡើងជាកំណត់ត្រា ខ្ញុំលើកឡើងទៅឯកសារ D375/1/8 គឺជាសេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធទៅនឹងសំណើសុំឲ្យធ្វើការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងលោក នួន ជា។ សំណើសុំទាំងអស់នេះ ទាក់ទងទៅនឹងការកោះហៅសាក្សីឡើងវិញ នេះគឺជាបញ្ហាដែលយើងបានពិភាក្សាគ្នាពីព្រឹកមិញនេះ។ ហើយសំណើសុំទាំងនេះ ក៏ត្រូវបានអង្គបុរេច្រានចោល ដោយហេតុផលមួយចំនួន យើងខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា ហេតុអ្វីបានជាអង្គបុរេជំនុំជម្រះច្រានចោលនេះ។ សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត គឺថាសហចៅក្រមស៊ើបអង្កេត

បានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងត្រឹមត្រូវ ក្នុងការបដិសេធសំណើសុំឲ្យបើកកិច្ចស៊ើបសួរឡើងវិញ។ ប៉ុន្តែនៅក្នុងដំណាក់កាលនៃអង្គជំនុំជម្រះសាលាដំបូង គឺថាមេធាវីការពារក្តីអាចជំទាស់តវ៉ាទៅលើភស្តុតាងទាំងអស់បាន។ អាចប្រើប្រាស់ឱកាស គ្រប់ឱកាសទាំងអស់ ដើម្បីធ្វើការជំទាស់តវ៉ា ដោយរួមទាំងស្នើសុំឲ្យអង្គបុរេ -- អង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សីឡើងវិញ ប៉ុន្តែដោយសារតែសហចៅក្រមស៊ើបអង្កេតបដិសេធមិនព្រមកោះហៅសាក្សី ដើម្បីមកធ្វើការសាកសួរឡើងវិញនោះទេ។ ចំណុចដែលសហចៅក្រមស៊ើបអង្កេតលើកឡើង ហើយដែលយល់ស្រប តាមដោយអង្គបុរេជំនុំជម្រះនោះ ដូច្នេះនៅក្នុងដំណាក់កាលនៃអង្គជំនុំជម្រះសាលាដំបូងនេះ គឺជាឱកាសមួយដែលអនុញ្ញាតឲ្យមេធាវីការពារក្តីជំទាស់តវ៉ាទៅលើភាពគួរឲ្យជឿជាក់បាន។ នេះគឺជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធទៅនឹងសំណើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរឡើងវិញនេះ។

[១២:០៧:៥០]

នេះគឺជាមូលដ្ឋានមួយដែលយើងខ្ញុំបានលើកឡើងនៅក្នុងចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ហើយចំណុចចុងក្រោយ ទាក់ទងទៅសំណួររបស់លោកចៅក្រម ឡាវ៉ែន ដែលថា ហេតុអីក៏មិនលើកឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត។ យើងខ្ញុំបានដាក់សំណើសុំឲ្យបើកកិច្ចស៊ើបសួរឡើងវិញ ១៥ សំណើសុំឯណោះ ខ្ញុំមិនអាចរៀបរាប់សំណើសុំទាំង២៥នេះបានទេ។ នេះគឺជាបញ្ហាមួយដែលត្រូវការពិភាក្សាគ្នាបន្តទៀត ខ្ញុំគ្រាន់តែជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ ឯពាក្យថា "ស្មាន"ៗ នោះវិញ ជានិយមន័យជាអង់គ្លេសនោះ គឺពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសន្និដ្ឋានណាមួយដែលមិនមានព័ត៌មាន ឬក៏ភស្តុតាងគ្រប់គ្រាន់ យកមកធ្វើជាសេចក្តីសន្និដ្ឋាន។ នេះគឺជានិយមន័យមួយដែលខ្ញុំយល់ជាភាសាអង់គ្លេស។ វាមានការស្មានៗ ដោយហេតុផល ក៏ប៉ុន្តែពាក្យនេះ គឺមិនមានន័យអ្វី ដូចដែលលោកស្រីចៅក្រម ខាតវ៉ាយថ៍ លើកឡើងនោះទេ។ ហើយយើងខ្ញុំចុងក្រោយយើងខ្ញុំទើបទទួលដំណឹងថា កូនក្តីរបស់យើងខ្ញុំមានការឈឺឆ្អឹងខ្នង មានឈឺក្បាល មិនអាចផ្តង់អារម្មណ៍។ ដូច្នេះ ស្នើសុំទៅតាមដានដំណើរការនីតិវិធីនៅបន្ទប់ដែលមានបំពាក់ប្រព័ន្ធសោតទស្សន៍នៅខាងក្រោមនេះ។ សូមអរគុណលោកប្រធាន។

[១២:០៩:២៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវី

ការពារក្ដីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលនេះ ដោយបញ្ជាមូលហេតុសុខភាព មិនអាចអង្គុយ តាមដានដោយផ្ទាល់នៅក្នុងសវនាការនេះបាន។ អង្គជំនុំជម្រះយល់ និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ នៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះ តម្រូវឲ្យក្រុមមេធាវីការពារក្ដី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការសវនាការ ដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដែលធ្វើឡើងដោយលោក នួន ជា គឺដោយមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃជាក់ច្បាស់របស់លោក នួន ជា។

[១២:១០:១៣]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលដំណើរការសវនាការនៅរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់ អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១០ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣២:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ហើយសូមជម្រាបសួរអស់លោក លោកស្រីចៅក្រម ព្រមទាំងភាគី ហើយសូមជម្រាបសួរដល់ប្រិយមិត្តទាំងអស់។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី ខ្ញុំសូមជម្រាបសួរ។ យើងសូមចាប់ផ្តើមបន្តពីអ្វីដែលយើងបានផ្អាកមុនពេលនេះ។ ខ្ញុំគិតថា យើងកំពុងតែនិយាយអំពី ប៊ុន គឺនៅពេលដែលយើង -- មុនពេលយើងឈប់សម្រាកអាហារថ្ងៃត្រង់ ខ្ញុំចាំថា សក្ខីកម្មរបស់លោកបានបញ្ជាក់ថា ប៊ុន ហើយនិង ថេរ ហើយពិសេសគឺ ប៊ុន គឺមានអំណាចផ្តាច់មុខក្នុងការបន្ថែម នៅក្នុងការសរសេរថាតើអ្នកណាខ្លះដែលត្រូវចម្លងជូន បានន័យថា ឯកសារចម្លងជូនសម្រាប់ការបកប្រែទូរសារនៅ ក-១។ តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ អឺចឹងមែនបាទ។

[១៣:៣៣:៣៤]

**ស៖** ហើយបើតាមដែលខ្ញុំយល់ ប្រសិនបើខ្ញុំយល់សក្ខីកម្មរបស់លោកមិនខុសទេ តាមចម្លើយទី១ របស់លោកចំពោះសហចៅក្រមស៊ើបអង្កេត គឺនិយាយថា “ប៊ុន មិនមានសិទ្ធិអំណាចបែបនេះទេ”។ គឺ ប៉ង់ ដែលជាប្រធានមន្ទីរ ៨៧០ គឺបុគ្គលដែលមានតួនាទីគ្រប់គ្រង ដែលជាអ្នកទទួលខុសត្រូវនៅមន្ទីរ ៨៧០ និងមន្ទីរមួយចំនួនទៀត តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ព្រោះ ប៉ង់ អឺចឹងមែន។ បើ ប៊ុន លោកនិយាយដំបូងថា ប៊ុន អាហ្នឹងខ្ញុំយល់ស្រប។ ដល់ថា ប៉ង់ គឺ ប៉ង់ មិនមានសិទ្ធិក្នុងការត្រួតពិនិត្យដាក់ចម្លងជូនអីទេបាទ។

**ស៖** ខ្ញុំចង់សួរលោកថា តើលោកដឹងអំពីបញ្ហាហ្នឹងដោយរបៀបណា? តើលោកផ្អែកទៅលើមូលដ្ឋានអ្វីដែលលោកបានិយាយ ដូចដែលលោកឆ្លើយប្រាប់ខ្ញុំបែបនេះ?

**ឆ៖** មូលដ្ឋានគឺ ជាទម្លាប់ការងាររបស់ខ្ញុំតាំងពីកាលខ្ញុំនៅក្នុងព្រៃមក គឺតាំងពីដើមមក គឺមិនដែលឃើញ ប៉ង់ ហ្នឹងមកត្រួតពិនិត្យការងារខ្ញុំ ហើយក៏មិនមានមកជ្រៀតជ្រែក ជាការងារបច្ចេកទេសក្តី ជាការពិនិត្យផ្ទៀងផ្ទាត់សារអី គឺគ្មានតួនាទីមកត្រួតត្រាអីទេបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមឲ្យលោកបញ្ជាក់បន្តិច ថាតើខ្ញុំយល់ខុស ឬត្រូវ គឺលោកធ្វើការសន្និដ្ឋានថា តាំងពីនៅក្នុងព្រៃ ប៉ង់ មិនមកជ្រៀតជ្រែកនៅក្នុងការងាររបស់លោកទេ។ ប៉ង់ ហ្នឹងគឺជាប្រធានមន្ទីរ៨៧០ គឺ ប៉ង់ នេះមិនមានសិទ្ធិសម្រេចជំនួសប៉ុន ដែល ប៉ុន ហ្នឹងគឺជាកូនចៅរបស់គាត់។ បានន័យថា ប៉ុន នៅក្រោម ប៉ង់ ប៉ុន្តែ ប៉ង់ មិនមានសិទ្ធិសម្រេចផ្សេងក្រៅពី ប៉ុន។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៣:៣៦:៣៦]

**ឆ៖** បាទ អ៊ីចឹងមែន ពីព្រោះ ប៉ង់ មានសិទ្ធិពីលើ ប៉ុន តែខាងការប្រជុំរៀនសូត្រនយោបាយ ហៅថាគ្រប់គ្រងនយោបាយ ឯការងារបច្ចេកទេសសម្ងាត់ ប៉ង់ មិនមានសិទ្ធិមកលូកលាន់លើការងារហ្នឹងទេបាទ។

**ស៖** សូមអរគុណ។ តាមដែលលោកដឹង គឺពាក់ព័ន្ធទៅនឹងបញ្ហាបច្ចេកទេស ការងារនេះវារួមបញ្ចូលបន្ថែមទៅលើការបកប្រែ និងការបំភ័ន្តអក្ខរ:ផង ថាតើអ្នកណាគឺជាគោលដៅដែលគេត្រូវធ្វើសារទូរលេខនោះទៅឲ្យ?

**ឆ៖** បាទ សូមធ្វើសំណួរម្តងទៀត ឲ្យច្បាស់លាស់បាទ។

**ស៖** ឥឡូវនេះយើងនិយាយអំពីសារទូរលេខដែលទៅ ក-១។ ខ្ញុំនិយាយអំពីទូរលេខដែលទៅ ក-១។ បើតាមខ្ញុំយល់ លោកបាននិយាយថា ជាបញ្ហាបច្ចេកទេស គឺការងាររបស់ ប៉ុន គឺថា ប៉ុន គាត់មានសិទ្ធិអំណាចដែលថាត្រូវដាក់ចម្លងជូនទៅអ្នកណាៗ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។ ការដាក់ចម្លងជូន គឺគាត់មានសិទ្ធិអំណាចដាក់បានបាទ។

**ស៖** ឥឡូវនេះយើងនិយាយអំពីបញ្ហានេះបន្តិច។ ក្រៅពីសរសេរចម្លងជូននោះ តើលោកដឹងដែរឬទេ ថា ប៉ុន មានសិទ្ធិដើម្បីបញ្ជាក់ថា ឯកសារនោះពិតៗប្រាកដជាបញ្ជូនទៅដល់ដៃបុគ្គលទាំងអស់ដែលគាត់ដាក់ថាចម្លងជូនហ្នឹង។ តើពិតមែនដែរឬទេ?

[១៣:៣៨:១១]

**ឆ៖** បាទ ការចាត់ចែងរបស់ ប៉ុន ថាពេលដែលគាត់ដាក់ចម្លងនោះ ហើយទូរលេខហ្នឹងពិតជាបានដល់អ្នកដែលត្រូវទទួលហ្នឹង ខ្ញុំមិនដឹងដែរ។ មិនដឹងជាបានដល់ ឬមិនដល់ ពីព្រោះគេនៅខាងក្នុង គេអ្នកចាត់ចែង។

**ស៖** សូមអរគុណ។ ចំណុចហ្នឹងហើយ គឺជាចំណុចដែលខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ ដើម្បីឲ្យខ្ញុំ

យល់ច្បាស់ទាំងអស់គ្នា។ អ្វីដែលលោកចង់ប្រាប់យើង គឺថាក្នុងមុខងារបច្ចេកទេស គឺគាត់មាន -- គឺគាត់ -- គេចាត់តាំងឲ្យគាត់ជាអ្នកសម្រេចថា អ្នកត្រូវបញ្ជូន អ្នកណាត្រូវចម្លងជូន។ តើលោកយល់ស្របបែបនេះជាមួយខ្ញុំដែរឬទេ?

**ផ៖** បាទ យល់ស្របអ៊ីចឹងមែន គឺថា -- ហើយគាត់មានសិទ្ធិថា មិនត្រូវចម្លងជូនអំណាខ្លះក្នុងកាលៈទេសៈណាមួយ គឺគាត់មានសិទ្ធិអ៊ីចឹងទៀតបាទ។ គាត់ដឹងអ៊ីចឹងទៀតថា អំណាគាត់មិននៅ មិនបាច់ចម្លងជូនអាំហ្នឹងទេ។ គាត់ដឹងអ៊ីចឹងទៀត។

**សៈ** សូមអរគុណ។ ដូច្នេះ គាត់មានសិទ្ធិអំណាចលើស ប៉ុល ពត ទៅទៀតក្នុងការសម្រេចថា តើត្រូវដាក់អ្នកណា ចម្លងជូនអ្នកណា នៅ អ្នកណាមិននៅ ត្រូវចម្លងជូនអ្នកណាខ្លះ មិនចម្លងជូនអ្នកណាខ្លះ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៣:៤១:០១]

**ផ៖** បាទ ព្រោះខាងក្នុងគាត់ដឹងហើយ អ្នកណាដែលនៅក្នុងនោះ អ្នកណាទៅធ្វើការនៅខាងក្រៅ គាត់អាចដឹងកិច្ចការច្រើននៅខាងក្នុង។ អ៊ីចឹងគាត់ក៏មានសិទ្ធិអំណាចចាត់ចែង តែក៏មិនមែនមានសិទ្ធិធំជាង ប៉ុល ពត នោះទេបាទ។

**សៈ** មុនពេលយើងឈប់សម្រាកអាហារថ្ងៃត្រង់ លោកបានប្រាប់យើងថា ប៉ុន គោរពទៅតាមគោលការណ៍រក្សាការសម្ងាត់។ លោកបានប្រាប់យើងបែបនេះ គឺថាគាត់មិនបានជម្រាបប្រាប់អ្នកណាម្នាក់អំពីសកម្មភាពផ្ទៃក្នុងនៅក-១ នោះទេ។ តើៗខ្ញុំនិយាយអ៊ីចឹងច្បាស់ដែរឬទេ?

**ផ៖** បាទ អ៊ីចឹងមែន គាត់អនុវត្តគោលការណ៍ហ្នឹងប្អូនយ៉ាងបានហ្មត់ចត់។

**សៈ** នៅពេលដែលលោកមកទីនេះ លោកមិនអាចនិយាយឲ្យច្បាស់ប្រាកដប្រជាថា តើ ប៉ុន ធ្វើអ្វី និងមិនធ្វើអ្វី នៅក្នុងបរិវេណនៃក-១ តើអ៊ីចឹងមែនទេ?

**ផ៖** បាទ មិនមែនថាមិនធ្វើអ្វីក្នុងបរិវេណក-១ នោះទេ គឺថាគាត់មិននិយាយអ្វី មិនធ្វើអ្វីឲ្យបែកការណ៍សម្ងាត់អំពីបញ្ហាផ្ទៃក្នុងខាងក្នុងឲ្យព្រួសខ្ចាយទៅខាងក្រៅនោះទេបាទ។ មិនមែនបានន័យថាមិនៗធ្វើអីសោះ អីរឿងនៅក្នុងក-១ ទេ គឺយើងនិយាយពីរឿងកិច្ចការសម្ងាត់បាទ។

[១៣:៤៣:២៥]

**សៈ** ពិតហើយ ដូច្នេះនៅពេលដែលលោកមកទីនេះ មកក្នុងសាលសវនាការនេះ តើលោកធ្វើការសន្មត ឬក៏មិនសន្មតទេ? តើលោកបានធ្វើការស្មានដែរឬទេ នៅពេលដែលលោកជម្រាបមកយើង

អំពីអ្វីដែលកើតឡើងចំពោះឯកសារនៅពេលដែល ប៉ុន បានទទួលហ្នឹង? តើអ្វីដែលលោកជម្រាបយើងហ្នឹងជាការសន្មត ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ មិនមែនជាការសន្មតទេ។ គឺជាការជាក់ស្តែងអ្វីដែលខ្ញុំមានបទពិសោធន៍ធ្លាប់បានធ្វើកិច្ចការទំនាក់ទំនងជាច្រើនឆ្នាំជាមួយ ប៉ុន នោះ។

**ស៖** ឥឡូវយើងត្រូវបន្តទៅមុខទៀត។ ខ្ញុំគិតថា លោកបានប្រាប់យើងថា លោកអត់មានការទំនាក់ទំនង ឬក៏គ្មានបទពិសោធន៍នៅក្នុងការទំនាក់ទំនងជាមួយ ប៉ុន ពាក់ព័ន្ធទៅនឹងការងាររបស់គាត់នៅក-១ នោះទេ លោកទើបប្រាប់យើងបែបនេះ?

**ឆ៖** បាទ បទពិសោធន៍ហ្នឹង គឺខ្ញុំចង់និយាយថាការដែលគាត់ -- អាកប្បកិរិយាគាត់មិននិយាយស្តីអ្វីពីការសម្ងាត់ ពីក្នុងទៅក្រៅ ពីក្រៅទៅក្នុងហ្នឹងទេបាទ។ អានេះគឺបទពិសោធន៍ហ្នឹងទេ ដែលៗជាទម្លាប់ការងាររបស់គាត់ហ្នឹង។ អ៊ីចឹងគឺការយល់ច្រឡំខុសគ្នាយ៉ាងហ្នឹងហើយ ដែលបាននាំឱ្យមានបញ្ហា។

**ស៖** ខ្ញុំសូមអភ័យទោស។ ដូច្នេះឥឡូវយើងបន្តទៅមុខទៀត ដើម្បីឱ្យយើងពិចារណាបន្ត។ នៅខែ -- នៅថ្ងៃទី០៣ ខែ៩ ឆ្នាំ២០១២ នៅក្នុងប្រតិចារឹកទំព័រ៣០ ខ្មែរ និងបារាំង៣៨។ ខ្ញុំចង់ឱ្យលោកបញ្ជាក់ទៅលើចំណុចមួយចំនួន។ លោកបានបញ្ជាក់ថា "ប៉ុន ហើយនិង ថេរ ធ្វើការដោយផ្ទាល់ជាមួយនឹង ប៉ុល ពត ហើយពួកគាត់មានតួនាទីជាលេខា។ ការបញ្ជាទាំងអស់ ដែលគាត់ -- ដែលពួកគាត់ប្រាប់មកខ្ញុំគឺគាត់ទទួលការណែនាំពីខាងលើ ឬមួយក៏គាត់បានទៅចូលធ្វើកំណត់ហេតុចូលរួមការប្រជុំជាមួយអចិន្ត្រៃយ៍ដែលបានណែនាំ -- ដែលៗគាត់បានណែនាំបន្តមកយើងខ្ញុំ"។ យើងលោកឃើញពីចំណុចទាំងអស់នេះទេ? តើលោកចាំទេ ថាលោកបាននិយាយបែបនេះប្រាប់មកអង្គជំនុំជម្រះ?

[១៣:៤៦:៣៤]

**ឆ៖** បាទ អ៊ីចឹងមែន ខ្ញុំបាននិយាយអ៊ីចឹងមែន។

**ស៖** ឥឡូវនេះយើងពិនិត្យមើលទៅលើបញ្ហានេះ។ ជាដំបូងខ្ញុំសួរលោក តើលោកធ្លាប់ចូលការ -- ចូលរួមការប្រជុំជាមួយគណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** បាទ មិនធ្លាប់ទេ។

**ស៖** ហើយលោកបានប្រាប់អំពីការរក្សាការសម្ងាត់ ហើយ ប៉ុន គាត់គោរពទៅតាមគោល-ការណ៍រក្សាការសម្ងាត់។ តើ ប៉ុន ធ្លាប់ប្រាប់ថា គាត់ធ្លាប់ចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ ហើយនិងប្រាប់

លោកថា គាត់តួនាទីជាលេខាធិការដែលចូលរួមធ្វើកំណត់ហេតុដែរឬទេ? តើគាត់ធ្លាប់ប្រាប់ដែរឬទេ?

**ឆ៖** បាទ មិនធ្លាប់ទេ តែអ្វីដែលខ្ញុំអាច អ្វីដែលខ្ញុំដឹងគឺមានអក្សរ ប៊ុន គាត់កត់ជាសារទូរលេខ ហើយជាមតិណែនាំរបស់ ប៉ុល ពត ហ្នឹងយកមកឲ្យខ្ញុំបកប្រែ។ ពាក្យពេចន៍ទាំងឡាយដែល ប៊ុន ទៅទទួលពីខាងលើមក ទាំងប៉ុន្មានក៏សារភាគច្រើន គឺជាអក្សររបស់ ប៊ុន ហ្នឹងហើយ។

[១៣:៤៨:១៣]

**ស៖** សូមអរគុណ។ ដោយយើងមានពេលវេលាកំណត់ ខ្ញុំគិតថាពេលវេលារបស់ខ្ញុំប្រហែលជាពន្យារទៅដល់សប្តាហ៍ក្រោយ ប៉ុន្តែខ្ញុំនឹងព្យាយាមបញ្ចប់នៅថ្ងៃនេះ។ ដូច្នេះខ្ញុំស្នើសុំឲ្យលោកជួយខ្ញុំក្នុងការឆ្លើយ។ ប្រសិនបើយើងសល់ពេល លោកអាចនិយាយអំពីអ្វីក៏បានដែរ ប្រសិនបើលោកប្រធានអនុញ្ញាត។ សំណួររបស់ខ្ញុំ ខ្ញុំសូមនិយាយសាជាថ្មី តើ ប៊ុន ធ្លាប់ប្រាប់លោកដែរឬទេ ថាគាត់ធ្លាប់ចូលរួមប្រជុំគណៈរដ្ឋមន្ត្រី -- គណៈអចិន្ត្រៃយ៍? គឺក្នុងតួនាទីជាលេខាដែលធ្វើការកំណត់ហេតុ សូមលោកឆ្លើយថាបាទ ឬក៏មិនមែន។

**ប្រធានអង្គជំនុំ៖**

សំណួរនេះសួររួចហើយអំមិញ ឆ្លើយរួចហើយ។ មិនបាច់ឆ្លើយទេ!

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះយើងពិនិត្យមើលទៅលើចំណុចនេះបន្តទៀតនៅក្នុងឃ្លាដដែលៗ គឺចាប់ពីដំបូងមក "ប៊ុន និង ថេរ គាត់នៅ -- គាត់ជាប់នៅផ្ទាល់ជាមួយ ប៉ុល ពត។ ដូច្នេះគាត់មានតួនាទីជាលេខាធិការ"។ តើលោកអាចប្រាប់បានដែរឬទេ ថាតើមូលដ្ឋានពិតប្រាកដដែលលោកពឹងផ្អែក ដើម្បីឲ្យយើងជឿជាក់លោកថា ប៊ុន មិនដែលប្រាប់អំពីសកម្មភាពអ្វីទាំងអស់របស់គាត់នៅក្នុង ក-១ តើផ្អែកទៅលើមូលដ្ឋានអ្វីដែរ?

[១៣:៤៩:៤២]

**លោក នង សុផង់៖**

**ឆ៖** បាទ ផ្អែកទៅលើអ្វីទាំងឡាយដែលគាត់និយាយមក គឺមិនដែលនិយាយពីរឿងរ៉ាវនៃការប្រជុំអីនៅ ក-១ ហ្នឹងទេ។ មិនដែលលេចការសម្ងាត់អីពីបងនេះបងនោះ អ៊ីចេះអ៊ីចុះក៏គ្មានដែរបាទ។ គឺមានតែការនិយាយពីបច្ចេកទេស អក្សរសម្ងាត់តែប៉ុណ្ណឹង។ និយាយតែពីរឿងអ្វីដែលជាការងារ ឯអ្វីដែលពុំមែនទាក់ទងនឹងកិច្ចការការងារគឺ គេមិនសូវមានពេលនិយាយជាមួយយើងផងបាទ។ ការងារ--

**ស៖** សូមអរគុណលោក។ តើគាត់ធ្លាប់ប្រាប់លោកថា គាត់មានតួនាទីជាលេខាធិការរបស់ ប៉ុល ពត ដែរឬទេ? ឬក៏ថាជាតួនាទីជាលេខារបស់គណៈណាមួយនៅក្នុងក-១ ដែរឬទេ?

**ឆ៖** មិនមាន ប៉ុល -- មិនមាន ប៉ុន ប្រាប់ខ្ញុំ ថាគាត់ជាលេខាទេ ប៉ុន្តែអ្វីដែល ប៉ុន ទៅទទួលមតិណែនាំ ទៅទទួលកត់ត្រាពាក្យពេចន៍របស់ ប៉ុល ពត អាហ្នឹងជាលេខាផ្ទាល់ហើយបានគាត់ទៅកត់ត្រាយកមកហ្នឹង។ ខ្ញុំអានេះជាការដែលខ្ញុំយល់ ថាគេអ្នកទៅកត់ត្រាហ្នឹង ដោយផ្ទាល់អ៊ីចឹង គឺជាលេខាធិការហើយ។

[១៣:៥១:៣៩]

**ស៖** សូមអរគុណ ដែលលោកបានបញ្ជាក់ទៅលើចំណុចនេះ។ ហើយផ្អែកទៅលើចំណុចនេះ ហើយបន្ទាប់មកលោកបាននិយាយថា ប៉ុន គាត់បានចូលរួមនៅក្នុងការប្រជុំអចិន្ត្រៃយ៍ ប្រជុំគណៈអចិន្ត្រៃយ៍ ដើម្បីធ្វើកំណត់ហេតុ។ គឺលោកធ្វើការសន្និដ្ឋានមួយ ហើយបន្ទាប់មកលោកសន្និដ្ឋានបន្ថែមទៅលើអ្វីដែលលោកបានសន្និដ្ឋាន ដោយសំអាងពីមុនមក។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន គឺថាខ្ញុំសន្និដ្ឋានទៅលើអ្វីដែលគាត់ធ្លាប់តែទៅកត់ត្រាពេល ប៉ុល ពត មានមតិណែនាំអី មានទូរលេខអី ប៉ុន គាត់ទៅ -- តាំងពីសម័យនៅជាមួយគ្នាក្នុងព្រៃក៏អ៊ីចឹងដែរ។ ពេល ប៉ុល ពត មានសារអី គាត់ក៏ឲ្យគេមកហៅ ប៉ុន ទៅ រាល់តែលើកហ្នឹង។

**ស៖** សូមអរគុណ។ តើលោកស្គាល់បុគ្គលម្នាក់ឈ្មោះ អឿន តាន ដែរឬទេ?

**ឆ៖** ខ្ញុំបានឆ្លើយក្នុង -- ជាច្រើនដងហើយ ថាខ្ញុំមិនស្គាល់ទេ។

**ស៖** សូមអរគុណ។ លោក អឿន តាន បានបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះនេះ ហើយផ្តល់សក្ខីកម្ម ហើយខ្ញុំចង់ឲ្យ -- ចង់ពិនិត្យទៅលើសក្ខីកម្មមួយចំនួនរបស់គាត់ពាក់ព័ន្ធទៅនឹងបញ្ហាសារទូរលេខ ហើយចង់ឲ្យលោកបញ្ចេញមតិទៅលើបញ្ហានេះ។ ហើយដើម្បីពិចារណាទៅលើអ្វីដែលលោកបានជម្រាបមកជំនុំជម្រះក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ។ ខ្ញុំនិយាយយោងទៅលើឯកសារ E3/86.1 គឺកំណត់ត្រាប្រតិចារឹកដែលខ្ញុំចង់ពិចារណា គឺមានច្រើនទំព័រ គឺមានប៉ុន្មានទំព័រដែលខ្ញុំចង់ពិនិត្យមើល គឺថ្ងៃ១៣ ខែមិថុនា ឆ្នាំ២០១២។ ភាសាខ្មែរគឺមានលេខ 00815998, ភាសាបារាំងគឺមានលេខ 00818066, ភាសាអង់គ្លេសគឺមានលេខ 008179 មើលទៅដូច 57។

[១៣:៥៤:២៧]

ខ្ញុំសូមចាប់ផ្តើម ខ្ញុំនឹងអានឲ្យយឺតៗ ដើម្បីពិចារណា ដើម្បីពិនិត្យទាំងអស់គ្នា។ នៅត្រង់នេះ

លោកសាក្សីនោះបានបញ្ជាក់ថា "គាត់ក្លាយទៅជាសន្តិសុខក្នុងឆ្នាំ៧០ ដល់៧៥ ហើយបន្តមកដល់៧៦, ៧៧។ ហើយ ប៉ង់ គឺជាអ្នកចាត់តាំងឲ្យគាត់ធ្វើកងការពារ"។ ហើយនៅបន្តបន្ទាប់ គាត់ -- ទំព័របន្ទាប់គាត់បាននិយាយថា "ខ្ញុំមានតួនាទីការពារកន្លែងប្រជុំ ហើយមកដល់ពេលដែលវៀតណាមចូលប្រទេសតែម្តង"។ ហើយបន្តទៅទំព័រ៦២ គឺខ្មែរមានលេខ 00816023, បារាំងគឺមានលេខ 00818098 ដល់ 99, អង់គ្លេសគឺ 00817987 គឺទំព័រ៦២។ គឺមានសំណួរដែលបានចោទសួរ ដោយបុគ្គលដែលនៅក្បែរលោកនេះដែរ "ខ្ញុំចង់សួរលោកថាតើមានទូរលេខណាមួយដែលប្រើប្រាស់ដោយ ក-១ ដែរឬទេ? ហើយចម្លើយគឺថា៖ ទូរលេខដែលប្រើប្រាស់នៅ ក-១ គឺមាន ប៉ុន្តែខ្ញុំមិនដឹងថាតើគេបញ្ជូនទៅណានោះទេ។ យ៉ាងណាក៏ដោយ ខ្ញុំដឹងថា ទូរលេខបែបនោះ គឺមាននៅ ក-១។ សំណួរ៖ តើលោកអាចប្រាប់តុលាការបានដែរឬទេ ថាតើមន្ទីរដែលគេទទួល និងបញ្ជូនទូរលេខនោះនៅកន្លែងណា មន្ទីរទូរលេខនោះ? ចម្លើយ៖ បាទ ពេលនោះ គឺមានសំបុត្រពី ប៉ុល ពត បញ្ជូនតាមទូរលេខ។ ទូរលេខហ្នឹងៗ គឺមាន ផង់ ប៉ុន្តែខ្ញុំគិតថា ប៉ង់ ទេ ហើយនិង យស់ អ្នកគ្រប់គ្រង ដើម្បីបញ្ជូនសារទៅក្រៅ ហើយនិងធានាថា នឹងមានការបញ្ជូនសារទៅក្រៅ"។

[១៣:៥៧:០១]

ឥឡូវនេះ យើងបន្តទៅទំព័របន្ទាប់ គាត់បានបន្តឆ្លើយទៀតថា "តាមពិតទៅគឺមានមនុស្សពីរនាក់ មួយគឺ ផង់ ហើយគឺមាន ផង់ ហើយនិង ប៉ង់ ដែលទទួលខុសត្រូវខាងផ្នែកទូរលេខ"។ តើលោកមានការទទួលខុសត្រូវអ្វី ទាក់ទងទៅនឹងទូរលេខ ឬក៏មន្ទីរទូរលេខ ដែល ប៉ង់ ធ្វើការនោះដែរឬទេ? ហើយចម្លើយគឺថា "បាទ គឺពី ផង់ មានក្មេងៗ។ ផង់ ហ្នឹង បញ្ជូនមកខ្ញុំនៅក-១ ដល់ទៅ ក-១ ខ្ញុំទទួលពីក្មេងៗ ផង់ នៅកន្លែងហ្នឹង ខ្ញុំបញ្ជូនឲ្យ ប៉ុល ពត"។ ដូច្នេះ ខ្ញុំនឹងព្យាយាមសង្ខេបនូវចម្លើយរបស់លោកតាមដែលអាចធ្វើបានទៅ ប្រសិនបើខុស សូមលោកជួយកែខ្ញុំផង។ "ផង់ ធ្វើការនៅមន្ទីរទូរលេខ គឺគាត់មានទទួលបានទូរលេខ ហើយក្មេងៗនៅមន្ទីររបស់គាត់នោះ យកទូរលេខនោះ មកឲ្យលោក ហើយលោកជាយកទូរលេខទាំងអស់នោះ បញ្ជូនទៅ ប៉ុល ពត។ តើត្រឹមត្រូវដែរឬទេ អ្វីដែលខ្ញុំសង្ខេបនេះ?" ឆ្លើយ "បាទ ត្រឹមត្រូវហើយ"។ ខ្ញុំសូមបញ្ឈប់ត្រឹមចំណុចនេះ ដើម្បីឲ្យយើងពិនិត្យមើល ថាតើយើងអាចទទួលបានព័ត៌មានអ្វីពីបុគ្គលមួយនេះ។ ថាតើលោកដឹងដែរឬទេ អំពីបញ្ហាទាំងនេះ?

[១៣:៥៨:៥៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ ដោយសារតែបុគ្គលដែលយើង -- ដោយសារតែខ្ញុំជាអ្នកសំណួរនេះ។ ដូច្នេះ ខ្ញុំចង់ឲ្យមានការបញ្ជាក់ទៅលើការអានឈ្មោះនេះ គឺបុគ្គលដែលនៅមន្ទីរទូរលេខនោះ ខ្ញុំមិនមែននិយាយអំពី ប៉ុន នោះទេ ដូចដែលមិត្តសហភាតារបស់ខ្ញុំបាននិយាយនោះឡើយ។ ដោយសារខ្ញុំហើយនិងសាក្សី អានថា ផង់។ ហើយសាក្សីបានកែមកខ្ញុំ នៅពេលដែលមានការច្រឡំគ្នានោះ ដើម្បីឲ្យមានការអានឈ្មោះឲ្យត្រឹមត្រូវ ហើយគាត់និយាយថាមានឈ្មោះពីរ មួយ ឈ្មោះ ផង់ ជាបុគ្គលដែលសាក្សីនោះ បានរៀបរាប់ថា ជាប្រធានមន្ទីរ ហើយមាន ប៉ង់ ដែលនៅខាងក្រៅ ដែលទទួលខុសត្រូវខាងទូរលេខ។ ខ្ញុំចង់ឲ្យយើងបញ្ជាក់ច្បាស់ទៅលើឈ្មោះទាំងពីរនេះ។ ហើយបន្ទាប់មក គឺលោកមេធាវីបានបន្តពីនេះ តាមពិតខ្ញុំចង់បញ្ជាក់ទៅលើឈ្មោះនេះ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំកំពុងតែពិនិត្យទៅលើឯកសារភាសាអង់គ្លេស គឺប្រតិចារឹកភាសាអង់គ្លេស ហើយជាអកុសលផងដែរ ដោយសារតែយើងគឺជាជនបរទេសទាំងពីររូប ចំពោះភាសាខ្មែរ ដូច្នេះ ការអានរបស់យើងអាចមានបញ្ហា។ សង្ឃឹមថា លោកសាក្សីអាចជួយយើងទៅលើបញ្ហានេះ។

[១៤:០០:៣១]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកដឹងដែរឬទេ ថាមានផ្នែកទូរលេខមួយផ្សេងទៀតនៅក្នុងក-១ ក្រៅពីផ្នែកដែលលោកបានប្រាប់យើងក្នុងរយៈពេលពីរបីថ្ងៃហ្នឹង ដែលលោកនិយាយថា នៅខាងក្នុងគឺ ប៉ុន ជាអ្នកទទួលខុសត្រូវតើមានមន្ទីរផ្សេងទេ?

**លោក នង សុផង់៖**

**ផ៖** បាទ មិនមានមន្ទីរផ្សេងក្រៅពីក្រុម ប៉ុន ហ្នឹងទេបាទ។ ហើយក៏ដែលគេដាក់ថា ការគ្រប់គ្រងទូរលេខ ប៉ង់ អ៎! ផង់ ហើយនិង ប៉ង់ ទទួលខុសត្រូវរួមបាទ។ អានេះគឺ ខ្ញុំពេលហ្នឹងមិនមានសិទ្ធិជាអ្នកទទួលខុសត្រូវរួចអីចឹងទេបាទ គឺខ្ញុំទទួលខុសត្រូវតែផ្នែកមួយនៅសាលាខ្ញុំហ្នឹងទេ។ ឯទទួលខុសត្រូវរួមពីលើខ្ញុំហ្នឹងទៀតគឺ ប៉ុន ខាងបច្ចេកទេស។ ឯ ប៉ង់ គេទទួលខុសត្រូវរួមលើមន្ទីរនានាគ្រប់ឲ្យតែមាន

ខ្សែ "ក" ទាំងប៉ុន្មានហ្នឹង ហៅថា ជាអង្គភាពស-៧១ ទាំងមូលតែម្តង។ ហ្នឹងគឺ ប៉ង់ គេនៅពីលើខ្ញុំ ពីលើ ប៉ុន អីទៀតណ៎ា ទាំងនៅលើអ្នកដែលឆ្លើយហ្នឹងទៀត។ អ៊ីចឹងអ្នកដែលឆ្លើយហ្នឹង ក៏គាត់ជាជនជាតិផង គាត់មិនសូវជាយល់ដឹងពីកិច្ចការរាក់ជ្រៅ ខាងផ្នែកទូរលេខយើងខ្ញុំទេបាទ។

[១៤:០២:២៨]

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់បំភ្លឺ ដើម្បីឲ្យយើងយល់ដូចគ្នា។ នៅពេលដែលយើងមើលចំណុច នៃចម្លើយរបស់ អឿន តាន នៅពេលដែលគាត់និយាយ ផង់ ឬក៏ ប៉ង់ តាមដែលគេអាននោះ តើលោកដឹងដែរឬទេថា មានបុគ្គលម្នាក់នៅក្នុងមន្ទីរក-១ ដែលមានឈ្មោះ ប៉ង់ ឬ ផង់ ហ្នឹង ដែលគាត់ទទួលភារៈខាងមន្ទីរទូរលេខ។ តាមដែលលោកយល់នៅពេលនោះ តើមានបុគ្គលឈ្មោះ ផង់ ហ្នឹងទទួលខុសត្រូវខាងមន្ទីរទូរលេខដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ជាថ្មីម្តងទៀត មេធាវីការពារក្តីគាត់លើកឡើងខុសទៅលើភស្តុតាងដែលបានឆ្លើយ។ ខ្ញុំស្ទាក់ស្ទើរក្នុងការលើកចំណុចនេះឡើង នៅចំពោះមុខសាក្សីណាស់។ វាអាចលក្ខណៈសមរម្យ ដែលថា ឲ្យសាក្សីនេះនៅខាងក្រៅ១០នាទីទៅ ដើម្បីយើងពិភាក្សាគ្នាទៅលើចំណុចនេះ។ អឿន តាន គាត់មិនបាននិយាយស៊ីជម្រៅទៅលើផ្ទៃក្នុង នៃមន្ទីរក-១ នោះទេ។ បើសិនជាយើងលើកឡើងខុសនោះ វាធ្វើឲ្យយើងយល់ច្រឡំទៅលើចម្លើយរបស់សាក្សីនេះ។ យើងឃើញថា យើងអាចមានភាពច្រឡំ យើងលើកឡើងភាសាបីខុសគ្នានៅចំណុចត្រង់នេះ។ ក៏ប៉ុន្តែខ្ញុំយល់ឃើញថា យើងគួរតែទុកឲ្យសាក្សីទៅក្រៅទៅ ដើម្បីយើងពិភាក្សាគ្នាទៅលើចំណុចហ្នឹង ដែលវាជាលក្ខណៈសមរម្យសម្រាប់យើង។

[១៤:០៤:២២]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន។ យើងស្តាប់ឮពីសាក្សីហើយថា តាមអ្វីដែលគាត់ដឹងនោះ គឺមានបុគ្គលតែម្នាក់ទេ ដែលគាត់កាន់មន្ទីរទូរលេខនៅក-១។ ប្រសិនបើសហព្រះរាជអាជ្ញា លើកឡើងថា មានបុគ្គលទទួលភារៈមន្ទីរទូរលេខហ្នឹងលើសពីមួយនោះ គឺវាអាចមានបុគ្គលម្នាក់ដែលមានឈ្មោះស្រដៀងហ្នឹង ប៉ុន នោះទទួលខុសត្រូវដែរ។ ហើយយើងអាច -- ព្រះរាជអាជ្ញា គឺគាត់អាចបង្ហាញភស្តុតាង នៅពេលណាដែល

គាត់យល់ថា វាពាក់ព័ន្ធទៅលើចំណុចនេះ។ ទោះបីយ៉ាងណាក៏ដោយ គឺខ្ញុំត្រូវតែចង់ដឹងផងដែរ ថាតើមានការងារអ្វីខ្លះ កើតឡើងនៅមន្ទីរក-១ ដែលខ្ញុំត្រូវការសួរទៅលើចំណុចនេះ។

[១៤:០៥:១១]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៧:៥៤]

**ប្រធានអង្គជំនុំ៖**

លោក នង សុផង់ លោកអាចបញ្ជាក់ឡើងវិញបានទេ នូវមន្ទីរនៃសារទូរលេខដែលលោកធ្វើការ ហើយនិងមន្ទីរសារទូរលេខផ្ទៃក្នុង រវាងឈ្មោះនេះ! ឥឡូវដូចជាច្រឡំបល់គ្នារវាងឈ្មោះ។ តើលោកអាចបញ្ជាក់បានទេថា ទី១ឈ្មោះ ប៉ង់។ ប៉ង់ នេះជាអ្នកណាគេ? ហើយមានការពាក់ព័ន្ធអ្វីដែលជាមួយនឹងមន្ទីរសារទូរលេខ ទាំងខាងក្នុង ទាំងខាងក្រៅ? ហើយទី២ ឈ្មោះ ប៊ុន ហើយទី៣ គឺឈ្មោះ ផង់។ ផង់ នេះតើនៅសារទូរលេខទាំងពីរកន្លែង។ ទាំងលោក កន្លែងលោកទៅធ្វើការ ហើយនិងកន្លែងលោកអះអាងថានៅក្នុងខាងក្នុងនោះ ដែលន័យមន្ទីរ ក-១ ហ្នឹងដែលលោកអះអាងថា មានឈ្មោះ ប៊ុន ជាប្រធានហ្នឹង។ តើមានឈ្មោះ ផង់ ផ្សេងទៀត ក្រៅពីលោកដែរឬទេ?

**លោក នង សុផង់៖**

**ឆ៖** បាទជម្រាបលោកប្រធាន។ អំពីឈ្មោះបី ផង់, ប៉ង់, ប៊ុន ៗ អត់មានចារនៅក្នុងហ្នឹងផង។ អត់មាននៅក្នុងរឿងហ្នឹង ប៉ុន្មានចម្លើយ ប៉ុន្មានសំណួរប៉ុន្មានហ្នឹងអត់មានដាក់ ប៊ុន ទេគឺមានឃើញប៉ង់។ ផង់ ហើយនិង ប៉ង់ ទទួលខុសត្រូវរួមបាទ។ កន្លែងនេះ ទូរលេខនេះ គឺអ្នកទទួលកិច្ចការរួមគ្នាគឺមានតែ ផង់ និង ប៊ុន ទេ។ អ្នកដែលឆ្លើយហ្នឹងថា ប៉ង់ ហ្នឹងច្រឡំពាក្យក៏មិនដឹង។ ព្រោះ ប៊ុន ហ្នឹងគឺ វា និង ប៉ង់ គឺវាអាចប្រាប់អស់លោកទៅ អស់លោកសំដៅថា ប៉ង់ៗ ហ្នឹងក៏មិនដឹង អ្នកវៃហ្នឹង ព្រោះជនជាតិគាត់និយាយខ្មែរមិនសូវច្បាស់ទេបាទ។ ប៉ង់, ប៊ុន អីហ្នឹង។ ឯ ផង់ ក្រៅពីឈ្មោះខ្ញុំដែលកាន់ខាងទូរលេខ មិនមាន ផង់ ណាដែលជាអ្នកបកប្រែនៅខាងក្នុង ក-១ ទេបាទ។ គឺមានតែ ផង់ ខ្ញុំហ្នឹងទេ។ ប៉ុន្តែ ខ្ញុំនៅសាលាសុធារស់ជាមួយក្មេងបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមាធាវីអាចបន្តតាំងសំណួរបានហើយ។

[១៤:១១:២៣]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ក៏ប៉ុន្តែតាមសក្ខីកម្មរបស់លោក អឿន តាន នោះ បង្ហាញឲ្យយើងឃើញថា គាត់ហ្នឹង ផង់ ហ្នឹង គាត់ជាបុគ្គលម្នាក់ដែលជាអ្នកបញ្ជូនសារទូរលេខនេះទៅកាន់ ប៉ុល ពត មិនមែន ប៉ុន ទេជាអ្នកយកសារទៅឲ្យ ប៉ុល ពត នោះ។ គឺបុគ្គលមួយដែលខ្ញុំលើកឡើងអម្បាញ់មិញជាអ្នកយកសារទៅឲ្យ ប៉ុល ពត។ អ៊ីចឹង តើលោកយល់ទេ អំពីរបៀបគេបញ្ជូននោះគឺយ៉ាងម៉េចដែរ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីកុំទាន់អាល់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំអធ្យាស្រ័យដែលខ្ញុំនៅតែកាត់នៅពេលនេះ។ នៅក្នុងភស្តុតាងគឺមិនមានបង្ហាញថាសាក្សី អឿន តាន គឺជា -- គាត់បង្ហាញបុគ្គលម្នាក់នោះ គឺជាបុគ្គលដែលបញ្ជូនសារនោះទៅឲ្យបុគ្គលដូចដែលគាត់ -- ដូចដែលលោកមេធាវីលើកឡើងនោះទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសួរត្រឡប់ឡើងវិញ តើលោកដឹងដែរឬទេ ថាសារទូរលេខបានយកទៅឲ្យ អឿន តាន នេះ ដើម្បីឲ្យ អឿន តាន នេះយកទៅឲ្យ ប៉ុល ពត។ តើលោកដឹងដែរឬទេចំណុចហ្នឹង?

[១៤:១២:៥០]

**ឆ៖** បាទ ខ្ញុំមិនដឹងទេ។ ពីព្រោះថា ហេតុផលអ៊ីចឹង គឺវាមានដំណាក់កាលមួយដែលនឹងនរ។ ដំណាក់កាលមួយដែលក្រោយគេដក ប៉ុន ហើយ។ ដែលគាត់និយាយពីរឿងគាត់យកសារទូរលេខទៅឲ្យ ប៉ុល ពត ផ្ទាល់អ៊ីចឹង ប្រហែល អ៎! អាហ្នឹងតាមខ្ញុំគិតទេ ថាខ្ញុំយល់ទេ។ ព្រោះដំណាក់កាល អស់លោកមិនបានបញ្ជាក់គាត់នៅឆ្នាំណា? បើពីឆ្នាំរហូតមកដល់ចុង៧៨ នេះ ពាក់កណ្តាល៧៨ នេះ ដែលមិនទាន់បាត់ ប៉ុន ហ្នឹងគឺមិនមាននរណាចាត់ចែងរឿងសារទូរលេខក្រៅពី ប៉ុន ហ្នឹងទេ។ ដែលមានសភាពដែលគេយកទៅឲ្យ ប៉ុល ពត ផ្ទាល់យ៉ាងដូច្នេះ គឺពិតជាដល់ពេលវេលាដែលជិតរត់ចេញពីភ្នំពេញហើយតាមមើល៍។ ដល់ពេលហ្នឹងគឺការងារវាច្របូកច្របល់ វាប្រញាប់ប្រញាល់ណាស់។ អ៊ីចឹង អស់លោកស្រាវជ្រាវមើលទៅ តើដំណាក់កាលណា។

**ស៖** សូមអរគុណ។ ចំណុចនេះហើយដែលខ្ញុំចង់លើកឡើងនោះ។ តើលោកនឹកឃើញដែរឬទេ នៅក្នុងសក្ខីកម្មរបស់គាត់នោះគឺ គាត់ធ្វើការនៅក្នុងឆ្នាំ៧៥, ៧៦ ដែលនៅពេលនោះ ពេលដែលគាត់ធ្វើការនោះ ប៉ុន ក៏ធ្វើការនៅទីនោះដែរ។ តើលោកអាចប្រាប់យើងខ្ញុំដែរឬទេ លោកដែលធ្លាប់ឃើញ ប៉ុន នេះយកសារដោយផ្ទាល់ខ្លួនឯងទៅឲ្យ ប៉ុល ពត ដែរឬទេ ដែលសារនោះ លោកជាអ្នករៀបចំសម្រាប់យកទៅជូន ប៉ុល ពត នោះ?

**ឆ៖** ខ្ញុំមិនដែលឃើញទេ ព្រោះក្នុងដំណាក់កាលដែល ប៉ុន នៅនឹងកន្លែងក-១ នេះ ខ្ញុំមានសិទ្ធិត្រឹមតែបញ្ជូនមកកន្លែង ប៉ុន តែប៉ុណ្ណឹង--

**ស៖** សូមអរគុណៗ។ ចំណុចនេះហើយដែលខ្ញុំចង់លើកឡើង នៅពេលដែលលោកយកសារនេះទៅឲ្យ ប៉ុន នៅមន្ទីររបស់គាត់ៗនោះគឺលោកមិនដឹងថា គេបញ្ជូនទៅណានោះទៀតទេ ក្រោយពីដែលលោកយកទៅមន្ទីរក-១ ទៅឲ្យ ប៉ុន នៅកន្លែងនោះហើយនោះ?

**ឆ៖** បាទ មិនដឹងថា ប៉ុន គាត់ចាត់ចែងយ៉ាងណាទេបាទ។

**ស៖** ហើយនៅក្នុងថ្ងៃនេះ ដែលលោកអង្គុយនៅទីនេះក៏លោកមិនអាចលើកឡើងថា លោកឯកភាព ឬក៏មិនឯកភាពជាមួយនឹង អឿន តាន ដែរ ដោយសារតែគាត់នោះ អឿន តាន នៅខាងក្នុង ហើយលោកនោះនៅខាងក្រៅក-១។ អ៊ីចឹងដែរឬទេ?

[១៤:១៦:២៦]

**ឆ៖** បាទ អ៊ីចឹងមែន។ ហើយខ្ញុំក៏មិនដឹងថា លោក តាន ហ្នឹងគាត់មានសិទ្ធិយកទូរលេខទៅឲ្យ ប៉ុល ពត ផ្ទាល់ហ្នឹង គឺក៏ខ្ញុំមិនដឹងបាទ។ ពីព្រោះដូចលោកឃើញហើយ ចម្លើយរបស់ មឿង តាន ហ្នឹងក្មេងៗខ្ញុំវាឲ្យតែរោងយាមនៅមុខក-១ ទេ ហើយខាង មឿង តាន ហ្នឹងគាត់យកទៅឲ្យផ្ទាល់បាន។ អ៊ីចឹងគឺពេលដំណាក់កាលដែលវាអត់ ប៉ុន ហើយ។

**ស៖** សូមអរគុណ។ ដូច្នេះ ចំណុចនៅកន្លែងហ្នឹងដែលលោកធ្វើការសន្និដ្ឋាន សន្មតហើយ។ លោកសន្មតថា វាអ៊ីចឹង ចម្លើយដែលលោកឆ្លើយអំមិញហ្នឹង តើមែនទេ?

**ឆ៖** ខ្ញុំសន្និដ្ឋានថា ពេលដែលបាត់ ប៉ុន ហ្នឹងហើយបានជា តាន ហ្នឹងមានសិទ្ធិយកទៅផ្ទាល់បានបាទ។

**ស៖** សូមអរគុណ។ នៅពេលនេះ នៅក្នុងសក្ខីកម្មរបស់លោកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ ទំព័រ៤៩ ជាភាសាអង់គ្លេស ខ្មែរគឺ 00842661, បារាំងទំព័រ៥១ ទៅដល់ ៥២ មានសំណួរដែលសួរ

ឡើងពាក់ព័ន្ធទៅនឹង ប៉ុល ពត ហើយចម្លើយមួយផ្នែករបស់លោកនោះ លោកឆ្លើយថា "ពាក់ព័ន្ធទៅនឹង ប៉ុល ពត គឺ ប៉ុល ពត គ្រប់គ្រងរួម គ្រប់គ្រងតំបន់រួម គាត់មានសិទ្ធិលើកឡើងសម្រេចទៅលើគ្រប់បុគ្គលទាំងអស់"។ គឺខ្ញុំយល់ថាលោកនៅតែរក្សាសម្ដី ដែលលោកបានឆ្លើយអ៊ីចឹងដដែល តើមែនដែរឬទេ?

[១៤:១៨:៤៥]

**ឆ៖** សូមលោកសម្រួលអាកន្លែងដែលខ្ញុំនិយាយហ្នឹង ដូចនិយាយតែពីរឿងសារណែនាំទេ កាលហ្នឹង។

**ស៖** នៅពេលនេះយើងនិយាយអំពី ប៉ុល ពត, ប៉ុល ពត និងអំណាចរបស់គាត់នៅក្នុងសម័យនោះ។ តាមដែលលោកយល់ថា តើគាត់មានអំណាចយ៉ាងម៉េចនោះ។ លោកបានលើកឡើងថា "ប៉ុល ពត នោះគឺគាត់មាន -- គាត់ណែនាំរួមទាំងអស់តែម្ដង អ្វីដែលគាត់មានសិទ្ធិគឺណែនាំរួមទៅលើគ្រប់បុគ្គល"។ ដែលនេះវាពាក់ព័ន្ធទៅនឹងអំណាចរបស់ ប៉ុល ពត នៅពេលនោះ។ តើអ៊ីចឹងដែរឬទេ?

[១៤:១៩:៥២]

**ឆ៖** បាទ ខាងអំណាចក៏ដូចជាការឆ្លើយឆ្លងសារ។ ការណែនាំគ្រប់បញ្ហា គឺគាត់មានសិទ្ធិនិយាយ ដែលខ្ញុំប្រាប់ -- ដែលខ្ញុំបានឆ្លើយគឺថា សាររបស់គាត់ហ្នឹង គឺគ្រប់បញ្ហា ទាំងនយោបាយ, យោធា, សេដ្ឋកិច្ច ហ្នឹងគឺគាត់មានសិទ្ធិនិយាយទូទៅបាទ។ មិនមែនតែចំពោះផ្នែកណាមួយអីនោះទេ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ នៅពេលដែលយើងមើលចម្លើយដែលលោកបានឆ្លើយ គឺនៅក្នុងផ្នែកនៃចម្លើយតាមខ្សែអាត់ ដែលលោកបានឆ្លើយ គឺឯកសារ D00/9.13 (ស៊ីក) ខ្មែរគឺ 008376 42, បារាំងគឺ 00843075, អង់គ្លេសលេខ ERN 00838744 ឯកសារ D200/9.13។ ចំណុចនេះគឺមិនឃើញមាននៅក្នុងសេចក្ដីសង្ខេបកំណត់ហេតុនៃការស្ដាប់ចម្លើយនោះទេ។ ក៏ប៉ុន្តែលោកបានសរសេរស្ដាប់ឮនៅក្នុងខ្សែអាត់ "បាទ តែអ៊ំ ប៉ុល ពត ទេ កិច្ចការទាំងអស់គឺនៅលើអ៊ំ ប៉ុល, អ៊ំទី១ ហ្នឹងហើយ"។

ដូច្នេះចំណុចនេះលោកយល់ស្របយ៉ាងនេះដែរឬទេ? ហើយលោកនៅតែរក្សាសម្ដីដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតដដែល បានន័យថា លោកឆ្លើយថា "កិច្ចការទាំងអស់គឺនៅលើ អ៊ំប៉ុល, ប៉ុល ពត អ៊ំទី១ ហ្នឹងហើយ"។ តើអ៊ីចឹងដែរឬទេ លោកនៅរក្សាសម្ដីហ្នឹងដដែល?

[១៤:២២:០៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

នៅពេលនេះ យើងឃើញមេធាវីការពារក្តីកំពុងតែតវ៉ាអំពីបញ្ហានៃការ -- នៃភស្តុតាង។ នេះគឺជាឧទាហរណ៍មួយដែលមេធាវីការពារក្តីស្នើសុំឲ្យសាក្សីលើកឡើងអំពីកិច្ចការរបស់មេដឹកនាំថ្នាក់លើ និងអំណាចរបស់ថ្នាក់លើ។ ខ្ញុំព្យាយាមមិនសួរសំណួរ -- ចំណុចទាំងអស់នេះទេ ដោយសារតែសាក្សីនោះគាត់បានប្រាប់យើងហើយថា គាត់មិនបានដឹងអំពីការងារផ្ទៃក្នុងរបស់ថ្នាក់លើនោះទេ។ ខ្ញុំគិតថា មេធាវីការពារក្តី គួរតែអង្គជំនុំជម្រះបង្គាប់គាត់ឲ្យធ្វើតាមចំណុចដែលខ្ញុំលើកឡើង។

[១៤:២២:៥៧]

**លោក ម៉ៃខល កាណាវាស៖**

នេះជាចំណុចហើយដែលខ្ញុំចង់ដឹង។ ប្រសិនបើសាក្សីគាត់មិនដឹងអំពីកិច្ចការផ្ទៃក្នុងរបស់ថ្នាក់ដឹកនាំទេ ខ្ញុំដកស្រង់សម្តីពាក្យនេះ "គឺកិច្ចការទាំងអស់នោះ ដែលខ្ញុំចង់សួរទៅលើថាលើអ៊ំ ប៉ុល ពត ឬយ៉ាងម៉េច? មុនពេលដែលគាត់នោះសម្រេច ថាតើគួរតែចម្លងជូនអ្នកណាខ្លះនៅក្នុងសារទូរលេខ"។ នេះជាចំណុចនៃសេចក្តីសន្និដ្ឋានរបស់ខ្ញុំ។ ប្រសិនបើសាក្សីនៅក្នុងសម័យនោះ គាត់ជឿថាគាត់បានដឹងថាកិច្ចការទាំងអស់ គឺនៅលើ ប៉ុល ពត គឺមិនជាបញ្ហាអ្វីនោះទេ។ ក៏ប៉ុន្តែបើសិនជាគាត់ធ្វើការទាយស្មានសន្មតនៅពេលដែលគាត់ឆ្លើយនោះ គឺវាជាចំណុចមួយដែលយើងចង់ចោទសួរ ហើយជាបញ្ហា។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់គ្មានប្រសិទ្ធភាព សាក្សីឆ្លើយតបទៅនឹងសំណួរនេះ!

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំនិយាយគឺយោងទៅលើខ្លឹមសារទូរលេខដែលត្រូវជូន គឺមានន័យថា សារទូរលេខគ្រប់ទាំងអស់ ទោះបីគេដាក់ជូន៨៧០ គណៈ៨៧០ ជូនបងអីៗទាំងអស់ គឺអត់ -- មិនអាចឲ្យភ្លេចអ៊ំទី១មួយហ្នឹងបានទេ ព្រោះថាសារអ្វីទាំងអស់ គឺអ៊ំទី១ ហ្នឹងគេដាក់មុនគេហើយបាទ។ អាហ្នឹងសូម្បីតែរឿងរ៉ាវអីផ្សេងៗក៏ត្រូវគាត់ដឹងទាំងអស់បាទ។ នេះគឺចង់បញ្ជាក់អ៊ីចឹងទេ។ ឯរឿងអំណាច ខ្ញុំអត់ដឹងបាទអំណាច សិទ្ធិ ធំប៉ុនណាៗហ្នឹង។ ប៉ុន្តែអំណាចខាងការទទួលសារ អានេះគឺដែលត្រូវចម្លងជូន គឺមិនអាច

ភ្លេច មិនបាច់ -- មិនអាចភ្លេចមិនឲ្យដាក់ចម្លងជូនអ៊ំទី១ ហ្នឹងបានទេ។ បាទនេះជាអ្វីដែលខ្ញុំបានឆ្លងកាត់កន្លងមកហ្នឹង គឺគ្រប់សារទាំងអស់។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ លោកប្រធាន ខ្ញុំត្រៀមចូលប្រធានបទមួយទៀតហើយ ដែលវាអាចឲ្យយើងហួសម៉ោងឈប់សម្រាករបស់យើង។ ដូច្នេះហើយ ខ្ញុំទុកឲ្យលោកប្រធានជាអ្នកសម្រេចទៅលើបញ្ហាម៉ោងដែលត្រូវឈប់សម្រាកនេះ ដើម្បីឲ្យយើងអាចសម្រួលទៅលើសំណួររបស់យើងខ្ញុំបាន។ ដូច្នេះហើយ យើងខ្ញុំសូមស្នើតែម្តងថា សម្រាកពេលនេះទៅ ជាជាងឲ្យខ្ញុំចូលទៅប្រធានបទមួយទៀត។ ក៏ប៉ុន្តែខ្ញុំត្រៀមខ្លួនអាចចូលប្រធានបទមួយទៀតតែម្តងនាពេលនេះក៏បានដែរ។

[១៤:២៦:១៣]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះសម្រាក១៥នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីខ្វះម្ភៃនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកដល់សាក្សីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី ខ្វះម្ភៃនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២៦ នាទី ដល់ម៉ោង ១៤:៤៥ នាទី)*

[១៤:៤៥:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនមេធាវីការពារក្តីលោក អៀង សារី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ហើយសូមជម្រាបសួរជាថ្មីម្ដងទៀត ដល់អស់លោក លោកស្រី។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឥឡូវនេះ ខ្ញុំចង់ផ្ដោតទៅលើបញ្ហាមួយទៀត គឺបញ្ហានៃប្រធានបទដែលយើងបានពិភាក្សារួចមកហើយ ប៉ុន្តែខ្ញុំនឹងព្យាយាមសង្ខេបទៅលើបញ្ហានេះ។ យើងយល់ហើយអំពីគណៈ៨៧០។ ដូច្នេះខ្ញុំសូមចាប់ផ្ដើមដោយនិយាយទៅលើចម្លើយរបស់លោក គឺ E3/64 គឺជាចម្លើយទី១របស់លោក។ ខ្ញុំពិនិត្យមើលទៅលើទំព័រ៧ ភាសាខ្មែរ គឺមានលេខ 00328028 ដល់ 029, ភាសាបារាំង គឺមានលេខ 00411697 ដល់ 98, និងភាសាអង់គ្លេសគឺមានលេខ 00334048។ ហើយចំណុចនេះ គឺលោកបាននិយាយថា "ជំហានបន្ទាប់ គឺគេបញ្ជូនទៅក្រុមវាយ ក្រុមវាយអង្គុលីលេខ រួចហើយបញ្ជូនទៅគណៈអចិន្ត្រៃយ៍ (គណៈ៨៧០) បន្ទាប់មកទៀត ប៉ុន និង ចេរ ជាអ្នកសរសេរចំណារបែងចែកសារទូរលេខនេះ ទៅអ្នកណាៗ"។ ដូច្នេះ នៅត្រង់ចំណុចនេះលោកនិយាយថា គណៈ៨៧០ គឺគណៈអចិន្ត្រៃយ៍។ ប្រសិនបើលោកបន្តទៅទំព័រ១៣ គឺប៉ុន្មានទំព័រចុះមកក្រោម ភាសាខ្មែរគឺមានលេខ 00328035 ដល់ 37, ភាសាបារាំង គឺមានលេខ 00411703 ដល់ 04, និងភាសាអង់គ្លេស គឺមានលេខ 00334054។

[១៤:៤៨:០៤]

នៅត្រង់ចំណុចនេះ គេសួរលោកដូចតទៅ "នៅពេលដែលមានការបញ្ជូន ជានិច្ចកាលត្រូវបញ្ជូនទៅគណៈអចិន្ត្រៃយ៍ទាំងអស់គ្នា ឬក៏មានផ្ញើខ្លះទៅអ្នកនេះ អ្នកនោះ មិនបញ្ជូនទាំងអស់ទេ? ឆ្លើយ៖ ភាគច្រើនដាក់ជូនគណៈ៨៧០ ប៉ុន្តែករណីខ្លះ មិនបានបញ្ជូនទៅគណៈអចិន្ត្រៃយ៍ទាំងអស់គ្នាទេ គឺបញ្ជូនទៅអ្នកដែលពាក់ព័ន្ធដែលមានភារកិច្ចទទួលខុសត្រូវឆ្លើយឆ្លង។ សំណួរ៖ តើមានន័យដូចម្ដេច ជូនគណៈ៨៧០? សំដៅលើអ្នកណា? ចម្លើយ៖ សំដៅលើគណៈមជ្ឈិមទាំងមូលតែម្ដង"។ បាទ ខ្ញុំសូមផ្អាកត្រឹមចំណុចនេះ។ នៅក្នុងចម្លើយមួយលោកនិយាយថា "គណៈអចិន្ត្រៃយ៍ គឺគណៈ៨៧០" ហើយបន្ទាប់មកទៀត លោកនិយាយថា "គឺគណៈមជ្ឈិម" ទៅវិញ។ តើលោកធ្វើការទាយស្មាន ឬក៏សន្មត នៅពេលដែលលោកផ្ដល់ចម្លើយទាំងអស់នេះ ឬមួយក៏លោកផ្ដល់ចម្លើយនេះ ទៅលើចំណេះដឹង ឬក៏ផ្អែកទៅលើការដឹងពិតប្រាកដ?

[១៤:៤៩:៤៨]

**លោក នង សុផង់៖**

**ឆ៖** ចម្លើយនេះ គឺជាចម្លើយដែលខ្ញុំបានធ្លាប់ឃើញសារទូរលេខ គេច្រើន -- វាច្រើនបែបច្រើនយ៉ាង ដែលគេខ្លះ គេដាក់ថា "គណៈ៨៧០" ខ្លះគេដាក់ថា "អង្គការ៨៧០" ហ្នឹង។ ឯការសន្និដ្ឋានរបស់ខ្ញុំថាយ៉ាងណា វាមិនប្រាកដដែរក្នុងខ្លួនខ្ញុំនេះ។ ពីព្រោះសារភាគច្រើនដែលគេជូន "គណៈ៨៧០" លោកមើលទៅគឺ ឧទាហរណ៍៖ សារមួយលេខ២៣៦ គោរពជូន គណៈ៨៧០។ ហើយនរណាខ្លះ--

**ស៖** សូមអភ័យទោស។ សូមកាត់លោកបន្តិច ព្រោះខ្ញុំចង់ឲ្យលោកឆ្លើយសំណួររបស់ខ្ញុំសិន។ ប្រហែលជាមានការបាត់ក្នុងពេលបកប្រែនៅទំព័រមួយនៃចម្លើយរបស់លោក លោកនិយាយថា "គណៈ៨៧០ គឺជាគណៈអចិន្ត្រៃយ៍"។ ហើយពីរបីទំព័រក្រោយមក ឃើញចម្លើយដដែលហ្នឹង គឺចម្លើយដែលលោកចុះហត្ថលេខាថា ពិតត្រឹមត្រូវ និងគ្រប់គ្រាន់ហ្នឹង គឺលោកនិយាយថា "គណៈ៨៧០ សំដៅលើគណៈមជ្ឈិម"។ ថាតើ "គណៈ៨៧០" ហ្នឹង ជាគណៈអី? គឺយើងមានចម្លើយពីរ។ តើលោកពិតជាដឹងដែរឬទេ នៅពេលដែលលោកធ្វើការផ្តល់ចម្លើយនោះ តើលោកដឹងថា "គណៈ៨៧០" ហ្នឹងជាអ្វីទេ?

[១៤:៥១:៤៧]

**ឆ៖** បាទ ពាក្យដែលខ្ញុំប្រាកដក្នុងចិត្តជាងគេ គឺថាពាក្យ "មជ្ឈិម" តែម្តងបាទ។ បើ--

**ស៖** សូមអភ័យទោស ខ្ញុំសូមកាត់លោក ខ្ញុំចង់ឲ្យលោកឆ្លើយ។ គឺយើងមាន "គណៈមជ្ឈិម" និង" គណៈអចិន្ត្រៃយ៍"--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

កុំអាលទាន់បន្តទៀត!

សាក្សីកុំអាលទាន់ឆ្លើយ!

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន។ សហភាតាខ្ញុំបានសួរដដែលៗទៅលើសាក្សី ហើយសាក្សីគាត់ព្យាយាមផ្តល់ -- គាត់ព្យាយាមផ្តល់ចម្លើយ។ នៅពេលដែលសាក្សីមិនអាចផ្តល់ចម្លើយដែលមេធាវីគាត់ចង់បាន គាត់កាត់សាក្សីខ្ញុំ។ ដូច្នេះ ខ្ញុំចង់ឲ្យអង្គជំនុំជម្រះប្រាប់ទៅដល់សាក្សី -- ប្រាប់ទៅដល់មេធាវី ដើម្បីឲ្យបន្ថយសំឡេងនៅក្នុងការនិយាយ ដើម្បីផ្តល់នូវការគោរពដល់សាក្សី ហើយកុំឲ្យកាត់សាក្សីបែបនេះ។ សូមអរគុណ។

**លោក ម៉ែខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវី កុំកាត់សាក្សីទៀត។ សូមបណ្តោយ ទុកលទ្ធភាពឱ្យសាក្សី មានលទ្ធភាពឆ្លើយតបទៅអ្វីដែលបទពិសោធន៍របស់គាត់ឆ្លងកាត់បញ្ហានេះ ពីព្រោះបញ្ហានេះ គាត់មានការពន្យល់ពាក់ព័ន្ធនឹងបញ្ហានេះជាច្រើនចំណុចខុសៗគ្នា។

យើងឃើញដែរ បញ្ហានេះឃើញច្រើនហើយ។ យើងបារម្ភថានៅពេលដែលសួរសាក្សី ហើយសាក្សីឆ្លើយ ហើយយើងកាត់។ ក្រែងលោបារម្ភថា បន្តិចទៀតសាក្សីលែងឆ្លើយ។

[១៤:៥៣:២៦]

**លោក ម៉ែខល កាណាវាស៖**

លោកប្រធាន ខ្ញុំគិតទៅដល់ពេលវេលា ដើម្បីកុំឱ្យសាក្សីគាត់ត្រឡប់មកវិញនៅអាទិត្យក្រោយទៀត។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់ទៅសួរនៅសំណួរដដែលនេះ។ នៅទំព័រ៧ គឺភាសាអង់គ្លេស គឺទំព័រហ្នឹងលោកនិយាយថា "គណៈ៨៧០ គឺជាគណៈអចិន្ត្រៃយ៍ គឺគណៈអចិន្ត្រៃយ៍" អត់មាននិយាយពីបក្សទេនៅទីនេះ។ ហើយពីរបីទំព័រក្រោយមកទៀត គឺលោកនិយាយថា "គណៈ៨៧០ គឺគណៈមជ្ឈិម"។ ខ្ញុំសូមសួរលោក តើលោកដឹងថា "គណៈអចិន្ត្រៃយ៍" និង "គណៈមជ្ឈិម" ហ្នឹងខុសគ្នាដែរឬទេ? ខ្ញុំសូមបញ្ចប់ត្រឹមនេះសិន ឱ្យលោកឆ្លើយ។

**លោក នង សុផង់៖**

**ឆ៖** បាទ វាមានខុសគ្នា។

**ស៖** តើលោកដឹងថាមានខុសគ្នាដែរឬទេនៅក្នុងចម្លើយរបស់លោក? មានភាពខុសគ្នាដែរឬទេនៅក្នុងចម្លើយរបស់លោក?

[១៤:៥៥:០៧]

**ឆ៖** បាទ ហ្នឹងគឺខុសគ្នាមែន ព្រោះអាមួយលោកដាក់នៅក្នុងរង្វង់ក្រចក "គណៈអចិន្ត្រៃយ៍" តែនេះដាក់ថា "គណៈអចិន្ត្រៃយ៍ គឺគណៈមជ្ឈិម"។

**ស៖** នៅពេលដែលគេអាចចម្លើយនេះឲ្យលោកស្តាប់ ហើយលោកចុះហត្ថលេខាថា វាត្រឹមត្រូវ ឬពិតប្រាកដនោះ តើលោកអាចប្រាប់យើងបានដែរឬទេ ថាតើនៅពេលនោះ គឺនៅពេលដែលលោកបាន ពិនិត្យគឺ--

**ប្រធានអង្គជំនុំ៖**

លោកសួរម្តងទៀត ភាសាខ្មែរស្តាប់មិនយល់ទេ ពីព្រោះបកប្រែមិនទាន់។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឥឡូវនេះយើងដឹងថា នៅពេលដែលលោកបញ្ចប់ការសម្ភាស ហើយប្រាំអាទិត្យក្រោយ មកគេត្រឡប់មកជួបលោកមួយសាទៀត គេអានននូវចម្លើយរបស់លោក ហើយគេ -- ហើយលោកចុះ ហត្ថលេខាដោយលោកមិនបានធ្វើការកែប្រែ។ លោកប្រាប់យើងថា មានភាពខុសគ្នារវាង "គណៈ អចិន្ត្រៃយ៍" និង "គណៈមជ្ឈិម"។ ដូច្នេះ សំណួររបស់ខ្ញុំដែលចង់សួរគឺថា តើវាគ្រាន់តែជាការយល់-- តើវាការយល់ខុសរបស់លោកដែលយល់ថា "គណៈអចិន្ត្រៃយ៍" គឺ "គណៈមជ្ឈិម" ឬមួយក៏លោកមិន ដឹងថា "គណៈអចិន្ត្រៃយ៍" ខុសពី "គណៈមជ្ឈិម" នៅពេលនោះ?

[១៤:៥៧:០៣]

**ឆ៖** បាទ ខ្ញុំមិនបានសង្កេតលើ ចាប់អារម្មណ៍លើពាក្យហ្នឹងថា ការបកស្រាយខុសមួយថា "គណៈអចិន្ត្រៃយ៍" មួយថា "គណៈមជ្ឈិម"។ ប៉ុន្តែសារហ្នឹងវាមិនដែលឃើញថា គេដាក់ "គណៈ អចិន្ត្រៃយ៍" ផ្សេង "គណៈមជ្ឈិម" ផ្សេង អ៊ីចឹងគេអត់មានបែងចែក អ៊ីចឹងបានថា ឧទាហរណ៍សារនេះ ខ្ញុំសំអាងលើសារនេះ ជូនគណៈ៨៧០ ហើយចម្លងជូនអ៊ំ, អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, បងខៀវ។ អ៊ីចឹងខ្ញុំសន្និត ថា អ្វីដែលមិនមានគណៈមជ្ឈិមទាំងអស់ទេ។ អាហ្នឹងគឺជាគណៈអចិន្ត្រៃយ៍ហើយ អ្នកប៉ុន្មាននាក់ហ្នឹង។

**ស៖** សូមអរគុណ។ ដូច្នេះការយល់ដឹងរបស់លោកនៅថ្ងៃនេះ គឺៗថាគណៈ៨៧០ គឺគណៈ អចិន្ត្រៃយ៍។ គឺវាមិនមែនជាគណៈមជ្ឈិមទេ តើលោកចង់និយាយបែបនេះ តើមែនដែរឬទេ?

[១៤:៥៨:២៦]

**ឆ៖** បាទ អ៊ីចឹងមែន ចង់បញ្ជាក់ថា គណៈ៨៧០ គឺអចិន្ត្រៃយ៍បាទ។

**ស៖** សូមអរគុណ។ លោកក៏បានបញ្ជាក់នៅក្នុងសក្ខីកម្មរបស់លោកផងដែរ ដែលថា ពាក្យនេះ ត្រូវបានគេប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក។ គឺនិយាយអំពីគណៈ៨៧០, មន្ទីរ៨៧០, ៨៧០ ហើយ ចម្លើយនេះគឺមាននៅក្នុងប្រតិចារឹកថ្ងៃទី០៤ ខែ៩ ឆ្នាំ២០១២ ហើយយើងពិនិត្យមើលថាតើលោកនិយាយ

អ្វីខ្លះនៅទំព័រនោះ? ខ្មែរគឺមានលេខ 00844493, ភាសាបារាំង គឺមានលេខ គឺទំព័រ៦០ ដល់ ៦១, អង់គ្លេស៥៥ លោកនិយាយថា៖ "ខ្ញុំមិនប្រាកដពាក់ព័ន្ធទៅនឹងពាក្យ "គណៈ" ហេតុដូច្នេះហើយខ្ញុំបញ្ជាក់ថា ខ្ញុំមិនច្បាស់។ ពេលខ្លះខ្ញុំនិយាយថា គណៈ៨៧០ ពេលខ្លះខ្ញុំថា មន្ទីរ៨៧០ និងពេលខ្លះគេដាក់ ៨៧០ ទទេ។ អ៊ីចឹង ធ្វើឲ្យខ្ញុំពិបាកក្នុងការជម្រាបជូនអង្គសវនាការឲ្យបានច្បាស់លាស់លើបញ្ហានេះ។ វាពិបាកនឹងចំណាំណាស់បាទ"។ ខ្ញុំគិតថាលោកនៅរក្សាចម្លើយនេះដដែល តើមែនអ៊ីចឹងទេ -- តើមែនដែរឬទេ?

**ឆ៖** បាទ ខ្ញុំរក្សាទុកដដែល។

**ស៖** ហើយបន្ទាប់មក នៅថ្ងៃទី០៣ ខែ៩ ឆ្នាំ២០០៩ គឺមានសំណួរមួយដែលគេសួរទៅលើលោក។ ខ្ញុំចង់ឲ្យលោកពិនិត្យមើលទំព័រដែលមានលេខ 00844223, ភាសាបារាំងគឺ 69, ភាសាអង់គ្លេស 69 ដែលគេចាប់ផ្តើមសួរលោក "គឺថាអ្វីដែលលោកអាន គឺសំដៅទៅលើមន្ទីរ គឺ៨៧, ៨៧០ គឺវាប្រហែលគ្នាទៅនឹងមន្ទីរ៨៧០ គឺសំដៅទៅលើគណៈមជ្ឈិម។ សូម្បីតែពាក្យ "អង្គការ" នោះ អង្គការ៨៧០ ហ្នឹងក៏អាចប្រើជំនួសទៅលើពាក្យ ម-៨៧០ ឬក៏មន្ទីរ ៨៧០ ឬក៏អាចប្រើជំនួសដោយ ៨៧០ ទទេ ដែលនេះគឺជាមជ្ឈិម"។ នេះគឺជាសំណួរដែលចោទសួរដោយតំណាងព្រះរាជអាជ្ញា។

[១៥:០១:៣២]

ដូច្នេះ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថាការកំណត់ផ្សេងៗគ្នាដូចជា អង្គការ៨៧០, ម-៨៧០ ឬក៏៨៧០ ហ្នឹងសំដៅទៅលើគណៈ ដូចដែលលោកបានយល់នោះ តើសំដៅទៅលើមជ្ឈិម ហើយលោកឆ្លើយថា "បាទ ខ្ញុំយល់ដូច្នេះមែនបាទ"។ ហើយនេះគឺជាអ្វីដែលបានចោទសួរ ហើយនិងចម្លើយដែលលោកផ្តល់ឲ្យ។

**ឆ៖** បាទ សំដៅកន្លែងមជ្ឈិមអ៊ីចឹងមែន សំដៅទៅលើមជ្ឈិម ឲ្យតែមានលេខ៨៧០ ហ្នឹង។

**ស៖** ដូច្នេះ ខ្ញុំសូមឲ្យមានការបញ្ជាក់ថាមិនមានការបកប្រែខុស។ លោកនិយាយថា គណៈ ៨៧០ គឺផ្អែកទៅតាមការយល់ដឹងរបស់លោកនៅពេលនោះ គឺគណៈអចិន្ត្រៃយ៍។ ហើយឥឡូវនេះក្នុងចម្លើយនៃសក្ខីកម្មរបស់លោក ដែលលោកនិយាយអំពី៨៧០ ក្នុងបរិបទផ្សេងៗគ្នា លោកទទួលថាពាក្យហ្នឹងអាចប្រើជំនួសគ្នាបាន។ ហើយនៅទីនេះលោកនិយាយថា សំដៅទៅលើគណៈមជ្ឈិម។ តើលោកធ្វើការបែងចែងរវាង៨៧០ និងគណៈ៨៧០ ដោយផ្អែកទៅលើអ្វីដែលលោកបានបញ្ជាក់ថា លោកមិនយល់ថាមួយជាមួយណានៅពេលនោះ តើអ៊ីចឹងមែន?

[១៥:០៣:២០]

**ឆៈ** បាទ ខ្ញុំវាមិនប្រាកដថា រឿងគណៈ និងអង្គការ នេះវាពិបាកបែងចែកថាជាអចិន្ត្រៃយ៍ ឬជាមជ្ឈិម។ ប៉ុន្តែអ្វីដែលខ្ញុំប្រាកដក្នុងចិត្ត គឺលេខ៨៧០។ បើ៨៧០ ហ្នឹងហើយ គឺៗច្បាស់ជាមជ្ឈិមហើយ ដែលច្បាស់ជាងគេគឺមជ្ឈិមតែម្តង ហើយនិងលេខ៨៧០ តែម្តង គឺច្បាស់ហ្នឹងតែម្តង។

**សៈ** សូមអរគុណ។ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់បញ្ជាក់ថា តើលោកឆ្លើយនឹងសំណួររបស់ខ្ញុំ ឬក៏យ៉ាងម៉េច? ខ្ញុំព្យាយាមបង្ហាញឲ្យឃើញថា លោកទាយ ឬក៏លោកសន្មតលើចំណុចហ្នឹង? ឬក៏លោកសន្មតថា ម-៨៧០, គណៈ៨៧០ គឺជាគណៈអចិន្ត្រៃយ៍ ឬក៏គណៈមជ្ឈិម? លោកនៅក្នុងថ្ងៃនេះហាក់ដូចជាចង់បានន័យថា លោកមិនដឹងទេ។ នេះជាចំណុចដែលខ្ញុំវាយតម្លៃទៅលើអ្វីដែលលោកឆ្លើយហ្នឹង ត្រឹមត្រូវដែរឬទេ?

**ឆៈ** បាទ ពាក្យថាមិនប្រាកដ គឺមិនច្បាស់ គឺមិនដឹងបាទ។ តែអ្វីដែលដឹងប្រាកដ គឺលេខ៨៧០ មានន័យថា "មជ្ឈិម" បាទ។

[១៥:០៥:០៥]

**សៈ** សូមអរគុណ។ យើងចូលទៅដល់ចំណុចមួយទៀតដែលសាក្សីមួយរូបទៀតគាត់ឆ្លើយប្រាប់យើងគឺលោក ដេវីដ ឆេនដ៍ល័រ ហើយយើងឃើញថាឈ្មោះនោះ គឺក៏មានការជំទាស់ពីខាងសហព្រះរាជអាជ្ញា។ លោក ដេវីដ ឆេនដ៍ល័រ គឺជាអ្នកប្រវត្តិវិទូប្រវត្តិសាស្ត្រកម្ពុជា។ នៅពេលដែលយើងមើលចម្លើយរបស់លោក ដេវីដ ឆេនដ៍ល័រ ដែលបានឆ្លើយ ខ្ញុំយោងទៅលើសក្ខីកម្មថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ខ្មែរត្រង់ទំព័រ 00826644 ទៅដល់ 45, បារាំងគឺ 00828607 ទៅដល់ 08, អង់គ្លេសគឺ 00828755។ នៅក្នុងចម្លើយនេះ សំណួរបានសួរទៅកាន់គាត់ ហើយខ្ញុំអានចំណុចដែលពាក់ព័ន្ធ លោកបានពន្យល់នៅក្នុងចម្លើយរបស់លោកថា "ប៉ុល ពត គឺក៏គេហៅគាត់ថា ជា៨៧០ផងដែរ"។ ដកស្រង់សម្តីៈ ឆ្លើយ ចម្លើយដែលគេឆ្លើយ "ពិតជាអ៊ីចឹង ខ្ញុំមិនចង់លើកមិនច្បាស់នោះទេ ក៏ប៉ុន្តែគឺគេមិនបានចាត់ទុកគាត់ថា ជាអង្គការនោះទេ។ លេខកូដរបស់គាត់សម្រាប់គាត់នោះ គឺថា៨៧០តែប៉ុណ្ណោះ"។

[១៥:០៦:៥១]

ក្រោយមកនៅទំព័រ៧០ ជាភាសាអង់គ្លេស ឬក៏ខ្មែរ 00826664 ទៅដល់ 65, បារាំង 00828637 ទៅដល់38, អង់គ្លេស 00828785។ បន្ទាប់មកសាក្សីរូបនោះឆ្លើយថា មួយផ្នែកដែល

ពាក់ព័ន្ធនោះឆ្លើយថា "ខ្ញុំពិតជាដឹងថា ខ្ញុំបានឆ្លើយចំណុចនេះ ជាច្រើនដងច្រើនសាដោយមិនបានយោងទៅដីកាដំណោះស្រាយថា មន្ទីរ៨៧០ គឺសំដៅលើ ប៉ុល ពត នោះទេ។ នេះគឺជាអ្វីដែលខ្ញុំដឹងតាមការស្រាវជ្រាវរបស់ខ្ញុំ ហើយខ្ញុំបានសរសេរចំណុចហ្នឹង"។ នេះគឺជាសំណួររបស់ខ្ញុំ តើលោកចង់ផ្តល់ចម្លើយយ៉ាងម៉េចពាក់ព័ន្ធនឹងការវិភាគរបស់លោក ដេវីដ ឆេនដ៍ល័រ ក្នុងនាមជា គាត់ជាអ្នកប្រវត្តិសាស្ត្រដែលគាត់និយាយថា ៨៧០ នេះគឺសំដៅលើ ប៉ុល ពត ក្នុងសម័យនុំុង?

[១៥:០៨:១២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

យើងខ្ញុំសូមជំទាស់ចំណុចហ្នឹង យើង -- ភាគីសួរសាក្សីទៅលើអង្គហេតុ ហើយសាក្សីនេះត្រូវបានសួរម្តងហើយម្តងទៀត ដូច្នេះហើយវាមិនសមរម្យដែលឲ្យសាក្សីផ្តល់ជាយោបល់ទៅលើយោបល់របស់អ្នកជំនាញនោះទេ។ ចំណុចនេះ គឺមិនអាចឲ្យធ្វើអ៊ីចឹងបាននោះទេ គឺសាក្សីបានបញ្ជាក់ទៅលើអ្វីគាត់បានប្រាប់អង្គហេតុនោះហើយ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំនឹងរៀបចំសំណួររបស់ខ្ញុំឡើងវិញលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើ ប៉ុល ពត គេធ្លាប់គេ -- គេហៅ ប៉ុល ពត ថា ៨៧០ ដែរឬទេ តាមអ្វីដែលលោកដឹងនោះ?

[១៥:០៩:០៨]

**លោក នង សុផង់៖**

**ឆ៖** តាមខ្ញុំដឹង គឺចំពោះបុគ្គល ប៉ុល ពត គេមិនដែលហៅថា បង៨៧០ អ៊ីចឹងទេ។ អ៊ីចឹងគឺ ៨៧០ មិនមែនជាបុគ្គលទេ បើគេហៅគាត់គឺ បងប៉ុល អ៊ីចឹងតែម្តងបាទ។ ប៉ុល គឺ ប៉ុល ពត ហើយ ឬមួយក៏ បងទី១ អានេះគឺគេសំដៅលើបុគ្គល ប៉ុល ពត ហើយ។ ក្នុង--

**ស៖** សូមអរគុណ។ តាមលោកដឹងមន្ទីរ៨៧០ នេះមិនដែលសំដៅថាជា ប៉ុល ពត នោះទេតាមដែលលោកដឹងនោះ?

**ឆ៖** បាទ ពាក្យថា "មន្ទីរ៨៧០" ក៏មិនមែនសំដៅលើ ប៉ុល ពត ដែរបាទ។

**ស៖** ខ្ញុំមិនដែលនិយាយថា "មន្ទីរ៨៧០" ទេ ខ្ញុំថា "៨៧០" តាមលោកដឹង គេមិនដែលហៅ ប៉ុល ពត ឬក៏គេក៏មិនយល់ថា ប៉ុល ពត នេះជា៨៧០ ដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គេមិនដែលប្រើ ប៉ុល ពត ហ្នឹងថា ៨៧០ ទេ។ បើគេដាក់លេខ ៨៧០ ហ្នឹង គឺជារួម បាទ។ ពហុវចនៈហើយ មិនមែនឯកវចនៈទេ។

**ស៖** សូមអរគុណ។ នៅពេលនេះ ខ្ញុំចូលទៅដល់ប្រធានបទចុងក្រោយរបស់ខ្ញុំ ហើយខ្ញុំចង់សុំសួរលោកអំពីចម្លើយដែលលោកបានឆ្លើយ។ គឺឯកសារ E3/64 ខ្មែរ 00328039 ទៅដល់ 40, បារាំង 00411707, អង់គ្លេស 00334057។ ខ្ញុំនឹងសួរសំណួរមួយទៅលោកពាក់ព័ន្ធទៅនឹងទូរលេខមួយដែលបានបង្ហាញលោក គឺទូរលេខ១៥ គឺឯកសារ E3/169។ យើងមិនមើលលើសារទូរលេខនេះទេ គឺ E3/1679 សំណួរដែលគេសួរលោកនោះគឺថា "នៅក្នុងទូរលេខនេះ គឺមានស្នើសុំឲ្យផ្ដល់យោបល់។ តើអ្នកទទួលទូរលេខនោះ ត្រូវឆ្លើយតបទៅនឹងសំណើរបែបនេះដែរឬទេ?" អ្នកស៊ើបអង្កេតសួរអ៊ីចឹងទៅកាន់លោក ហើយលោកឆ្លើយដូច្នេះថា "ពាក់ព័ន្ធនឹងបញ្ហាជាក់លាក់មួយចំនួន ប្រសិនបើ ប៉ុល ពត អាចដោះស្រាយបាននោះ គឺគាត់ឆ្លើយតបភ្លាមតែម្ដង។ ក៏ប៉ុន្តែបញ្ហាខ្លះមិនអាចក្ដាប់បាន ជួនកាលការងារទាក់ទងនឹងគណៈទាំងមូលដើម្បីសម្រេច ដូច្នេះ ប៉ុល ពត អាចកោះប្រជុំគណៈអចិន្ត្រៃយ៍ ដើម្បីសម្រេច"។ ដូច្នេះ យើងមើលចម្លើយដែលលោកឆ្លើយនេះ។ បញ្ហាខ្លះៗបើ ប៉ុល ពត អាចដោះស្រាយបាន គាត់ឆ្លើយតបទៅភ្លាម។ តើលោកដឹងដោយរបៀបណា? ផ្អែកតាមបទពិសោធន៍ដែលលោកធ្លាប់ឆ្លងកាត់ ទើបលោកនិយាយដូច្នេះ ឬក៏យ៉ាងម៉េច?

[១៥:១៣:២៤]

**ឆ៖** បាទ លើសារទូរលេខនេះ ខ្ញុំធ្លាប់មានបទពិសោធន៍ដែលលោកឆ្លើយភ្លាមៗដែរ។ បញ្ហាដែលដូចខាងសមរភូមិគេស្នើយោបល់អី ស្នើមតិណែនាំអី លោកក៏បន្ទាប់ពីទទួលសារហើយ ក៏បន្តិចក្រោយមកក៏វាមានសារមួយឆ្លើយតបទៅវិញអ៊ីចឹងដែរ។ អានេះបញ្ហាដែលធ្លាប់ជួបប្រទះកន្លងមក ប៉ុន្តែបញ្ហាខ្លះដែល បញ្ហាច្រើន បញ្ហាច្រើនស្មុគស្មាញ ឃើញថាមិន -- គាត់មិនចេះតែឆ្លើយភ្លាមៗបានទេបាទ។ ហើយរឿងហ្នឹងក៏ខ្ញុំបានបញ្ជាក់ហើយថា ខ្ញុំមានប្រើពាក្យ "អាចគាត់កោះហៅប្រជុំអីណាណីហ្នឹង" ខ្ញុំសូមឲ្យលុបចេញហើយ ថាពាក្យដែលខ្ញុំប្រើថាពេល "អាច" ហ្នឹង វាពុំមែនជាការពិតទេបាទ។ វាជាការវិភាគ ការវិភាគរបស់ខ្ញុំទេ។ វាអាចអ៊ីចេះ អាចអ៊ីចុះហ្នឹង។

**ស៖** សូមអរគុណ។ នៅពេលនេះ លោកស្នើជូនអង្គជំនុំជម្រះថា អង្គជំនុំជម្រះគួរតែដកចំណុចដែលជាចម្លើយរបស់លោកនេះចេញ ដែលថា "ប៉ុល ពត អាចកោះប្រជុំអចិន្ត្រៃយ៍ដើម្បីសម្រេច"។ ជាពិសេសដោយលោកខ្លួនឯងនេះ គឺមិនដែលធ្លាប់ចូលរួមនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍។ តើអ៊ីចឹងដែរឬទេ?

[១៥:១៥:៣៩]

**ផ៖** បាទ អ៊ីចឹងមែន ខ្ញុំមិនដែលប្រជុំជាមួយអចិន្ត្រៃយ៍ទេបាទ។

**ស៖** ដូច្នេះ ត្រង់ចំណុចនេះហើយ ទើបលោកស្នើសុំឱ្យអង្គជំនុំជម្រះដកចេញ ចំណុចដែលថា "ប៉ុល ពត អាចកោះប្រជុំគណៈអចិន្ត្រៃយ៍ ដើម្បីសម្រេចនេះ" ដោយសារតែលោកគ្រាន់តែធ្វើការសន្មតតែប៉ុណ្ណោះ។ តើអ៊ីចឹងមែនដែរឬទេ លោកសុំឱ្យដកចេញចំណុចហ្នឹង?

**ផ៖** បាទ ពិតដូច្នោះមែន។

**ស៖** សូមអរគុណ ខ្ញុំអរគុណច្រើន។ នៅពេលដែលយើងមើលចម្លើយបន្ទាប់របស់លោកមួយទៀត គឺ E3/67 គឺជាឧទាហរណ៍មួយទៀត ខ្មែរទំព័រលេខ 00294543 ទៅដល់ 44, បារាំង គឺ 00374939 ទៅដល់ 40, អង់គ្លេស 00483972។ ទំព័រ១០ ជាភាសាអង់គ្លេស បើសិនជាខ្ញុំមើលទៅ។ នៅពេលដែលយើងមើលឯកសារនេះ គេបានសួរសំណួរលោកនៅក្នុងកថាខណ្ឌ១៩ ចំណុច១៩ ដែលក្នុងនោះ និយាយអំពីសេចក្តីណែនាំរបស់ ៨៧០ ចុះថ្ងៃ៣ ខែមករា ឆ្នាំ១៩៧៨។ ហើយលោកបានលើកឡើងថា "ខ្ញុំស្គាល់អក្សរនេះ ជាអក្សរ ប៉ុល ពត។ ព្រោះគាត់មានសិទ្ធិកែ"។ ខ្ញុំសូមសួរលោកដូចតទៅ៖ តើលោកពិតជាស្គាល់អក្សរ ជាអក្សរ ប៉ុល ពត ឬក៏លោកគ្រាន់តែសន្មតថា ជាអក្សររបស់ ប៉ុល ពត ដោយសារតែ ប៉ុល ពត ហ្នឹង គាត់មានសិទ្ធិកែ?

[១៥:១៧:៤៧]

**ផ៖** ខ្ញុំធ្លាប់ឃើញអក្សរ ប៉ុល ពត ហើយអក្សរដែលគាត់កែហ្នឹង គឺដូចគ្នា ដែលខ្ញុំធ្លាប់ឃើញបាទ។

**ស៖** សូមអរគុណ។ បន្ទាប់មកលោកបានឆ្លើយទៀតថា "ឯកសារនេះ ប្រហែលជារបស់គណៈ ៨៧០ ចេញពីមកការប្រជុំពិភាក្សាគ្នាហើយ បានធ្វើជាកំណត់ហេតុ ប៉ុន្តែមិនដឹងថាមានអ្នកណាខ្លះចូលរួម ហើយក៏មិនដឹងថា ប្រជុំនៅឯណាដែរ។ ប៉ុន្តែ ជួនកាលក៏ជាគំនិតរបស់ ប៉ុល ពត សរសេរ ហើយបានដាក់ឱ្យប្រជុំគណៈ៨៧០ អនុម័ត ចំណុចណាសំខាន់ គាត់គូសបន្ទាត់ក្រហមពីក្រោម"។ ហើយ

បន្ទាប់មកចម្លើយរបស់លោកឆ្លើយតទៀត។ ខ្ញុំឃើញថា ក្នុងនេះ លោកប្រើពាក្យ "ប្រហែល"។ នេះគឺជាចំណុចមួយទៀតហើយ ដែលគេឲ្យឯកសារមួយមកឲ្យលោកមើល ហើយឲ្យលោកវិភាគ ហើយក្រោយពីអានវិភាគទៅ លោកគ្រាន់តែធ្វើការសន្និដ្ឋានតែប៉ុណ្ណោះ។ តើអ៊ីចឹងដែរឬទេ?

[១៥:១៩:១៤]

**ឆៈ** បាទ អ៊ីចឹងមែន ពីព្រោះខ្ញុំ -- គេមិនបានផ្ដល់ដំបូន្មានឲ្យខ្ញុំពីថាការប្រើពាក្យ "ប្រហែល" យ៉ាងម៉េចៗហ្នឹងទេ ពេលនោះ។ អ៊ីចឹង ខ្ញុំនិយាយពីការវិភាគ ការយល់របស់ខ្ញុំ គឺខ្ញុំប្រើពាក្យ "ប្រហែល" ហ្នឹង គឺមកពីខ្ញុំមិនដឹង បាទ។ អ៊ីចឹង សូមថាមិនដឹងច្បាស់បាទ។

**សៈ** សូមអរគុណ។ នៅពេលនេះ យើងមើលឯកសារ E3/67 ដដែល ជាចម្លើយកំណត់ហេតុនៃការស្ដាប់ចម្លើយ ខ្មែរ គឺ 00294546 ទៅដល់ 47, 00374941 នេះជាភាសាបារាំង, អង់គ្លេស 004300 -- អង់គ្លេស 00483974 ទំព័រ១២។ លោក គេបានបង្ហាញឯកសារមួយទៅលើលោក គឺពាក់ព័ន្ធនឹងគណៈអចិន្ត្រៃយ៍ ខែតុលា ថ្ងៃ០៩ តុលា ឆ្នាំ៧៥។ នៅពេលនេះ យើងមើលអ្វីដែលលោកមើល លោកនិយាយពីទំព័របន្ទាប់។ ខ្មែរគឺត្រង់ទំព័រលេខ ERN 48 ដល់ 49, អង់គ្លេស 76, បារាំង 42 ទៅ 43។ "យោងតាមការវិភាគរបស់ខ្ញុំ អ្នកខ្លះមិនអនុវត្តមានតាមសេចក្ដីសម្រេចទាំងអស់របស់អចិន្ត្រៃយ៍នោះទេ ដោយសារតែពួកគេគិតថា ពួកគេជាថ្នាក់ដឹកនាំ។ ខ្ញុំបានឃើញឯកសារមួយចុងក្រោយអម្បាញ់មិញ មិនបានសុំយោបល់ពីគណៈអចិន្ត្រៃយ៍ទេ គឺបានបាញ់សម្លាប់មនុស្ស ៤០នាក់រួចហើយ ទើបបានរាយការណ៍តាមក្រោយ ហើយក្នុងករណីខ្លះមិនរាយការណ៍ក៏មានដែរ"។ ផ្អែកតាមចម្លើយមួយនេះ តើនេះគឺជាការវិភាគដែលផ្អែកទៅលើបទពិសោធន៍របស់លោកទៅកន្លែងនោះផ្ទាល់ ដែលលោកចុះទៅតាមមូលដ្ឋាន ឬគ្រាន់តែលោកមើលឯកសារហើយ ក្រោយមកព្យាយាមពន្យល់ និងសន្និដ្ឋានចំពោះអ្នកស៊ើបអង្កេតតែប៉ុណ្ណោះ?

[១៥:២១:០៤]

**ឆៈ** បាទ ខ្ញុំបានដាក់តាំងពីដើមទីថា "ការវិភាគរបស់ខ្ញុំផ្ទាល់"បាទ។ អ៊ីចឹងគឺជាការវិភាគទេ ហើយក៏មិនមែនដែលខ្ញុំបានធ្លាប់ចុះទៅពិនិត្យនៅមូលដ្ឋានអ្វីដែរ។ គឺគ្រាន់តែឃើញឯកសារដែលអស់លោក ចៅក្រមស៊ើបអង្កេតមកបង្ហាញ ហើយជួយពន្យល់គាត់តែប៉ុណ្ណឹង។

**សៈ** នៅពេលដែលលោកជួយធ្វើការវិភាគទៅលើចំណុចនេះ។ ព្រឹកមិញនេះ យើងឃើញថាមានការជំទាស់លើកឡើងដោយខាងតំណាងសហព្រះរាជអាជ្ញា។ ដូច្នេះ នៅពេលដែលលោកធ្វើការ

វិភាគនោះ គឺលោកបានសន្និដ្ឋានដែរឬទេ ដោយសារតែលោកមិនមានចំណេះ -- មានការដឹងដោយផ្ទាល់ទៅលើហេតុការណ៍នោះ ទើបលោកសន្និដ្ឋានអ៊ីចឹង នៅពេលដែលលោកធ្វើការវិភាគនោះ។ តើអ៊ីចឹងដែរឬទេ?

**ផ៖** បាទ អ៊ីចឹងមែន។ ដោយឃើញខ្លឹមសាររបស់សារដែលក្នុងទូរ អ៎! នៅក្នុង -- សារដែលឯកសារដែលលោកបានជូនមកខាងខ្ញុំឱ្យជួយពន្យល់បាទ។

**ស៖** ប្រសិនបើខ្ញុំយល់ចម្លើយ៣ថ្ងៃនេះ លោកប្រាប់អង្គជំនុំជម្រះថា ឲ្យមានការប្រុងប្រយ័ត្នទទួលយកចម្លើយរបស់លោក។ ជាពិសេសនៅត្រង់ចំណុចដែលលោកធ្វើការសន្និដ្ឋាន ឬក៏សន្និដ្ឋានដោយមានមូលដ្ឋាន, សន្និដ្ឋាន ឬក៏វិភាគ។ នេះចំណុចដែលលោកចង់បានន័យស្នើសុំទៅអ៊ីចឹងតើមែនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:២៤:២៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំជំទាស់ សំណួរនេះគឺជាសំណួរមួយស្មុគស្មាញ ហើយវាជាសំណួរនាំមុខ។ អង្គជំនុំជម្រះបានណែនាំមុន នាពេលមុនរួចមកហើយ ហើយធ្វើការបែងចែកចម្លើយដែលស្មាន និងចម្លើយដែលផ្អែកតាមបទពិសោធន៍។ ផ្អែកតាមការណែនាំទាំងអស់នេះហើយ វាមិនសមស្របសួរឲ្យសាក្សីផ្តល់ការណែនាំទៅដល់អង្គជំនុំជម្រះថា តើគួរតែវាយតម្លៃទៅលើភស្តុតាងនេះយ៉ាងម៉េចនោះទេ? សំណួរទាំងឡាយនោះគួរតែធ្វើយ៉ាងណា មិនសួរឲ្យសាក្សីធ្វើការណែនាំទៅដល់អង្គជំនុំជម្រះទៅលើកាលវិភាគនៃភស្តុតាងនោះទេ។ គឺយើងគួរតែសួរតែសំណួរទាំងឡាយណាដែលផ្អែកទៅតាមបទពិសោធន៍ដែលសាក្សីបានដឹងបានដោយផ្ទាល់។ ហើយជាពិសេស គឺការសន្និដ្ឋានដោយផ្អែកទៅលើការដឹងរបស់សាក្សី។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ សាក្សីរូបនេះក្នុងរយៈពេលបីបួនថ្ងៃនេះ គឺគេបានសួរអំពីរបៀបដែលចម្លើយនោះគឺកត់ត្រាឡើងយ៉ាងម៉េច ហើយគាត់ចុះហត្ថលេខាហ្នឹងយ៉ាងណា។ ហើយពេលខ្លះទៅនៅពេលដែលយើងបង្ហាញចម្លើយរបស់គាត់ផ្នែកមួយចំនួននោះ គឺគាត់បានបង្ហាញម្តងហើយម្តងទៀត

ថាគាត់សន្មត គាត់ស្មាន។ ហើយគាត់បានផ្តល់ការវិភាគនុ៎ង គឺពេលខ្លះទៅគឺគាត់មិនបានដឹងដោយផ្ទាល់នោះទេ គឺគ្រាន់តែ -- គឺគាត់គ្រាន់ទៅមើលលើឯកសារហើយ គាត់ធ្វើការវិភាគនិយាយដូច្នោះតែម្តង។ ដូច្នេះហើយទើបក្នុងរយៈពេលបីបួនថ្ងៃនេះ គឺគាត់ស្នើសុំឲ្យអង្គជំនុំជម្រះទាត់ចោលចំណុចទាំងឡាយណាដែលពាក់ព័ន្ធថា គាត់គ្រាន់តែមានមតិទៅលើចំណុចហ្នឹង គាត់សន្មត គាត់ស្មាន។

ដូច្នេះហើយ នៅក្នុងថ្ងៃនេះ ខ្ញុំគ្រាន់តែសួរគាត់ថា តើសាក្សីហ្នឹងគាត់មានបំណងឲ្យអង្គជំនុំជម្រះនោះមានការប្រុងប្រយ័ត្នទៅលើចម្លើយរបស់គាត់ ជាពិសេសឲ្យមានការប្រុងប្រយ័ត្នទៅលើចំណុចណាដែលវាពាក់ព័ន្ធទៅនឹងចម្លើយរបស់គាត់។

[១៥:២៦:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៧:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះយល់ឃើញថាការជំទាស់របស់សហព្រះរាជអាជ្ញាមានសុពលភាព។ ចៅក្រមនឹងពិចារណាបញ្ហានានាដែលបានលើកឡើងក្នុងពេលដេញដោលសាក្សីរូបនេះ។ ទាំងភស្តុតាងដែលគាត់ផ្តល់ជូនទាំងមូល ឬក៏ចំណុចជាក់លាក់នៃភស្តុតាងរបស់គាត់ ហើយចៅក្រមនេះ គឺមានសមត្ថភាពអាចធ្វើការសន្និដ្ឋានទៅលើភស្តុតាងរបស់សាក្សីបាន។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៍។ គឺជាការសង្ខេបទៅលើអ្វីដែលសាក្សីបានឆ្លើយតែប៉ុណ្ណោះ។ ក្នុងនាមជាមេធាវីការពារក្តី អៀង សារី រួមជាមួយលោក អាង ឧត្តម នោះគឺខ្ញុំសូមថ្លែងអំណរគុណកលោកដែលលោកមកចូលរួមផ្តល់សក្ខីកម្មនៅទីនេះ។ ហើយសូមឲ្យលោកធ្វើដំណើរទៅវិញដោយសុវត្ថិភាព។ ហើយសូមអរគុណផងដែរ អង្គជំនុំជម្រះទាំងមូល។

[១៥:២៨:៣៥]

*(សម្រាករយៈពេលខ្លី)*

[១៥:២៩:០៤]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ សល់ពេលវេលាតិចតួចដែរ ហើយនិងអង្គជំនុំជម្រះថាកិច្ចដំណើរការសម្រាប់ថ្ងៃនេះ ដល់ពេលត្រូវសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃពុធ ទី១២ ខែកញ្ញា ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយថ្ងៃពុធ ហ្នឹងសវនាការនឹងដំណើរដោយស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-307 ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា បន្ទាប់ពីសំណួរបឋមរបស់អង្គជំនុំជម្រះ។

អង្គជំនុំជម្រះសូមជម្រាបថានៅថ្ងៃទី១០ និងថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះមិនធ្វើសវនាការទេ ដោយហេតុថាចៅក្រមនៃអង្គជំនុំជម្រះត្រូវប្រជុំពិភាក្សាផ្ទៃក្នុង ដើម្បីសម្រេចលើបញ្ហាចាំបាច់បន្ទាន់មួយចំនួន ហើយនិងបញ្ហាមួយចំនួនទៀត មានចៅក្រមប្រឹក្សាមួយចំនួននៃអង្គជំនុំជម្រះវិសាមញ្ញ -- នៃអង្គជំនុំជម្រះសាលាដំបូងត្រូវចូលរួមប្រជុំនៅក្នុងគណៈកម្មាធិការវិធានផ្ទៃក្នុង និងនីតិវិធីនៃ អ.វ.ត.ក។ សូមសាធារណជន និងភាគីជ្រាប។

លោក នង សុផង់ ការស្ដាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅដែលលោកចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានអញ្ជើញមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះច្រើនថ្ងៃកន្លងមកនេះ ហើយដែលមានភាពអំណត់អត់ធ្មត់ ខិតខំអស់ពីសមត្ថភាព។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគនៅក្នុងការស្វែងរកការពិតនៃរឿងក្ដីនេះ។ ហើយសូមលោកជួបតែសំណាងល្អ ហើយនិងធ្វើដំណើរវិលត្រឡប់ទៅវិញទៅប្រកបដោយសុវត្ថិភាព។

[១៥:៣០:៥២]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ។ ស្រដៀងនេះដែរ គឺសាក្សីបម្រុងដែលមានរហស្សនាម TCW-307 ក៏ឲ្យជូនគាត់ត្រឡប់ទៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ អ.វ.ត.ក នេះវិញនៅព្រឹកថ្ងៃពុធ ទី១២ ខែកញ្ញា ឆ្នាំ២០១២។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅ

ព្រឹកថ្ងៃពុធ ទី១២ ខែកញ្ញា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៣១ នាទី)*